ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីព្រាងច្បាប់

# ក្រមព្រហ្មទណ្ឌ

# ភាគទី ១

# គោលការណ៍គ្រឹះ

## គន្ថីទី ១

## គោលការណ៍ទូទៅនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ

### មាតិកាទី ១

### លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ

#### ជំពូកទី ១

#### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** ដែនអនុវត្តនៃក្រមព្រហ្មទណ្ឌ

ក្រមព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថា ជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ ។

**មាត្រា ២.-** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស

ច្បាប់បញ្ញត្តិថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ ។

នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ៣.-** គោលការណ៍នីត្យានុកូលភាព

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។

មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។

**មាត្រា ៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវតែអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

**មាត្រា ៥.-** ចេតនាប្រព្រឹត្តបទល្មើស

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។

ក៏ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការមិនយកចិត្តទុកដាក់ ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។

**មាត្រា ៦.-** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង ។ ចៅក្រមមិនអាចពង្រីកវិស័យអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ ។

**មាត្រា ៧.-** ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនបានប្រកាសដោយតុលាការទេ ។

**មាត្រា ៨.-** លក្ខខណ្ឌនៃការអនុវត្តច្បាប់ខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ វិស័យអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៩.-** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ ។

# ជំពូកទី ២
## ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

**មាត្រា ១០.-** ការអនុវត្តច្បាប់ដែលស្រាលជាង

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ឈប់ ។

ប្រសិនបើការផ្តន្ទាទោសជាស្ថាពរ ត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត ។

**មាត្រា ១១.-** ការអនុវត្តច្បាប់ដែលស្រាលជាង ឬធ្ងន់ជាង

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែការផ្តន្ទាទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។

**មាត្រា ១២.-** សុពលភាពនៃកិច្ចនីតិវិធី

ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលបានបំពេញស្របតាមបទប្បញ្ញត្តិចាស់ឡើយ ។

# ជំពូកទី ៣
# ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ
## ផ្នែកទី ១
## បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅដែនដី នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៣.-** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ព្រហ្មទណ្ឌកម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមមានលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.-** ទីកន្លែងប្រព្រឹត្តបទល្មើស

បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានេះ ។

**មាត្រា ១៥.-** បទល្មើសដែលបានប្រព្រឹត្តនៅលើនាវាកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៦.-** បទល្មើសដែលបានប្រព្រឹត្តនៅលើនាវាបរទេស

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ ។

**មាត្រា ១៧.-** បទល្មើសដែលបានប្រព្រឹត្តនៅលើយន្តហោះកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៨.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្តើមប្រព្រឹត្តនៅកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជា អ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះត្រូវបានបំពេញ :

១-បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង ។

២-អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស ។

**មាត្រា ១៩.-** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល

ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល ។

## ផ្នែកទី ២

## បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ២០.-** បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទល្មើសឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋកម្ពុជានៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់កម្ពុជា ត្រូវអនុវត្តទៅលើបទល្មើសមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋកម្ពុជានៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានបែងចែកឱ្យផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះ ។

បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ ។

**មាត្រា ២១.-** ជនរងគ្រោះជាជនជាតិខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទល្មើសឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេសទៅលើជនរងគ្រោះ ដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

**មាត្រា ២២.-** ការធ្វើបណ្តឹងចោទប្រកាន់

នៅក្នុងករណីដែលមានចែងនៅក្នុងមាត្រា ២០ (បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្ត ដោយពលរដ្ឋខ្មែរ) និងមាត្រា ២១ (ជនរងគ្រោះជាជនជាតិខ្មែរ) ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ ។ ការចោទប្រកាន់ត្រូវតែមានបណ្តឹងរបស់ជនរងគ្រោះ ឬរបស់សិទ្ធិវន្ត ឬបណ្តឹងជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជា ទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត ។

**មាត្រា ២៣.-** សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា :

១-បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ។

២-បទល្មើសក្លែងត្រានៃព្រះរាជាណាចក្រកម្ពុជា ។

៣-បទល្មើសក្លែងរូបិយវត្ថុជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

៤-បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

៥-បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៤.-** ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តបានប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេស ចំពោះអំពើល្មើសដដែល ក្នុងករណីដែលមានការផ្តន្ទាទោសបុគ្គលនោះ បុគ្គលនោះបានបង្ហាញថាខ្លួនបានទទួលទោសរបស់ខ្លួនរួចហើយ ឬក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២

## ការទទួលខុសត្រូវព្រហ្មទណ្ឌ

## ជំពូកទី ១

## ចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត

**មាត្រា ២៥.-** និយមន័យនៃចារី

ត្រូវចាត់ទុកថាជាចារី គឺបុគ្គលណាប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់ ។

ត្រូវចាត់ទុកថាជាចារីដែរ គឺបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

**មាត្រា ២៦.-** និយមន័យនៃសហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកថាជាសហចារីដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

**មាត្រា ២៧.-** និយមន័យនៃការប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបានកាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

១-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស គឺមានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស ។

២-ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស មិនមែនជាការចាប់ផ្ដើមអនុវត្តទេ ។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្ដន្ទាទោសទេ ។

**មាត្រា ២៨.-** និយមន័យនៃអ្នកផ្ដើមគំនិត

ត្រូវចាត់ទុកថាជាអ្នកផ្ដើមគំនិត គឺបុគ្គលណា :

១-ជម្រុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមតាមការណែនាំ ឬបញ្ជា ។

២-បង្កឱ្យមានបទឧក្រិដ្ឋ ឬមជ្ឈិម ដោយផ្ដល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន ។

អ្នកផ្ដើមគំនិតនឹងអាចត្រូវផ្ដន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ។

អ្នកផ្ដើមគំនិតនៃបទឧក្រិដ្ឋ ឬមជ្ឈិម ត្រូវទទួលទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ២៩.-** និយមន័យនៃអ្នកសមគំនិត

ត្រូវចាត់ទុកថាជាអ្នកសមគំនិត គឺបុគ្គលណាដែលជួយសម្រួលដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬមជ្ឈិម ដោយផ្ដល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួនដោយចេតនា ។

អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវទទួលទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ៣០.-** និយមន័យនៃអ្នករាជការសាធារណៈ ពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត

១-អ្នករាជការសាធារណៈមានន័យថា :

ក/ បុគ្គលដែលបំពេញការងារនៅក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ ឬស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬ

ជាបណ្តោះអាសន្នក្តី ទោះជាបានទទួលប្រាក់ឈ្នួល ឬមិនបានក្តី ដោយមិនគិតពីឋានៈ អាយុ វ័យរបស់បុគ្គលនោះឡើយ ។

ខ/ បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

២-ពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត មានន័យថាជាសមាជិកព្រឹទ្ធសភា រដ្ឋសភា សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

## ជំពូកទី ២
## មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.-** មូលហេតុនៃការមិនទទួលខុសត្រូវ ដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននេះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននេះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.-** ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ ។

បុគ្គលដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនេះ មិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ស្តែង ។

ប៉ុន្តែ ចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនេះបានប្រព្រឹត្តបទល្មើសដែលបញ្ញត្ត អនុញ្ញាត ឬហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនេះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.-** ការការពារស្របច្បាប់

បុគ្គលដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់នោះ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

១-បទល្មើសត្រូវទុកថា ត្រឹមត្រូវដោយការចាំបាច់ក្នុងការការពារប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ ។

២-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា ។

៣-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារខ្លួនដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

**មាត្រា ៣៤.-** សច្ចាធារណ៍នៃការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារខ្លួនស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានន្ទូវការចូលក្នុងពេលយប់ ដោយការគាស់ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចាធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចាធារណ៍នេះ អាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើសនោះ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

សភាពនៃការចាំបាច់ ត្រូវមានលក្ខខណ្ឌដូចតទៅ :

១-បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន ។

២-ត្រូវមានសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬនៃការបង្ខំ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មណាមួយទេ ។

## ជំពូកទី ៣
## ការទទួលខុសត្រូវខាងព្រហ្មទណ្ឌនៃអនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពព្រហ្មទណ្ឌ ត្រូវបានកំណត់ត្រឹមអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។

**មាត្រា ៤០.-** ប្រភេទនៃវិធានការ

វិធានការអប់រំ វិធានការតាមដាន វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើ

របាយការណ៍ស្តីពីកិរិយាមាយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា ។ បុគ្គលនេះផ្តល់ព័ត៌មាន ដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

## ជំពូកទី ៤
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌនៃនីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

# មាតិកាទី ៣
# និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ
## ជំពូកទោល
## ស្ថានទម្ងន់ទោសដោយឡែក

**មាត្រា ៤៣.-** ក្រុមមានការចាត់តាំង

ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬជាសន្និដ្ឋភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន ។

**មាត្រា ៤៤.-** ការគិតទុកជាមុន

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស ។

**មាត្រា ៤៥.-** ការកាប់គាស់ទម្លុះទម្លាយ

ការកាប់គាស់ទម្លុះទម្លាយគឺជាអំពើបង្ខំធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញគ្រឿងបិទទ្វារ ឬរបង ទោះបីមានប្រភេទយ៉ាងណាក៏ដោយ ។

ត្រូវចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយ :

១-ការប្រើប្រាស់កូនសោក្លែង ។

២-ការប្រើប្រាស់កូនសោដែលបានមកដោយឧបាយកលទុច្ចរិត ។

៣-ការប្រើប្រាស់គ្រប់ឧបករណ៍ ដើម្បីធ្វើឱ្យគ្រឿងបិទដំណើរការដោយគ្មានការបង្ខំ ខូចខាត ឬបំផ្លិចបំផ្លាញទេ ។

**មាត្រា ៤៦.-** ការផ្លោះរបងចូល

ការផ្លោះរបងចូល គឺជាអំពើចូលទៅក្នុងទីកន្លែងណាមួយដោយឆ្លងរបង ឬដោយ ចូលតាមទ្វារ ឬបង្អួច ដែលមិនមែនសម្រាប់ធ្វើជាផ្លូវចូលទេ ។

**មាត្រា ៤៧.-** អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ

អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬធ្វើឱ្យមានរបួស ។

ត្រូវបានចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀត ដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណីដូចតទៅ ៖

១-វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឱ្យរបួស ឬគំរាមកំហែង ។

២-វត្ថុមានទីដៅសម្រាប់សម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង ។

ការប្រើប្រាស់សត្វដើម្បីសម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង ត្រូវចាត់ទុកដូចបានប្រើប្រាស់អាវុធដែរ ។

**មាត្រា ៤៨.-** ការពួនស្ទាក់

ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំជនរងគ្រោះនៅទីកន្លែងណាមួយ ក្នុងគោលបំណងឆ្មក់បុគ្គលនោះ ដើម្បីប្រព្រឹត្តបទល្មើស ។

# គន្ថីទី ២

# ទោស

## មាតិកាទី ១

## ប្រភេទនៃទោស

### ជំពូកទី ១

### មូលទោស

**មាត្រា ៤៩.-** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៥០.-** អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ

កាលបើបទល្មើសត្រូវផ្តន្ទាទោសដោយដាក់ពន្ធនាគារ ច្បាប់កំណត់អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អប្បបរមា និងអតិបរមានៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

**មាត្រា ៥១.-** ការទម្ងន់ទោស និងការសម្រាលទោស

អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ អាចបន្ថែម ឬបន្ថយនៅក្នុងលក្ខខណ្ឌដែលចែងដោយក្រមនេះ ។

**មាត្រា ៥២.-** និយមន័យនៃបទឧក្រិដ្ឋ

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវវងនោះ :

១-ជាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

២-ជាទោសដាក់ពន្ធនាគារមានរយៈពេលដែលមានថិរវេលាលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៥៣.-** និយមន័យនៃបទមជ្ឈិម

បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៥៤.-** និយមន័យនៃបទលហុ

បទល្មើសជាបទលហុ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៥៥.-** ការគណនាអំពីថិរវេលានៃទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ ១ (មួយ) ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ ។

**មាត្រា ៥៦.-** លក្ខខណ្ឌដោយឡែកនៃការបញ្ចប់នៃទោស

តាមគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃអាទិត្យ ឬថ្ងៃបុណ្យនោះ ។

**មាត្រា ៥៧.-** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ។

**មាត្រា ៥៨.-** ផលនៃទោសពិន័យ

ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិការដ្ឋ ។

## ជំពូកទី ២

## ទោសបន្ថែម

**មាត្រា ៥៩.-** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ដកលិខិតបើកបរ ។

៥-ហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ហាមឃាត់ចំពោះការចូល និងស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-រឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-រឹបអូសវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

១០-រឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-រឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១២-រឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ។

១៤-បណ្តេញចេញពីអាបណសញ្ញាសាធារណៈ ។

១៥-បិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៧-បិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងសារព័ត៌មាន ។

១៩-ការចាក់ផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនា-គមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗ ទៀត ។

**មាត្រា ៦០.-** លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម

ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់ ។

ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។

**មាត្រា ៦១.-** សិទ្ធិជាពលរដ្ឋដែលអាចដកបាន

សិទ្ធិជាពលរដ្ឋដែលអាចដកបានដូចមានចែងក្នុងចំណុច ១ នៃមាត្រា ៥៩ (ប្រភេទនៃទោសបន្ថែម) រួមមាន :

១-សិទ្ធិបោះឆ្នោត ។

២-សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ។

៣-សិទ្ធិបំពេញការងារក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។

៤-សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬជាអណត្តិគាហករបស់តុលាការ ។

៥-សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់ ។

៦-សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ ។

ទោសនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

**មាត្រា ៦២.-** ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ

ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ មិនអនុវត្តទៅលើការបំពេញអាណត្តិដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ ឬការទទួលខុសត្រូវខាងសហជីពទេ ។ ការហាមនេះ មិនអាចអនុវត្តចំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មានទេ ។

ទោសនេះអាចជាស្ថាពរ ឬក៏បណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

តុលាការត្រូវបញ្ជាក់មុខរបរដែលត្រូវហាមឃាត់ ។

**មាត្រា ៦៣.-** ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ

ការហាមឃាត់ចំពោះការបើកបរយានយន្ត មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំទេ ។

**មាត្រា ៦៤.-** ការព្យួរលិខិតបើកបរ

ទោសព្យួរលិខិតបើកបរ មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួនទៅក្រឡាបញ្ជីតុលាការ ។ លិខិតបើកបរត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៦៥.-** ការហាមឃាត់ចំពោះការស្នាក់នៅកន្លែងមួយចំនួននៅកម្ពុជា

ទោសហាមឃាត់ការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិត ចំពោះការមានមុខនៅកន្លែងខ្លះនៃដែនដីព្រះរាជាណាចក្រកម្ពុជា ។ ទោសនេះមិនអាចលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម ។

តុលាការកំណត់បញ្ជីនៃកន្លែងដែលហាមឃាត់ និងកំណត់ថិរវេលានៃការហាមឃាត់ ។

ការហាមឃាត់ការស្នាក់អាស្រ័យ រួមមានវិធានការតាមដាន ។

ទណ្ឌិតត្រូវតែ :

១-ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាល ដែលតុលាការបានចាត់តាំង ។

២-ត្រូវចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬកងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ ។

តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន ។

សេចក្តីសម្រេចរបស់តុលាការ ត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**មាត្រា ៦៦.-** ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ការហាមឃាត់ចំពោះការចាកចេញពីដែនដីកម្ពុជា មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ។

ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ ។ លិខិតឆ្លងដែននេះ ត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនបានទេ ក្នុងរយៈពេលដែលកំពុងទទួលទោសនោះ ។

**មាត្រា ៦៧.-** ការហាមឃាត់ចំពោះការចូល និងស្នាក់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស

ការហាមឃាត់ចំពោះទណ្ឌិតបរទេសនូវការចូល និងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចជាស្ថាពរ ឬជាបណ្តោះអាសន្នដែលមានរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះ នាំឱ្យមានការបណ្តេញទណ្ឌិតឱ្យចេញដោយពេញច្បាប់នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ ។

**មាត្រា ៦៨.-** ការរឹបអូស

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចតទៅ :

១-ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើស ។

២-វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

ក៏ប៉ុន្តែ ការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

**មាត្រា ៦៩.-** ការចាត់ចែងទ្រព្យដែលរឹបអូស

កាលបើការរឹបអូសបានក្លាយទៅជាស្ថាពរ របស់ដែលរឹបអូសក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងអំពីការប្រគល់ផ្សេងពីនេះ ។

រដ្ឋអាចលក់ ឬបំផ្លាញទ្រព្យដែលរឹបអូស តាមនីតិវិធីស្ដីពីការលក់ទ្រព្យសម្បត្តិរដ្ឋ ។

**មាត្រា ៧០.-** ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ

ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ អាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។ ការហាមឃាត់នេះត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧១.-** ការបណ្ដេញចេញពីអាបណសាធារណៈ

ការបណ្ដេញចេញពីអបណសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងអាបណទាំងឡាយដែលស្នើឡើងដោយ :

១-រដ្ឋ ។

២-សម្ព័ន្ធភាពដែនដីវិមជ្ឈការ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលត្រូវបានធ្វើសម្បទាន ឬត្រួតត្រាដោយរដ្ឋ ឬដោយសម្ព័ន្ធភាពដែនដីវិមជ្ឈការ ។

ទោសបណ្តេញចេញនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៧២.-** ការបិទគ្រឹះស្ថាន

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថានដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង ។

ទោសបិទគ្រឹះស្ថាននេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៧៣.-** ហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលត្រូវប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬជាបណ្តោះអាសន្នដែលមានរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៧៤.-** ការបិទផ្សាយសេចក្តីសម្រេច

ទោសបិទផ្សាយសេចក្តីសម្រេច អនុវត្តនៅកន្លែងដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ឡើងដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ទេ ។ ការបិទផ្សាយអាចធ្វើទាំងស្រុង ឬតាមសម្រង់ ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

ក្នុងករណីមានការបំបាត់ចោល ការលាក់បំបាំង ឬការហែកចោលសេចក្តីប្រកាសនេះ ត្រូវតែធ្វើការបិទផ្សាយជាថ្មី ។ ការបិទផ្សាយនេះ ត្រូវអ្នកដែលបំបាត់ចោល ឬអ្នកហែកចោល ជាអ្នកចេញសោហ៊ុយ ។

**មាត្រា ៧៥.-** ការចេញផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ

ទោសផ្សព្វផ្សាយសេចក្ដីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ ។

សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត ។ ក្នុងករណីមិនគោរពតាមទណ្ឌិត អាចត្រូវដាក់គុកបង្ខំរូបកាយ ។

បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្ដីសម្រេច សារព័ត៌មានមិនអាចបដិសេធការផ្សព្វផ្សាយនេះបានទេ ។

**មាត្រា ៧៦.-** ការផ្សព្វផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសតាមមធ្យោបាយទូរគមនា-គមន៍សោតទស្សន៍

ទោសចាក់ផ្សាយជាសាធារណៈនូវសេចក្ដីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយតុលាការ ។ ការផ្សាយនេះមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ទេ ។ ការផ្សាយអាចផ្សាយទាំងស្រុង ផ្សាយតាមសម្រង់ ឬផ្សាយតាមនិទ្ទេស ។ សោហ៊ុយនៃការផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

**មាត្រា ៧៧.-** ចិរវេលានៃការអនុវត្តទោសបន្ថែម

លើកលែងតែមានសេចក្ដីសម្រេចផ្ទុយរបស់តុលាការ ទោសបន្ថែមទាំងឡាយដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦ និង ៧ នៃមាត្រា ៥៩ (ប្រភេទនៃទោសបន្ថែម) ត្រូវអនុវត្ត នៅពេលផុតទោសពន្ធនាគារ ។

## ជំពូកទី ៣
## ទោសជំនួស
## ផ្នែកទោល
## ការងារសហគមន៍

**មាត្រា ៧៨.-** និយមន័យនៃការងារសហគមន៍

កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬ

ស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍ ។

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃជាអត្ថប្រយោជន៍របស់រដ្ឋ របស់សមូហភាពដែនដី របស់នីតិបុគ្គលតាមច្បាប់សាធារណៈ របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ។

**មាត្រា ៧៩.-** អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍

នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ ។

**មាត្រា ៨០.-** របបគតិយុត្តនៃការងារសហគមន៍

ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃក្រមការងារ ជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី ។

ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ ។

**មាត្រា ៨១.-** គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ

រដ្ឋត្រូវតែចេញសោហ៊ុយជួសជុលការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍ ។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ នៅក្នុងសិទ្ធិជនរងគ្រោះ ។

## ផ្នែកទី ២
## ការស្ដីបន្ទោស

**មាត្រា ៨២.-** របបគតិយុត្តនៃការស្ដីបន្ទោស

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្ដីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ :

១-ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើស

បានបញ្ចប់ ។

២-ការខូចខាតត្រូវបានជួសជុលរួចហើយ ។

៣-ជនល្មើសមានការបង្ហាញឆន្ទៈក្នុងការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ ។

## មាតិកាទី ២

## ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស

## ជំពូកទី ១

## ការមិនរាងចាល

**មាត្រា ៨៣.-** អានុភាពនៃការមិនរាងចាល

ការមិនរាងចាលមានអានុភាព នាំឱ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម នៅក្នុងលក្ខខណ្ឌដែលមានចែងដោយជំពូកនេះ ។

**មាត្រា ៨៤.-** លក្ខខណ្ឌនៃការមិនរាងចាល

ការមិនរាងចាលត្រូវបានកើតក្នុងករណីណាមួយដូចតទៅ :

១-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីទៀតនៅក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ។

២-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

៣-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម ដោយត្រូវជាប់ពន្ធនាគារស្មើ ឬលើសពី ៣ (បី) ឆ្នាំ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋ ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

៤-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមដដែលនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

រយៈពេល ១០ (ដប់) ឆ្នាំ និង ៥ (ប្រាំ) ឆ្នាំ ចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសចំពោះបទល្មើសទី ១ ចូលជាស្ថាពរ ។

**មាត្រា ៨៥.-** ការមិនរាងចាលក្នុងបទឧក្រិដ្ឋ

កាលបើបុគ្គលណាមួយ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនេះបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយថ្មីទៀតនៅក្នុងរយៈពេល ១០ (ដប់) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មី ត្រូវទម្ងន់តាមខ្នាតដូចតទៅ :

១-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មីមិនលើសពី ២០ (ម្ភៃ) ឆ្នាំ ទេ អតិបរមានេះ ត្រូវទ្វេឡើង ។

២-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មីនេះមានរយៈពេល ៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៨៦.-** ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទឧក្រិដ្ឋ

កាលបើបុគ្គលណាមួយ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋណាមួយ បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិម ត្រូវទ្វេឡើង ។

តាមអានុភាពនៃការមិនរាងចាល ក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ បទល្មើសនៅតែជាបទមជ្ឈិមដដែល ទោះបីជាមានការបន្ថែមទម្ងន់ទោសយ៉ាងណាក៏ដោយ ។

**មាត្រា ៨៧.-** ការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម

កាលបើបុគ្គលណាមួយ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមដាក់ពន្ធនាគារស្មើ ឬលើសពី ៣ (បី) ឆ្នាំ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ទោសដែលត្រូវផ្តន្ទាទោសលើបទឧក្រិដ្ឋនេះ ត្រូវបន្ថែមទម្ងន់ទៅតាមខ្នាតដូចតទៅ :

១-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋមិនលើសពី ២០ (ម្ភៃ) ឆ្នាំ ទេ អតិបរមានេះ ត្រូវទ្វេឡើង ។

២-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋមានរយៈពេល ៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៨៨.-** ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម

កាលបើបុគ្គលណាមួយ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមណាមួយ បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមដដែលនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមថ្មី ត្រូវទ្វេឡើង ។

តាមអំណាចនៃការមិនរាងចាល ក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ បទល្មើសនៅតែជាបទមជ្ឈិមដដែល ទោះបីជាមានការទម្ងន់ទោសយ៉ាងណាក៏ដោយ ។

**មាត្រា ៨៩.-** បទល្មើសប្រដូច ដើម្បីបង្កើតឱ្យមានការមិនរាងចាល

ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល បទលួច បទរំលោភលើទំនុកចិត្ត និងបទឆបោក ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នាដដែល ។

បទល្មើសទទួលផលចោរកម្ម ត្រូវប្រៀបដូចជាបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិដែលទទួលលាក់បំបាំង ។

បទល្មើសសំអាតប្រាក់កខ្វក់ ត្រូវប្រៀបប្រដូចជាបទល្មើសដែលការសំអាតប្រាក់កខ្វក់នេះបានសម្រេច ។

**មាត្រា ៩០.-** ការមិនរាងចាល និងកិច្ចនៃការចោទប្រកាន់

សភាពមិនរាងចាលអាចត្រូវតុលាការជំនុំជម្រះកត់ត្រាទុក ហើយនិងជាមូលហេតុនៃការបន្ថែមទម្ងន់ទោសដាក់ពន្ធនាគារបាន ប្រសិនបើមានចែងយ៉ាងជាក់លាក់នៅក្នុងលិខិតចោទប្រកាន់ ។

**មាត្រា ៩១.-** ការមិនរាងចាល និងសេចក្តីសម្រេចស្ថាពរ

សេចក្តីសម្រេចត្រូវបានចាត់ទុកថាជាស្ថាពរ កាលណាសេចក្តីសម្រេចនេះមិនអាចមានផ្លូវតវ៉ាបានទៀតឡើយ ។

ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល ត្រូវគិតគូរតែទណ្ឌកម្មដែលស្ថាពរខាងបណ្តឹងអាជ្ញាប៉ុណ្ណោះ ។

**មាត្រា ៩២.-** បទប្បញ្ញត្តិដោយឡែក

សភាពមិនរាងចាលអាចត្រូវកត់ត្រាទុក ទោះបីទោសដែលកើតចេញពីការផ្តន្ទាទោសនោះត្រូវផុតអាជ្ញាយុកាលក៏ដោយ ។

សភាពមិនរាងចាល មិនអាចត្រូវកត់ត្រាទុកទេ បើទោសដែលកើតចេញពីការផ្តន្ទាទោសស្ថាពរនោះ ត្រូវបានលើកលែងដោយអនុលោមតាមមាត្រា ៩០ វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## ស្ថានសម្រាលទោស

**មាត្រា ៩៣.-** និយមន័យនៃស្ថានសម្រាលទោស

កាលណាប្រភេទនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃចារិតម្រូវ តុលាការអាចសម្រេចឱ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស ។

ស្ថានសម្រាលទោសអាចត្រូវផ្តល់ឱ្យទណ្ឌិតបានដែរ ទោះបីជាជននោះត្រូវបានប្រកាសថា ស្ថិតនៅក្នុងភាពមិនរាងចាលក៏ដោយ ។

**មាត្រា ៩៤.-** អានុភាពនៃស្ថានសម្រាលទោស

កាលណាតុលាការផ្តល់ឱ្យជនជាប់ចោទ នូវស្ថានសម្រាលទោសអប្បបរមានៃមូលទោសចំពោះបទឧក្រិដ្ឋ ឬមជ្ឈិម ត្រូវបន្ថយតាមខ្នាតដូចខាងក្រោម :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ អប្បបរមានៃទោស ត្រូវបន្ថយមកត្រឹម ២ (ពីរ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ ហើយតិចជាង ១០ (ដប់) ឆ្នាំ អប្បបរមានៃទោស ត្រូវបន្ថយមកត្រឹម ១ (មួយ) ឆ្នាំ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ ហើយតិចជាង ៥ (ប្រាំ) ឆ្នាំ អប្បបរមានៃទោស ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ ហើយតិចជាង ២ (ពីរ) ឆ្នាំ អប្បបរមានៃទោស ត្រូវបន្ថយមកត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យ ត្រូវបន្ថយមកត្រឹមពាក់កណ្ដាល ។

**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាល

កាលណាបទល្មើសត្រូវបានផ្ដន្ទាទោសដាក់គុកអស់មួយជីវិត ចៅក្រមដែលផ្ដល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ ។

## មាតិកាទី ៣

## របបនៃការប្រកាសទោស

### ជំពូកទី ១

### របបទូទៅ

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើទម្ងន់ទោស និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុក ទៅលើមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ។

**មាត្រា ៩៧.-** ការប្រកាសមូលទោស

នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស :

១-ទោសដាក់ពន្ធនាគារ និងទោសពិន័យត្រួតគ្នា ។

២-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

៣-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បាន

ទេ ។

ការស្តីបន្ទោសជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសការស្តីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស

កាលណាបទល្មើសមួយត្រូវផ្តន្ទាទោស ដោយទោសបន្ថែមមួយ ឬច្រើន ទោសបន្ថែមនេះ ត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) ចេញ ។

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម

តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន នៅក្នុងករណីដូចខាងក្រោម :

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោបន្ថែមមួយ ឬច្រើន តុលាការ នេះមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ ។

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ ។ តុលការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា ។

**មាត្រា ១០២.-** ចិរវេលា និងអំឡុងពេលនៃការងារសហគមន៍

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីចិរវេលានៃ

ការងារ និងរយៈពេលដែលត្រូវបំពេញ ។ រយៈពេលនេះមិនអាចលើសពី ១ (មួយ) ឆ្នាំ ទេ ។

**មាត្រា ១០៣.-** បែបបទនៃការអនុវត្តទោសការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ។

ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។

## ជំពូកទី ២

## ការព្យួរទោសធម្មតា

### ផ្នែកទី ១

### បទប្បញ្ញត្តិរួម

**មាត្រា ១០៤.-** ការប្រកាសការព្យួរទោស

តុលាការអាចបង្គាប់ថា នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្អាកការអនុវត្តនូវមូលទោស ។

**មាត្រា ១០៥.-** របបនៃការព្យួរទោស

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការព្យួរទោស ត្រូវគិតតែអំពីទណ្ឌកម្មជាស្ថាពរខាងបណ្ដឹងអាជ្ញាប៉ុណ្ណោះ ។

### ផ្នែកទី ២

### ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

**មាត្រា ១០៦.-** លក្ខខណ្ឌទាក់ទងនឹងការផ្ដន្ទាទោសពីមុន

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្ដល់ឱ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្ដន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនអំពើល្មើស ។

**មាត្រា ១០៧.-** ទោសអាចនាំឱ្យមានការព្យួរទោស

ការព្យួរទោសធម្មតា ត្រូវអនុវត្តទៅលើទោសដូចតទៅ :

១-ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១០៨.-** ការព្យួរទោសមួយផ្នែក

តុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ថិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ ។

**មាត្រា ១០៩.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់ ។

ទោសទី ១ ត្រូវអនុវត្តដោយមិនអាចស្រួបចូលជាមួយទោសទី ២ បានឡើយ ។

**មាត្រា ១១០.-** ការមិនដកហូត

ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៩ (ការដកហូតការព្យួរទោស) តុលាការអាចសម្រេចថា ទណ្ឌកម្មថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតា ដែលបានសម្រេចពីមុននោះទេ ។ សេចក្តីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុជាពិសេស ។

**មាត្រា ១១១.-** ការទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយគ្មានការផ្តន្ទាទោសថ្មីជាស្ថាពរ

មួយទៀត ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវចាត់ទុកថាជាអសារបង់ ។

កាលណាបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះ ការផ្តន្ទាទោស ត្រូវចាត់ទុកជាអសាបង់ទាំងស្រុង ។

## ផ្នែកទី ៣
## ការចោទប្រកាន់ចំពោះបទលហុ

**មាត្រា ១១២.-** លក្ខខណ្ឌទាក់ទងទៅនឹងការផ្តន្ទាទោសពីមុន

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាស ប្រសិនបើជនជាប់ចោទ មិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយ នៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ មុនបទល្មើសនេះ ។

**មាត្រា ១១៣.-** ទោសអាចនាំឱ្យមានការព្យួរទោស

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោសដូចតទៅនេះ :

១-ទោសដាក់ពន្ធនាគារ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១១៤.-** ការដកហូតនៃការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុ ដោយមានការព្យួរទោសធម្មតាផង រួចកើតមានទ្វេការផ្តន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតាពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវដកចេញដោយពេញច្បាប់ ។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានស្រួបជាមួយទោសទី ២ ឡើយ ។

**មាត្រា ១១៥.-** ការមិនដកហូត

ជាបដិប្បញ្ញត្តិនៃមាត្រា ១១៤ (ការដកហូតនៃការព្យួរទោស) តុលាការ

អាចសម្រេចថាការផ្តន្ទាទោសថ្មីមិនអាចនាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតានេះ ដែលសម្រេចពីមុននោះទេ ។ សេចក្តីសម្រេចនេះ ត្រូវតែមានសំអាងហេតុជាពិសេស ។

**មាត្រា ១១៦.-** ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុ ដែលមានការព្យួរទោសធម្មតា គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការផ្តន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## ជំពូកទី ៣
## ការព្យួរទោសសាកល្បង

**មាត្រា ១១៧.-** និយមន័យ និងលក្ខខណ្ឌនៃការព្យួរទោសសាកល្បង

តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចជាប់ពន្ធនាគារដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។

ការព្យួរទោសសាកល្បង មានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង ។

**មាត្រា ១១៨.-** រយៈពេលនៃការសាកល្បង

តុលាការកំណត់ពេលវេលានៃការសាកល្បង ។ រយៈពេលនេះមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ ទេ ។

**មាត្រា ១១៩.-** វិធានការត្រួតពិនិត្យ

វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិត មានដូចតទៅ :

១-ទណ្ឌិត ត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញានេះបានប្រគល់អំណាចឱ្យ ។

២-ទណ្ឌិត ត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជាអាជ្ញាបានប្រគល់អំណាចឱ្យ ។

៣-ទណ្ឌិត ត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យនូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ ។

៤-ទណ្ឌិត ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្ដូរអាសយដ្ឋានរបស់ខ្លួន ។

៥-ទណ្ឌិត ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្ដូរមុខរបររបស់ខ្លួន ។

៦-ទណ្ឌិត ត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស ។

**មាត្រា ១២០.-** កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត

កាតព្វកិច្ចដោយឡែកដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅ :

១-បំពេញសកម្មភាពខាងវិជ្ជាជីវៈ ។

២-ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

៣-រស់នៅក្នុងកន្លែងណាមួយជាកំណត់ ។

៤-ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល ។

៥-បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ ។

៦-ធ្វើការជួសជុលការខូចខាតដែលបណ្ដាលមកអំពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន ។

៧-បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្ដន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន ។

៨-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស ក្នុងករណីនេះតុលាការ បញ្ជាក់អំពីសកម្មភាពដែលហាមឃាត់ ។

៩-មិនត្រូវមានមុខនៅទីកន្លែងខ្លះ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់ ។

១០-មិនត្រូវសេពគប់បនល្បែង ។

១១-មិនត្រូវសេពគប់តៀមភេសជ្ជៈស្រវឹង ។

១២-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី ជនសមគំនិត ឬជនរងគ្រោះនៃបទល្មើស ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ ។

១៣-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត ។

**មាត្រា ១២១.-** ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

នៅគ្រប់ពេលវេលា តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន ។

តុលាការ ត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២២.-** ការដកហូតការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងអាចត្រូវដកហូតដោយតុលាការ នៅក្នុងករណីដូចខាងក្រោមនេះ :

១-ប្រសិនបើក្នុងចិរវេលាសាកល្បងទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ ។

២-ប្រសិនបើក្នុងចិរវេលាសាកល្បងទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត ។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក ។ នៅក្នុងករណីនេះ ទោសត្រូវយកមកអនុវត្តទាំងមូល ឬមួយផ្នែក ។

តុលាការ ត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២៣.-** ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់

ការផ្តន្ទាទោស ត្រូវចាត់ទុកជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលសាកល្បង គ្មានពាក្យសុំដកហូតដែលមានសេចក្តីសម្រេចដកហូតទេ ។

## ជំពូកទី ៤

## ការផ្អាកនៃការប្រកាសទោស

**មាត្រា ១២៤.-** លក្ខខណ្ឌនៃការផ្អាកនៃការប្រកាសទោស

ក្នុងករណីចោទប្រកាន់ពីបទមជ្ឈិម តុលាការក្រោយពីបានប្រកាសថាជនជាប់ចោទមានពិរុទ្ធ អាចផ្អាកការប្រកាសទោស ប្រសិនបើលក្ខខណ្ឌដូចតទៅនេះត្រូវបានបំពេញ :

១-ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈ ដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់ ។

២-ជនជាប់ចោទមានការធានាក្នុងការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គម ។

៣-ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត ។

**មាត្រា ១២៥.-** សេចក្តីសម្រេចនៃការផ្អាក

ការផ្អាកអាចត្រូវបង្គាប់បានលុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ ។

តុលាការកំណត់នៅក្នុងសាលក្រម ឬសាលដីកានូវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស ។

សេចក្តីសម្រេចអំពីទោសត្រូវតែធ្វើឡើងយ៉ាងច្រើនបំផុត ១ (មួយ) ឆ្នាំក្រោយសេចក្តីសម្រេចផ្អាក ។

**មាត្រា ១២៦.-** សវនាការពិនិត្យរឿងដែលបង្អង់

នៅពេលសវនាការពិនិត្យរឿងដែលបង្អង់នេះ តុលាការសម្រេចអំពីទោស ។

## ជំពូកទី ៥
## ពាក់កណ្ដាលសេរីភាព

**មាត្រា ១២៧.-** លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ តុលាការអាចសម្រេចថា ទោសត្រូវអនុវត្តក្រោមរបបពាក់កណ្ដាលសេរីភាព ដើម្បីអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្ដុះបណ្ដាល ឬការពិនិត្យព្យាបាលជម្ងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ ។

**មាត្រា ១២៨.-** បែបបទនៃរបបពាក់កណ្ដាលសេរីភាព

ទណ្ឌិតដែលស្ថិតនៅក្រោមរបបពាក់កណ្ដាលសេរីភាព ត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារ ក្នុងរយៈពេលជាកំណត់ ។

តុលាការកំណត់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបានអនុញ្ញាតឱ្យអវត្តមាននៅក្នុងពន្ធនាគារ ។

**មាត្រា ១២៩.-** ការគិតបញ្ចូលរយៈពេលនៃរបបពាក់កណ្ដាលសេរីភាពពីទោស

រយៈពេលនៃពាក់កណ្ដាលសេរីភាព ត្រូវគិតបញ្ចូលទៅលើថិរវេលានៃទោសដែលកំពុងអនុវត្ត ។

**មាត្រា ១៣០.-** ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាលសេរីភាព

នៅគ្រប់ពេល តុលាការអាចរៀបចំរយៈពេលនៃពាក់កណ្ដាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្ដាលសេរីភាព តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការ ត្រូវទទួលដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣១.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃពាក់កណ្ដាលសេរីភាព ។

# ជំពូកទី ៦
# ការបែងចែកទោសជាប្រភាគ

**មាត្រា ១៣២.-** លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ ។

តុលាការអាចសម្រេចថា ទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរ មានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម ។

**មាត្រា ១៣៣.-** បែបបទនៃការបែងចែកទោសជាប្រភាគ

ប្រភាគនៃទោសនីមួយៗ មិនត្រូវតិចជាង ១ (មួយ) ខែ ទេ ។ ចិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី ២ (ពីរ) ឆ្នាំ ទេ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស ។

តុលាការ កំណត់ក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ ។

**មាត្រា ១៣៤.-** ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ

នៅគ្រប់ពេលវេលា តុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលរបបនៃការបែងចែកទោសជាប្រភាគ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការ ទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣៥.-** លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស ។

## មាតិកាទី ៤
## វិធានអនុវត្តនៅក្នុងករណីបទល្មើសត្រួតគ្នា
## ជំពូកទី ១
## វិធានទូទៅ

**មាត្រា ១៣៦.-** បទល្មើសត្រួតគ្នា

មានបទល្មើសត្រួតគ្នាកើតឡើង កាលបើបទល្មើសមួយត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ មុនពេលដែលបុគ្គលនេះត្រូវជំនុំជម្រះជាស្ថាពរចំពោះបទល្មើសមួយផ្សេងទៀត ។

**មាត្រា ១៣៧.-** ការចោទប្រកាន់តែមួយ

កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗ អាចត្រូវប្រកាសឡើង ។ ប៉ុន្តែកាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។

ទោសនីមួយៗ ដែលប្រកាសត្រូវចាត់ទុកថាជាទោសរួម ចំពោះបទល្មើសដែលត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ អនុវត្តទៅលើបទល្មើសនីមួយៗ ។

**មាត្រា ១៣៨.-** ការចោទប្រកាន់ដាច់ពីគ្នា

នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវប្រកាស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។

ប៉ុន្តែតុលាការចុងក្រោយដែលត្រូវសម្រេច អាចប្រកាសឱ្យអនុវត្តទោសស្រូបបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា ។

ដើម្បីអនុវត្តមាត្រានេះ នៅក្នុងករណីទោសដែលច្បាប់កំណត់ជាទោសដាក់ពន្ធនាគារមួយជីវិត អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់

ពន្ធនាគារត្រឹម ៣០ (សាមសិប) ឆ្នាំ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ ។

ការលុបទោសទាំងមូល ឬមួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើសដែលត្រួតគ្នានេះ មិនអាចជាឧបសគ្គដល់ការអនុវត្តទោសនៃប្រភេទដូចគ្នាដែលគ្មានការលុបទោសទេ ។

## ជំពូកទី ២
## វិធានដោយឡែក

**មាត្រា ១៣៩.-** ឧប្បត្តិកនៃការលើកលែងទោស និងការបន្ធូរបន្ថយទោសលើការស្រូបទោស

កាលបើទោស បានជាកម្មវត្ថុនៃវិធានការលើកលែងទោស និងបន្ធូរបន្ថយទោសដូចមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ត្រូវតែគិតគូរអំពីទោសដែលជាលទ្ធផលនៃការលើកលែងទោស និងបន្ធូរបន្ថយទោស ដើម្បីអនុវត្តវិធានស្តីពីការស្រូបបញ្ចូលគ្នានៃទោស ។

ចិរវេលានៃការបន្ធូរបន្ថយទោស ត្រូវរាប់បញ្ចូលទៅលើចិរវេលានៃទោសទៅថ្ងៃមុខ ជាយថាហេតុ ក្រោយការស្រូបទោស ។

**មាត្រា ១៤០.-** ការបូកបញ្ចូលគ្នានៃទោសពិន័យ

ជាបដិប្បញ្ញត្តិទៅលើបទប្បញ្ញត្តិមុននេះ ការពិន័យដែលបានប្រកាសឡើងចំពោះ បទលហុច្រើននោះ ត្រូវត្រួតគ្នារវាងគ្នានឹងគ្នា ហើយត្រូវត្រួតគ្នាផងដែរជាមួយទោសពិន័យ ដែលប្រកាសឡើងចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

**មាត្រា ១៤១.-** ការមិនស្រូបចូលនៃទោសដែលត្រូវបានប្រកាសចំពោះករណីរត់ចេញពីពន្ធនាគារ

ក្នុងករណីផ្តន្ទាទោសពីបទរត់ចេញពីពន្ធនាគារ ទោសដែលប្រកាសពីបទនេះត្រូវត្រួតជាមួយនឹងទោសដែលប្រកាសឡើងចំពោះបទល្មើសដែលនាំឱ្យមានការឃុំខ្លួនជននោះ ដោយមិនអាចមានការស្រូបចូលគ្នា ។

# មាតិកាទី ៥
# មូលហេតុនានាដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស
## ជំពូកទី ១
## អាជ្ញាយុកាលនៃទោស

**មាត្រា ១៤២.-** អានុភាពនៃអាជ្ញាយុកាល

នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ ។

**មាត្រា ១៤៣.-** ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋមួយចំនួន

ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាលទេ ។

ក្រៅពីបទល្មើសខាងលើ ច្បាប់ពិសេសអាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងទៀតបាន ។

**មាត្រា ១៤៤.-** កំឡុងពេលនៃអាជ្ញាយុកាលបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ

ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ ។

ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ ។

ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ ។

**មាត្រា ១៤៥.-** ចំណុចចាប់ផ្ដើមនៃចិរវេលា

ចិរវេលា ២០ (ម្ភៃ) ឆ្នាំ ៥ (ប្រាំ) ឆ្នាំ និង ១ (មួយ) ឆ្នាំ ខាងលើដែលមានចែងនៅក្នុងមាត្រា ១៤៤ (កំឡុងពេលនៃអាជ្ញាយុកាល : បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ) ចាប់គិតពីថ្ងៃដែលសេចក្ដីសម្រេចផ្ដន្ទាទោស បានក្លាយទៅជាស្ថាពរ ។

ក្រៅពីបទល្មើសខាងលើ ច្បាប់ពិសេសអាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងទៀតបាន ។

**មាត្រា ១៤៦.-** អាជ្ញាយុកាលនៃកាតព្វកិច្ចរដ្ឋប្បវេណីដែលកើតចេញពីសេចក្ដីសម្រេចព្រហ្មទណ្ឌ

កាតព្វកិច្ចដែលមានប្រភេទជារដ្ឋប្បវេណី ដែលមានប្រភពចេញមកពីសេចក្ដីសម្រេចព្រហ្មទណ្ឌដែលក្លាយជាស្ថាពរ ផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី ។

## ជំពូកទី ២

## ការអនុគ្រោះទោស

**មាត្រា ១៤៧.-** និយមន័យ និងអានុភាពនៃការអនុគ្រោះទោស

ការអនុគ្រោះទោសដូចដែលមានចែងនៅក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញលើកលែងឱ្យទណ្ឌិតរួចផុតពីការអនុវត្តទោស ។

**មាត្រា ១៤៨.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការអនុគ្រោះទោស

លើកលែងតែបទប្បញ្ញត្តិផ្ទុយនៃព្រះរាជក្រឹត្យ ការអនុគ្រោះទោសមិនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងជួសជុលការខូចខាតទេ ។

## ជំពូកទី ៣

## ការលើកលែងទោសជាទូទៅ

**មាត្រា ១៤៩.-** និយមន័យ និងអានុភាពនៃការលើកលែងទោស

ការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ នៃរដ្ឋធម្មនុញ្ញលប់បំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់លើកលែងទោស ។

ទោសមិនអាចអនុវត្តទេ ។

ទោសដែលកំពុងអនុវត្ត ត្រូវបានបញ្ចប់ ជាយថាហេតុ ។

ប៉ុន្តែ ចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្ដី ដែលបានបង់រួចហើយ មិនអាចទារសំណងពីរដ្ឋបានទេ ។

**មាត្រា ១៥០.-** ការលើកលែងទោស និងការដកការព្យួរទោស

កាលបើការព្យួរទោសពីមុន ត្រូវបានដកហូតដោយអានុភាពនៃការផ្តន្ទាទោសខាងក្រោយ ការលើកលែងទោសជាទូទៅចំពោះទោសខាងក្រោយនេះ បង្កើតឡើងវិញនូវការព្យួរទោសដែលមានពីមុន ។

**មាត្រា ១៥១.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការលើកលែងទោស

លើកលែងតែបទប្បញ្ញត្តិផ្ទុយនៃច្បាប់ ការលើកលែងទោសជាទូទៅ មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងការជួសជុលនៃការខូចខាតឡើយ ។

## ជំពូកទី ៤
## ការរៀបចំទោស និងការលុបបំបាត់នូវទោសបន្ថែមខ្លះៗ

**មាត្រា ១៥២.-** លក្ខខណ្ឌនៃការកែប្រែទោសបន្ថែមខ្លះៗ

ក្នុងករណីផ្តន្ទាទោសបន្ថែមដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦, ៧, ១៤, ១៥ និង ១៦ នៃមាត្រា ៥៩ (ប្រភេទនៃទោសបន្ថែម) តុលាការអាចបង្គាប់ឱ្យធ្វើការរៀបចំកែប្រែ ឬការលុបបំបាត់ចោលទោសមួយ ឬច្រើន បើសិនលក្ខខណ្ឌដូចតទៅនេះ បានត្រូវបំពេញ :

១-ភាពច្របូកច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ឈប់ ។

២-ការអន្តរាយ ត្រូវបានជួសជុល ។

៣-សេចក្តីសម្រេចរៀបចំកែប្រែ ឬលុបចោល មានលក្ខណៈអនុគ្រោះឱ្យធ្វើការបញ្ជូលជនល្មើសទៅរស់នៅក្នុងសង្គមវិញ ។

តុលាការទទួលពាក្យប្តឹងពីអយ្យការ តាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមពាក្យប្តឹងរបស់ទណ្ឌិត ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយ

ពីបានស្តាប់យោបល់របស់តំណាងអយ្យការ ទណ្ឌិត និងជាយថាហេតុ មេធាវីរបស់ជននេះ ។

**មាត្រា ១៥៣.-** ការធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ ឬខ្លះៗ

ក្នុងករណីដកសិទ្ធិពលរដ្ឋ តុលាការអាចធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ ដែលរៀបរាប់នៅមាត្រា ៦១ (សិទ្ធិជាពលរដ្ឋដែលអាចដកបាន) ឬក៏សិទ្ធិខ្លះក្នុងចំណោមសិទ្ធិទាំងនេះ ។

**មាត្រា ១៥៤.-** ការរៀបចំកែប្រែ ឬការលុបចោលនូវការហាមឃាត់

តុលាការអាចរៀបចំកែប្រែ ឬលុបចោលនូវ :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ឬសកម្មភាពសង្គម ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ។

**មាត្រា ១៥៥.-** ការប្រគល់ឱ្យវិញនូវលិខិតបើកបរ

ក្នុងករណីព្យួរលិខិតបើកបរ តុលាការអាចបង្គាប់ឱ្យប្រគល់លិខិតបើកបរនេះទៅម្ចាស់វិញ ។

**មាត្រា ១៥៦.-** ការកែប្រែវិធានការនៃការហាមឃាត់ការស្នាក់នៅ

ក្នុងករណីផ្តន្ទាទោសហាមឃាត់ការស្នាក់អាស្រ័យនៅ តុលាការអាចកែប្រែបែបបទនៃវិធានការតាមដាន ។

ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យស្នាក់អាស្រ័យនៅបណ្តោះអាសន្ន ដែលមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ នៅក្នុងទីកន្លែងដែលហាមឃាត់ ។ ព្រះរាជអាជ្ញា ជូនព័ត៌មានអំពីកិច្ចនេះដល់តុលាការ ។

សេចក្តីសម្រេចរបស់តុលាការ និងព្រះរាជអាជ្ញា ត្រូវបានជូនដំណឹងដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**មាត្រា ១៥៧.-** ការកែប្រែការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

តុលាការ អាចលុបចោលការហាមឃាត់ ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ តុលាការអាចគ្រោងទុកនូវលក្ខខណ្ឌខ្លះៗ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ។

**មាត្រា ១៥៨.-** ការកែប្រែការហាមឃាត់ការចូលមកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

តុលាការ អាចលុបចោលការហាមឃាត់ចំពោះការស្នាក់អាស្រ័យ និងចំពោះការចូលក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតបរទេស ។

ប៉ុន្តែ ជាបឋម ព្រះរាជអាជ្ញាត្រូវតែទទួលយោបល់ពីក្រសួងការបរទេស និងជូនដំណឹងនៃយោបល់នេះទៅតុលាការ ។

យោបល់នេះមិនបង្ខំឱ្យតុលាការត្រូវតែអនុវត្តតាមទេ ។

**មាត្រា ១៥៩.-** ការកែប្រែការបណ្តេញចេញ ការបិទ ការហាមឃាត់ការធ្វើអាជីវកម្ម

តុលាការអាចរៀបចំកែប្រែទោស ឬបញ្ចប់នូវទោសដូចខាងក្រោមនេះ :

១-ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ ។

២-ការបិទគ្រឹះស្ថាន ។

៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

# មាតិកាទី ៦
# ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុលើសពី ១៤ (ដប់បួន) ឆ្នាំ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះតែប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ និងចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។ ប៉ុន្តែថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្ត ការមិនរាងចាលចំពោះអនីតិជន

បទប្បញ្ញត្តិស្តីអំពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាល

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល ។

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល ។

៤-ជួសជុលការអន្តរាយដែលបណ្ដាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្ដន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ។

## ជំពូកទី ២

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាកន្លែងសម្រាប់អប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ។

# មាតិកាទី ៧
# ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦៧.-** ទោសដែលត្រូវរងដោយនីតិបុគ្គល

ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គលមានដូចតទៅ :

១-ទោសពិន័យក្នុងឋានៈជាមូលទោស ។

២-ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) ។

## ជំពូកទី ២
## ទោសបន្ថែម

**មាត្រា ១៦៨.-** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅ :

១-ការរំលាយចោល ។

២-ការដាក់ឱ្យនៅក្រោមការតាមដានរបស់តុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន ។

៤-ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលបញ្ជាក់ដោយធនាគារណាមួយ ។

៧-ការហាមចំពោះការប្រើប័ណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

១១-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាទីដៅនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសនូវឧបភោគភ័ណ្ឌ សម្ភារៈ និងចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ឬផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន ។

**មាត្រា ១៦៩.-** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់ ។

**មាត្រា ១៧០.-** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល

សេចក្តីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការបញ្ជូននីតិបុគ្គលនេះទៅមុខតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី ។

**មាត្រា ១៧១.-** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ សេចក្តីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។ ជារៀងរាល់ ៦ (ប្រាំមួយ) ខែ យ៉ាងតិច អាណត្តិគាហកតុលាការធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន ។

ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្តឹងទៅតុលាការដែលបានប្រកាសឱ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ ។

តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់យោបល់របស់តំណាងអយ្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ ។

**មាត្រា ១៧២.-** ការហាមឃាត់ចំពោះការធ្វើសកម្មភាព

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬជាបណ្ដោះអាសន្ន សម្រាប់ចិរវេលា ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់ ។

**មាត្រា ១៧៣.-** ការបណ្ដេញចេញពីអាបណសាធារណៈ

ទោសបណ្ដេញចេញពីអាបណសាធារណៈ នាំឱ្យមានការហាមចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងគ្រប់អាបណសញ្ញាសាធារណៈដែលស្នើឡើងដោយ :

១-រដ្ឋ ។

២-សមូហភាពដែនដីវិមជ្ឈការ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទាន ឬត្រួតពិនិត្យដោយរដ្ឋ ឬដោយសមូហភាពដែនដីវិមជ្ឈការ ។

ទោសនេះ អាចជាស្ថាពរ ឬជាបណ្ដោះអាសន្ន សម្រាប់ចិរវេលាមួយមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

**មាត្រា ១៧៤.-** ការហាមចំពោះការធ្វើអំពាវនាវសាធារណៈឱ្យធ្វើការសន្សំសំចៃ

ការហាមចំពោះការធ្វើការអំពាវនាវជាសាធារណៈ ឱ្យធ្វើការដាក់ប្រាក់សន្សំ អាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ការហាមនេះ នាំឱ្យមានការហាមដល់នីតិបុគ្គលចំពោះការធ្វើអំពាវនាវ ដើម្បីឱ្យដាក់ឧបករណ៍អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានឥណទាន គ្រឹះស្ថានហិរញ្ញវត្ថុ ឬក្រុមហ៊ុន លក់ទិញភាគហ៊ុន ។

ការហាមនេះ នាំឱ្យមានការហាមចំពោះការធ្វើការផ្សព្វផ្សាយជាសាធារណៈដែរ ។

**មាត្រា ១៧៥.-** ការហាមចំពោះការចេញមូលប្បទានប័ត្រ

ការហាមចំពោះការចេញឧបករណ៍អាចជួញដូរបានអាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ចំពោះការហាមប្រើប្រាស់ប័ណ្ណទូទាត់ ក៏ដូចគ្នាដែរ ។

**មាត្រា ១៧៦.-** ការបិទគ្រឹះស្ថាន

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះនូវសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ ។

ទោសនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

**មាត្រា ១៧៧.-** ការហាមចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន

ការហាមចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានមួយដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬជាបណ្តោះអាសន្នក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ១៧៨.-** ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស

កាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុដែលរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែបទប្បញ្ញត្តិដោយឡែកបានចែងអំពីការប្រគល់ផ្សេងទៀត ។

រដ្ឋអាចលក់ ឬបំផ្លាញចោលវត្ថុដែលរឹបអូសនៅក្នុងទម្រង់ដែលមានចែងសម្រាប់ការលក់ទ្រព្យសម្បត្តិរបស់រដ្ឋ ។ ច្បាប់អាចចែងអំពីការបំផ្លាញចោលនូវវត្ថុខ្លះផងដែរ ។

កាលបើវត្ថុដែលរឹបអូសមិនត្រូវបានចាប់ទេ ហើយនិងមិនអាចប្រគល់ឱ្យទេនោះ ទណ្ឌិតត្រូវចេញសងតម្លៃនៃវត្ថុរឹបអូសនេះ ។ តម្លៃនេះត្រូវបានកំណត់ដោយ

តុលាការ ។ វិធានការដើម្បីប្រមូលប្រាក់នេះ ត្រូវធ្វើឡើងដូចក្នុងរឿងដាក់ពន្ធនាគារបង្ខំលើរូបកាយដែរ ។

**មាត្រា ១៧៩.-** ការរឹបអូស និងសិទ្ធិតតិយជន

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចខាងក្រោមនេះ :

១-ឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

២-វត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៣-ផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

៤-ឧបភោគភ័ណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើតឡើង ។

ក៏ប៉ុន្តែ ការរឹបអូសមិនអាចត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

**មាត្រា ១៨០.-** ការបិទផ្សាយសេចក្ដីសម្រេច

ទោសបិទផ្សាយសេចក្ដីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលប្រាប់ដោយតុលាការ និងសម្រាប់រយៈពេលមួយដែលកំណត់ឡើងដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ។ ការបិទផ្សាយ អាចទាំងស្រុងតាមសម្រង់ ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយនៃការបិទផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្ដន្ទាទោស ។

ក្នុងករណីដែលដកបំបាត់ចេញ លាក់បំបាំង ឬហែកចោលប័ណ្ណបិទផ្សាយនោះ ត្រូវធ្វើការបិទផ្សាយជាថ្មីម្ដងទៀត ។ សោហ៊ុយនៃការបិទផ្សាយនេះ ត្រូវចេញដោយជនល្មើស ដែលជាអ្នកដកបំបាត់ចោល លាក់បំបាំង ឬហែកចោល ។

**មាត្រា ១៨១.-** ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍

ទោសផ្សាយចេញសេចក្ដីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ឡើងដោយតុលាការ ។ ការផ្សាយនេះ

មិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ។ ការផ្សាយនេះ អាចទាំងស្រុងតាមសម្រង់ ឬតាមនិទ្ទេស ។ សោហ៊ុយនៃការផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

**មាត្រា ១៨២.-** ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងរូបវន្តបុគ្គល និងនីតិបុគ្គល

បទប្បញ្ញត្តិនៃគន្ថីទី ១ និងគន្ថីទី ២ នៃភាគទី ១ នៃក្រមនេះ ដែលទាក់ទងនឹងរូបវន្តបុគ្គល ត្រូវអនុវត្តទៅលើនីតិបុគ្គលក្នុងកម្រិតដែលបទប្បញ្ញត្តិនេះ មិនផ្ទុយជាមួយនឹងបទប្បញ្ញត្តិនៃមាតិកានេះ ។

# ភាគទី ២
# បទល្មើសប្រឆាំងនឹងបុគ្គល
## គន្ថីទី ១
## បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម
### មាតិកាទី ១
### បទប្រល័យពូជសាសន៍
### ជំពូកតោល
### បទប្រល័យពូជសាសន៍

**មាត្រា ១៨៣.-** បទប្រល័យពូជសាសន៍

បទប្រល័យពូជសាសន៍ គឺជាអំពើណាមួយក្នុងចំណោមនៃអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា :

១-ឃាតកម្មលើសមាជិកនៃក្រុម ។

២-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬសតិបញ្ញារបស់សមាជិកនៃក្រុម ។

៣-ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខណ្ឌ ដែលនាំឱ្យវិនាសអន្តរាយទាំងស្រុង ឬមួយផ្នែកនៃក្រុម ។

៤-វិធានការសំដៅរារាំងកំណើតទារកនៅក្នុងក្រុម ។

៥-ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។

**មាត្រា ១៨៤.-** ទោសដែលត្រូវអនុវត្ត

បទប្រល័យពូជសាសន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ១៨៥.-** អំពើត្រៀមរៀបចំក្នុងបទប្រល័យពូជសាសន៍

ការចូលរួមក្នុងក្រុមណាមួយដែលបង្កើតឡើង ឬចូលរួមក្នុងសន្និដ្ឋិភាពដែលធ្វើឡើង ដើម្បីរៀបចំការប្រល័យពូជសាសន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារក្នុងចន្លោះ

ពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

ការរៀបចំ ត្រូវមានលក្ខណៈសំគាល់ដោយអំពើជាក់ស្តែងមួយ ឬច្រើន ។

**មាត្រា ១៨៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាច ត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមចំពោះការប្រកបវិជ្ជាជីវៈ កាលបើអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្ត ឡើងនៅក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេស ចំពោះការចូលមក ឬស្នាក់អាស្រ័យ នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ១៨៧.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌនៃនីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តក្នុងមាត្រា ១៨៣ (ធាតុផ្សំនៃបទប្រល័យពូជសាសន៍) និងមាត្រា ១៨៥ (អំពើត្រៀមរៀបចំក្នុងបទប្រល័យពូជសាសន៍) ។

នីតិបុគ្គល ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន) រៀល ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្ដេញចេញពីអាបណសញ្ញាសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្ដេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) ។

៦-ការបិទផ្សាយនូវសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្ដីសម្រេច) ។

៧-ចុះផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស នៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## មាតិកាទី ២

## បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

## ជំពូកទោល

## បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

**មាត្រា ១៨៨.-** បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាបទឧក្រិដ្ឋដែលអំពើណាមួយដែលចែងខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ ឬជាប្រព័ន្ធ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល :

១-ឃាតកម្ម ។

២-ការសម្លាប់រង្គាល ។

៣-ការធ្វើឱ្យទៅជាទាសកម្ម ។

៤-ការនិរទេស ឬជម្លៀសប្រជាជនដោយបង្ខំ ។

៥-ការដាក់ពន្ធនាគារ ឬគ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ។

៦-ការធ្វើទារុណកម្ម ។

៧-ការចាប់បង្ខំសេពសន្ថវៈ ការធ្វើទាសកម្មខាងផ្លូវភេទ ពេស្យាចារដោយបង្ខំ ការធ្វើឱ្យមានគភ៌ដោយបង្ខំ ការធ្វើឱ្យគ្មានកូនដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហិង្សាខាងផ្លូវភេទ ដែលមានទម្ងន់ដូចគ្នា ។

៨-ការធ្វើទុកបុកម្នេញលើក្រុម ឬសមូហភាពដោយមូលហេតុនយោបាយ ពូជអម្បូរ ជនជាតិ ជាតិពន្ធុ វប្បធម៌ សាសនា ឬភេទ ។

៩-ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ។

១០-ការប្រកាន់ពូជសាសន៍ ។

១១-គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ ។

**មាត្រា ១៨៩.-** ទោសដែលត្រូវទទួល

បទក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ១៩០.-** អំពើត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

ការចូលរួមក្នុងក្រុមដែលបង្កើតឡើង ឬសន្ទិដ្ឋិភាពដែលធ្វើឡើងដើម្បីរៀបចំអំពើឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

ការត្រៀមរៀបចំ ត្រូវមានលក្ខណៈសំគាល់ដោយអំពើជាក់ស្តែងមួយ ឬច្រើន ។

**មាត្រា ១៩១.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមចំពោះការប្រកបវិជ្ជាជីវៈ កាលបើអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងនៅក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ១៩២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌនៃនីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តក្នុងមាត្រា ១៨៨ (ធាតុផ្សំនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ) និងមាត្រា ១៩០ (អំពើត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ) ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន) រៀល ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) ។

៦-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

៧-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

# មាតិកាទី ៣

# បទឧក្រិដ្ឋសង្គ្រាម

## ជំពូកតែមួយ

## បទឧក្រិដ្ឋសង្គ្រាម

**មាត្រា ១៩៣.-** បទឧក្រិដ្ឋសង្គ្រាម

បទឧក្រិដ្ឋសង្គ្រាម គឺជាអំពើណាមួយដូចមានចែងខាងក្រោមនេះ កាលបើអំពើនោះត្រូវបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៨ :

១-ឃាតកម្ម ។

២-ទារុណកម្ម ឬគ្រប់អំពើអមនុស្សធម៌ រួមបញ្ចូលទាំងការពិសោធន៍ជីវសាស្ត្រ ។

៣-អំពើបង្កដោយចេតនា នូវការឈឺចាប់ ឬដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ឬរណភាពបុគ្គល ឬសុខភាព ។

៤-ការបំផ្លាញ ឬការកេងយកនូវទ្រព្យសម្បត្តិ ដោយគ្មានហេតុផលត្រឹមត្រូវខាងយោធា និងក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់ និងតាមទំនើងចិត្ត ។

៥-អំពើបង្ខំឈ្លើយសឹក ឬជនស៊ីវិល ឱ្យបម្រើក្នុងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋដែលជាសត្រូវ ។

៦-អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬជនស៊ីវិល ក្នុងការទទួលការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលំអៀង ។

៧-ការជម្លៀស ការបញ្ជូន ឬការឃុំឃាំងដោយខុសច្បាប់ ។

៨-ការចាប់ជាចំណាប់ខ្មាំង ។

**មាត្រា ១៩៤.-** បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត

អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺជាបទឧក្រិដ្ឋសង្គ្រាមដែរ កាលបើអំពើនោះ ត្រូវបានប្រព្រឹត្តក្នុងឱកាសជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ឬមិនមែនអន្តរជាតិ :

១-ការប្រើប្រាស់អាវុធដែលមានជាតិពុល ឬអាវុធដែលស្ថាបនាឡើងដើម្បីបង្កការឈឺចាប់ឥតប្រយោជន៍ ។

២-អំពើវាយប្រហារ ឬទម្លាក់គ្រាប់បែកដោយចេតនា តាមមធ្យោបាយណាក៏ដោយទៅលើទីក្រុង ភូមិ កន្លែងរស់នៅ ឬអាគារដែលមិនមានការការពារ និងដែលមិនមែនជាកម្មវត្ថុខាងយោធា ។

៣-អំពើវាយប្រហារដោយចេតនាទៅលើមនុស្ស ឬសម្ភារៈដែលប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃបេសកកម្មមនុស្សធម៌ ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ។

៤-អំពើបង្កគ្រោះទុរ្ភិក្សដោយចេតនា ដល់ប្រជាជនស៊ីវិល ដោយដកហូតនូវទ្រព្យសម្បត្តិចាំបាច់សម្រាប់បន្តការរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនេះ ។

៥-អំពើប្រើប្រាស់ជនស៊ីវិល ដើម្បីជៀសវាងនូវប្រតិបត្តិការយោធា ទៅលើអាគារខ្លះ តំបន់ខ្លះនៃដែនដី ឬកងកម្លាំងយោធាខ្លះ ។

៦-អំពើបំផ្លាញ ឬធ្វើឱ្យខូចខាត ដោយចេតនា នូវអាគារសម្រាប់សាសនា សប្បុរសធម៌ អប់រំ សិល្បៈ និងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈ ឬស្នាដៃដែលមានលក្ខណៈវិទ្យាសាស្ត្រ ។

៧-អំពើបង្កដល់បរិស្ថានធម្មជាតិ នូវការខូចខាតដ៏ធំ យូរអង្វែង និងធ្ងន់ធ្ងរ ដែលមានលក្ខណៈហួសហេតុយ៉ាងជាក់ស្តែង បើប្រៀបទៅនឹងផលប្រយោជន៍ពិតប្រាកដ និងផ្ទាល់ ខាងផ្នែកយោធាដែលសង្ឃឹមទុក ។

៨-ការលួចប្លន់នូវសម្បត្តិសាធារណៈ ឬឯកជន ។

**មាត្រា ១៩៥.-** ទោសដែលត្រូវអនុវត្ត

បទក្រិដ្ឋសង្គ្រាម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ១៩៦.-** អំពើត្រៀមរៀបចំក្នុងបទឧក្រិដ្ឋសង្គ្រាម

ការចូលរួមក្នុងក្រុមដែលបង្កើតឡើង ឬសន្និដ្ឋភាពដែលធ្វើឡើងដើម្បីរៀបចំអំពើឧក្រិដ្ឋសង្គ្រាម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

កាត្រៀមរៀបចំ ត្រូវមានលក្ខណៈសំគាល់ដោយអំពើជាក់ស្តែងមួយ ឬច្រើន ។

**មាត្រា ១៩៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមចំពោះការប្រកបវិជ្ជាជីវៈ កាលបើអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងនៅក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

### **មាត្រា ១៩៨.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌនៃនីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តក្នុងមាត្រា ១៩៣ (ធាតុផ្សំនៃបទឧក្រិដ្ឋសង្គ្រាម) មាត្រា ១៩៤ (បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត) និងមាត្រា ១៩៦ (អំពើត្រៀមរៀបចំក្នុងបទឧក្រិដ្ឋសង្គ្រាម) ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន) រៀល ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្ដេញចេញពីអាបណសញ្ញាសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្ដេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) ។

៦-ការបិទផ្សាយនូវសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្ដីសម្រេច) ។

៧-ចុះផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស នៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

# គន្ថីទី ២
# ការប៉ះពាល់ជីវិតមនុស្ស
## មាតិកាទី ១
## ការប៉ះពាល់ជីវិតមនុស្ស
### ជំពូកទី ១
### ការប៉ះពាល់ដោយចេតនាដល់ជីវិតមនុស្ស

**មាត្រា ១៩៩.–** ឃាតកម្ម

អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬមិនប្រើអាវុធ ដោយគ្មានស្ថានទម្ងន់ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០ (ឃាតកម្មគិតទុកជាមុន) ដល់មាត្រា ២០៥ (ឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើវិលោភសេពសន្ថវៈ) គឺជា ឃាតកម្ម ។

ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ២០០.–** ឃាតកម្មគិតទុកជាមុន

ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយការពួនស្ទាក់ ។

ការគិតទុកជាមុន គឺគម្រោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។

ការពួនស្ទាក់ គឺការរង់ចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តហិង្សាទៅលើបុគ្គលនោះ ។

ឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ២០១.–** ឃាតកម្មដែលប្រព្រឹត្តដោយការប្រើថ្នាំពុល

ឃាតកម្មដែលប្រព្រឹត្តដោយការប្រើថ្នាំពុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ២០២.-** ឃាតកម្មដែលមានស្ថានទម្ងន់ទាក់ទងនឹងជនរងគ្រោះ

ឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ :

១-បុគ្គលដែលជាពិសេសទន់ខ្សោយដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬដែលជនល្មើសបានដឹង ។

៣-បុគ្គលដែលជាពិសេសទន់ខ្សោយដោយមូលហេតុនៃជម្ងឺ ឬភាពពិការ កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬដែលជនល្មើសបានដឹង ។

៤-មន្ត្រីរាជការសាធារណៈ ស៊ីវិល ឬយោធាក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២០៣.-** ឃាតកម្មដែលមានស្ថានទម្ងន់អាស្រ័យទៅនឹងគោលដៅ

ឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះបានប្រព្រឹត្ត :

១-លើជនរងគ្រោះ ឬលើដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហារពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលការអន្តរាយ ។

២-លើសាក្សី ដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-លើជនរងគ្រោះ ឬលើដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬសុំឱ្យជួសជុលការអន្តរាយ ។

៤-លើសាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ២០៤.-** ឃាតកម្មប្រព្រឹត្តដោយមន្ត្រីរាជការ

ឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ

ស៊ីវិល ឬយោធាក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២០៥.-** ឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ

ឃាតកម្មដែលកើតក្នុងពេល ឬក្រោយអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ២០៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងនៅក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការប៉ះពាល់ដោយអចេតនាដល់ជីវិត

**មាត្រា ២០៧.-** បទមនុស្សឃាតដោយអចេតនា

បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្ដាលឱ្យស្លាប់អ្នកដទៃដោយ :

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ការមិនយកចិត្តទុកដាក់ ។

២-ការបំពានលើកាតព្វកិច្ច សន្តិសុខ ឬការប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

បទមនុស្សឃាតដោយអចេតនា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២០៨.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាសចំពោះបទល្មើសមនុស្សឃាតដោយអចេតនា :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សព្វផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២០៩.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌនៃនីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តិក្នុងមាត្រា ២០៧ (ធាតុផ្សំនៃបទមនុស្សឃាតដោយអចេតនា) ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល)។

២-ដាក់ឱ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-បិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) ។

៥-ហាមឃាត់ការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណព់ដោយមាត្រា ១៧៧ (ការហាម ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) ។

៦-ការបិទផ្សាយនូវសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្ដីសម្រេច) ។

៧-ចុះផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## មាតិកាទី ២

## ការប៉ះពាល់ដល់បូរណភាពនៃបុគ្គល

### ជំពូកទី ១

### ទារុណកម្ម និងអំពើឃោរឃៅ

**មាត្រា ២១០.-** ទារុណកម្ម និងអំពើឃោរឃៅ

ទារុណកម្ម ឬអំពើឃោរឃៅដែលប្រព្រឹត្តទៅលើបុគ្គលណាមួយ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ២១១.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនរងគ្រោះ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (ទារុណកម្ម និងអំពើឃោរឃៅ) ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ :

១-បុគ្គលណាម្នាក់ជាពិសេសដែលទន់ខ្សោយដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្ដែង ឬដែលជនល្មើសបានដឹង ។

៣-បុគ្គលដែលជាពិសេសទន់ខ្សោយដោយមូលហេតុនៃជម្ងឺ ឬភាពពិការ កាលបើស្ថានភាពបុគ្គលនេះ ត្រូវបានគេឃើញជាក់ស្ដែង ឬដែលជនល្មើសបានដឹង ។

**មាត្រា ២១២.-** ស្ថានទម្ងន់ទាក់ទងទៅនឹងគោលដៅ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (ទារុណកម្ម និងអំពើឃោរឃៅ) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្ត :

១-លើជនរងគ្រោះ ឬលើដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹង បរិហារពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលការអន្តរាយ ។

២-លើសាក្សីដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-លើជនរងគ្រោះ ឬលើដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារ ពីបទល្មើស ឬសុំឱ្យជួសជុលការអន្តរាយ ។

៤-លើសាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ២១៣.-** ស្ថានទម្ងន់ទាក់ទងទៅនឹងចារី

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (ទារុណកម្ម និងអំពើឃោរឃៅ) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើ ឧក្រិដ្ឋនេះ ត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ ស៊ីវិល ឬយោធានៅក្នុង ក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២១៤.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមានការកាត់ផ្តាច់អវៈយវៈ និងពិការភាព

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (ទារុណកម្ម និងអំពើឃោរឃៅ) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទឧក្រិដ្ឋ នេះនាំឱ្យមានការកាត់អវៈយវៈ ឬឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២១៥.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមរណភាពនៃជនរងគ្រោះ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (ទារុណកម្ម និងអំពើឃោរឃៅ) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាល

បើអំពើឧក្រិដ្ឋនេះនាំឱ្យមានមរណភាពដល់ជនរងគ្រោះ ដោយគ្មានបំណងនឹងធ្វើឱ្យស្លាប់ ឬនាំឱ្យមានអត្តឃាតរបស់ជននោះ ។

**មាត្រា ២១៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងនៅក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## អំពើហិង្សា

**មាត្រា ២១៧.-** អំពើហិង្សាដោយចេតនា

អំពើប្រព្រឹត្តដោយចេតនានូវហិង្សាលើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២១៨.-** ស្ថានទម្ងន់

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះបានប្រព្រឹត្ត :

១-ដោយមានការគិតទុកជាមុន ។

២-ដោយប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ ។

៣-ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត ។

**មាត្រា ២១៩.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនរងគ្រោះ

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះត្រូវបានប្រព្រឹត្តទៅលើ :

១-បុគ្គលណាម្នាក់ដែលជាពិសេសទន់ខ្សោយដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬដែលជនល្មើសបានដឹង ។

៣-បុគ្គលដែលជាពិសេសទន់ខ្សោយដោយមូលហេតុនៃជម្ងឺ ឬភាពពិការ កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬដែលជនល្មើសបានដឹង ។

**មាត្រា ២២០.-** ស្ថានទម្ងន់ទាក់ទងទៅនឹងគោលដៅ

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះ ត្រូវបានប្រព្រឹត្ត :

១-លើជនរងគ្រោះ ឬលើដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហារពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលការអន្តរាយ ។

២-លើសាក្សី ដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-លើជនរងគ្រោះ ឬលើដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬសុំឱ្យជួសជុលការអន្តរាយ ។

៤-លើសាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ២២១.-** ស្ថានទម្ងន់ទាក់ទងទៅនឹងចារី

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះ ត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ ស៊ីវិល ឬយោធានៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២២២.-** អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះ ត្រូវបានប្រព្រឹត្តដោយសហព័ទ្ធ ឬដោយ អនីតិសង្វាសជនរបស់ជនរងគ្រោះ ។

**មាត្រា ២២៣.-** ស្ថានទម្ងន់ដែលបណ្ដាលមកពីមានការកាត់ផ្ដាច់អវយវៈ និងពិការភាព

អំពើហិង្សាដោយចេតនា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវយវៈ ឬឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២២៤.-** ស្ថានទម្ងន់ដែលបណ្ដាលមកពីមរណភាពនៃជនរងគ្រោះ

អំពើហិង្សាដោយចេតនា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានមរណភាពដល់ជនរងគ្រោះ ដោយគ្មានចេតនានឹងធ្វើឱ្យស្លាប់ទេ ។

**មាត្រា ២២៥.-** ការប្រដូចការប្រើសារជាតិពុលទៅនឹងអំពើហិង្សាដោយចេតនា

អំពើដែលឱ្យអ្នកដទៃផឹក លេប ឬបញ្ចូលទៅក្នុងខ្លួនអ្នកដទៃ តាមមធ្យោបាយណាក៏ដោយ ដោយចេតនានូវសារជាតិដែលបណ្ដាលឱ្យខូចសុខភាព ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៦.-** ការប្រដូចការផ្ដល់អាហារដែលមានសារជាតិពុលទៅនឹងអំពើហិង្សាដោយចេតនា

អំពើលក់ ធ្វើអនុប្បទាន ឬឱ្យចំណី ឬភេសជ្ជៈ ដោយដឹងថាចំណី ឬភេសជ្ជៈនោះ នាំឱ្យខូចសុខភាពនោះ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៧.-** ការប្រដូចការបញ្ចូលសារធាតុជាតិពុលក្នុងទឹកសម្រាប់បរិភោគទៅនឹងអំពើហិង្សាដោយចេតនា

អំពើប្រព្រឹត្តឡើងដោយចេតនា ដោយដាក់បញ្ចូលនូវសារជាតិនាំឱ្យខូចសុខភាពទៅក្នុងទឹកសម្រាប់ហូបជាសាធារណៈ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៨.-** អំពើហិង្សាស្រាល

អំពើប្រព្រឹត្តទៅលើអ្នកដទៃនូវហិង្សាស្រាលដែលមិននាំឱ្យមានរបួសទេនោះ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ២២៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ៥ (ប្រាំ) យ៉ាង ច្រើន ។

៤-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្តីផ្តន្ទាទោស សម្រាប់រយៈពេល ២ (ខែ) យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោត ទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៣០.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តិក្នុងមាត្រា ២២៦ (ការប្រដូចការផ្តល់អាហារដែលមានសារជាតិពុលទៅ

នឹងអំពើហិង្សាដោយចេតនា) និងមាត្រា ២២៧ (ការប្រឆ្លូចការបញ្ចូលសារធាតុជាតិពុលក្នុងទឹកសម្រាប់បរិភោគទៅនឹងអំពើហិង្សាដោយចេតនា) ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ១០.០០០.០០០ (ដប់លាន) ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្តេញចេញពីអាបណសញ្ញា តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) ។

៦-បិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) ។

៧-ហាមឃាត់ការធ្វើអាជីវកម្មលើ គ្រឹះស្ថានដែលបើកចំហសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាម ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៩-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

១១-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

១២-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## ជំពូកទី ៣
## ការគំរាមកំហែង

**មាត្រា ២៣១.-** អំពើគំរាមកំហែង

ការគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមប្រឆាំងនឹងបុគ្គល កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត ឬដោយស្តែងចេញតាមលិខិត រូបភាព ឬវត្ថុ អ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ២៣២.-** ការគំរាមកំហែងដោយការបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ

ការគំរាមកំហែងក្រោមរូបភាពណាក៏ដោយ ថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល ប្រសិនបើការគំរាមកំហែងនេះត្រូវបានធ្វើឡើងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២

(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៣៣.-** ការគំរាមកំហែងថានឹងសម្លាប់

ការគំរាមកំហែងថានឹងសម្លាប់ កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត ឬដោយស្តែងចេញតាមលិខិត រូបភាព ឬវត្ថុអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៣៤.-** ការគំរាមថានឹងសម្លាប់ ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ

ការគំរាមកំហែងថានឹងសម្លាប់ក្រោមរូបភាពណាក៏ដោយ ប្រសិនបើការគំរាមកំហែងនេះ ត្រូវបានធ្វើឡើងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២៣៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសត្រូវបានប្រព្រឹត្តឡើងនៅក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៤
## ការបង្កឱ្យមានរបួសដោយអចេតនា

**មាត្រា ២៣៦.-** អំពើបង្កឱ្យមានរបួសដោយអចេតនា

បទល្មើសបង្កឱ្យមានរបួសដោយអចេតនា គឺជាអំពើដែលបណ្តាលឱ្យមានរបួសដល់អ្នកដទៃដោយ :

១-ការមិនប្រុងប្រយ័ត្ន ដោយការមិនយកចិត្តទុកដាក់ ដោយការធ្វេសប្រហែស ដែលបង្កឱ្យមានអសមត្ថភាពធ្វើការងារស្មើ ឬលើសពី ៨ (ប្រាំបី) ថ្ងៃ ។

២-ការបំពានលើកាតព្វកិច្ច សន្តិសុខ ឬការមិនប្រុងប្រយ័ត្នដែលច្បាប់បានតម្រូវ ។

បទល្មើសបង្កឱ្យមានរបួសដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៣៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយ សម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៣៨.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តក្នុងមាត្រា ២៣៦ (អំពើបង្កឱ្យមានរបួសដោយអចេតនា) ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-បិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) ។

៥-ហាមឃាត់ការធ្វើអាជីវកម្មលើ គ្រឹះស្ថានដែលបើកចំហសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាម ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) ។

៦-បិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

៧-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## មាតិកាទី ៣
## ការឈ្លានពានខាងផ្លូវភេទ
## ជំពូកទី ១
## ការរំលោភសេពសន្ថវៈ

**មាត្រា ២៣៩.-** ធាតុផ្សំបទរំលោភសេពសន្ថវៈ

អំពើបញ្ចូលកេរភេទ តាមប្រភេទណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងកេរភេទ ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្មក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ ។

ការចាប់រំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

នីតិភាពនៃការរួមភេទ ត្រូវបានកំណត់ចាប់ពីអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

**មាត្រា ២៤០.-** ស្ថានទម្ងន់ដោយផ្អែកលើមធ្យោបាយដែលប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើង :

១-ដោយការប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយមិនអាចទប់ទល់បាន ។

៣-ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាច ដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។

**មាត្រា ២៤១.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅលើ :

១-បុគ្គលណាម្នាក់ជាពិសេសដែលទន់ខ្សោយដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬដែលជនល្មើសបានដឹង ។

៣-បុគ្គលដែលជាពិសេសទន់ខ្សោយដោយមូលហេតុនៃជម្ងឺ ឬភាពពិការ កាលបើស្ថានភាពបុគ្គលនេះ ត្រូវបានគេឃើញជាក់ស្តែង ឬដែលជនល្មើសបានដឹង ។

**មាត្រា ២៤២.-** ស្ថានទម្ងន់បណ្តាលមកពីមានការកាត់អវៈយវៈ ឬពិការភាព

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះ នាំឱ្យមានការកាត់អវៈយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២៤៣.-** ស្ថានទម្ងន់បណ្តាលមកពីការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះបានកើតឡើងមុន ក្នុងពេល ឬក្រោយពីបានប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ ។

**មាត្រា ២៤៤.-** ស្ថានទម្ងន់បណ្តាលមកពីមរណភាពនៃជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះនាំឱ្យជនរងគ្រោះស្លាប់ដោយគ្មានបំណងនឹងធ្វើឱ្យស្លាប់ ។

**មាត្រា ២៤៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំយ៉ាងច្រើន ។

៤-ការហាមចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការចេញផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សព្វផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការឈ្លានពានផ្លូវភេទដទៃទៀត

**មាត្រា ២៤៦.-** អំពើអាស

អំពើអាស ទោះបីតាមប្រភេទណាក៏ដោយ ដែលប្រព្រឹត្តទៅលើអ្នកដទៃ ដោយហិង្សា ដោយការបង្ខិតបង្ខំ ដោយការគំរាមកំហែង ឬការឆ្លក់ឱកាស ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២៤៧.-** ស្ថានទម្ងន់ដោយផ្អែកលើមធ្យោបាយដែលប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស

បទល្មើសដែលមានចែងក្នុងមាត្រា ២៤៦ (អំពើអាស) ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះ ប្រព្រឹត្តឡើង ៖

១-ដោយការប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយមិនអាចទប់ទល់បាន ។

៣-ដោយបុគ្គលដែលមានអំណាច ទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាច ដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី ជាអ្នកផ្ដើមគំនិត ឬជាអ្នកសមគំនិត ។

**មាត្រា ២៤៨.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនរងគ្រោះ

បទល្មើសដែលមានចែងក្នុងមាត្រា ២៤៦ (អំពើអាស) ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះប្រព្រឹត្តទៅលើ :

១-បុគ្គលណាម្នាក់ជាពិសេសដែលទន់ខ្សោយដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្ដែង ឬដែលជនល្មើសបានដឹង ។

៣-បុគ្គលដែលជាពិសេសទន់ខ្សោយដោយមូលហេតុនៃជម្ងឺ ឬភាពពិការ កាលបើស្ថានភាពបុគ្គលនេះ ត្រូវបានគេឃើញជាក់ស្ដែង ឬដែលជនល្មើសបានដឹង ។

**មាត្រា ២៤៩.-** ការបង្ហាញកេរភេទ

ការបង្ហាញកេរភេទ ដែលនាំឱ្យអ្នកដទៃមើលឃើញ នៅក្នុងកន្លែងមួយដែលសាធារណជនអាចមើលឃើញ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ហាសិបម៉ឺន) រៀល ។

**មាត្រា ២៥០.-** អំពើរុកកួនខាងផ្លូវភេទ

អំពើរុកកួនខាងផ្លូវភេទ គឺជាអំពើដែលបុគ្គលម្នាក់រំលោភអំណាចរបស់ខ្លួន

ដែលមុខងាររបស់ខ្លួនប្រគល់ឱ្យ ធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃក្នុងគោល បំណងទទួលការអនុគ្រោះ ដែលមានប្រភេទជាផ្លូវភេទ ។

អំពើរុកគួនខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ហាសិបម៉ឺន) រៀល ។

**មាត្រា ២៥១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ២៥២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការចេញផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សព្វផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ៤
## ការប៉ះពាល់ដល់សេរីភាព
## ជំពូកទី ១
## ការចាប់ ការឃុំឃាំង និងការបង្ខាំងខុសច្បាប់

**មាត្រា ២៥៣.-** អំពើចាប់ ឃុំឃាំង ឬបង្ខាំងខុសច្បាប់

បុគ្គលដែលចាប់ ដែលឃុំឃាំង ឬដែលបង្ខាំងបុគ្គលផ្សេងទៀត ដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក្រៅពីករណីដែលច្បាប់អនុញ្ញាត ត្រូវផ្ដន្ទាទោស :

១-ដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬការបង្ខាំងខ្លួនមានរយៈពេលតិចជាង ៤៨ (សែសិបប្រាំបី) ម៉ោង ។

២-ដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬការបង្ខាំងខ្លួនមានរយៈពេលចាប់ពី ៤៨ (សែសិបប្រាំបី) ម៉ោង ដល់តិចជាង ១ (មួយ) ខែ ។

៣-ដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬការបង្ខាំងខ្លួនមានរយៈពេលស្មើ ឬលើសពី ១ (មួយ) ខែ ។

**មាត្រា ២៥៤.-** ស្ថានទម្ងន់ទោស

បុគ្គលដែលចាប់ ដែលឃុំឃាំង ឬដែលបង្ខាំងបុគ្គល ដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក្រៅពីករណីដែលច្បាប់អនុញ្ញាត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ក្នុងករណីដូចខាងក្រោម :

១-ដោយមានទារុណកម្ម ឬអំពើឃោរឃៅ ។

២-បណ្ដាលឱ្យមានមនុស្សស្លាប់ដោយគ្មានបំណងនឹងធ្វើឱ្យស្លាប់ ។

៣-ប្រព្រឹត្តក្នុងគោលដៅជំរិតយកប្រាក់ ។

**មាត្រា ២៥៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការចេញផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សព្វផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការប៉ះពាល់ដល់សេរីភាពដនៃទៀត

**មាត្រា ២៥៦.-** អំពើដណ្ដើមកាន់កាប់មធ្យោបាយដឹកជញ្ជូន

អំពើដណ្ដើម ឬយកការត្រួតត្រាដោយហិង្សា ឬដោយការគំរាមកំហែងថានឹងប្រើហិង្សាលើមធ្យោបាយដឹកជញ្ជូនដែលមានបុគ្គលច្រើនរូបជិះក្នុងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ២៥៧.-** ស្ថានទម្ងន់បណ្ដាលមកពីមានការកាត់អវយវៈ ឬពិការភាព

បទល្មើសដែលមានចែងក្នុងមាត្រា ២៥៦ (អំពើដណ្ដើមកាន់កាប់មធ្យោបាយដឹកជញ្ជូន) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើបទល្មើសនោះនាំឱ្យមានការកាត់អវយវៈ ឬឱ្យមានពិការភាពជាអចិន្ត្រៃយ៍ចំពោះជនរងគ្រោះ ។

**មាត្រា ២៥៨.-** ស្ថានទម្ងន់បណ្ដាលមកពីការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

បទល្មើសដែលមានចែងក្នុងមាត្រា ២៥៦ (អំពើដណ្ដើមកាន់កាប់មធ្យោបាយដឹកជញ្ជូន) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើមានធ្វើទារុណកម្ម ឬអំពើឃោរឃៅនៅមុន ក្នុងពេល ឬក្រោយពីបានប្រព្រឹត្តបទល្មើស ។

**មាត្រា ២៥៩.-** ស្ថានទម្ងន់បណ្ដាលមកពីមានការកាត់អវយវៈ ឬពិការភាព

បទល្មើសដែលមានចែងក្នុងមាត្រា ២៥៦ (អំពើដណ្ដើមកាន់កាប់មធ្យោបាយដឹកជញ្ជូន) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើបទល្មើសនេះបណ្ដាលឱ្យមនុស្សស្លាប់ម្នាក់ ឬច្រើននាក់ ។

**មាត្រា ២៦០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សព្វផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនា-គមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

# មាតិកាទី ៥

# ការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ

## ជំពូកទី ១

## ការប៉ះពាល់ដល់ការគោរព ដែលតម្រូវឱ្យមានចំពោះអ្នកដែលស្លាប់

**មាត្រា ២៦១.-** អំពើប៉ះពាល់ដល់បូរណភាពនៃសាកសព

អំពើធ្វើឱ្យប៉ះពាល់ដល់បូរណភាពនៃសាកសព ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ២៦២.-** អំពើប្រមាថទីបញ្ចុះសព

អំពើប្រមាថតាមមធ្យោបាយណាមួយក៏ដោយទៅលើផ្នូរ លើទីបញ្ចុះសព ទៅលើកោដិ ឬវិមានដែលកសាងឡើងសម្រាប់រំលឹកវិញ្ញាណក្ខ័ន្ធនៃអ្នកទទួលមរណភាព ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ២៦៣.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ២៦៤.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការចេញផ្សាយសេចក្ដីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សព្វផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការរើសអើង

**មាត្រា ២៦៥.-** អំពើបដិសេធក្នុងការផ្តល់ទ្រព្យ ឬសេវា

អំពើដែលមិនព្រមផ្តល់នូវទ្រព្យសម្បត្តិ ឬសេវាទៅដល់បុគ្គលណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល កាលបើការមិនព្រមនេះផ្អែកទៅលើមូលហេតុណាមួយដូចតទៅ :

១-ការដែលបុគ្គលនោះជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិពន្ធុ ជាតិ ឬពូជសាសន៍ណាមួយជាកំណត់ ។

២-ការដែលបុគ្គលនោះជាសមាជិក ឬមិនមែនជាសមាជិកនៃសាសនាណាមួយជាកំណត់ ។

៣-និន្នាការនយោបាយរបស់បុគ្គល ។

៤-សកម្មភាពសហជីពរបស់បុគ្គល ។

៥-ស្ថានភាពគ្រួសាររបស់បុគ្គល ។

៦-ភេទរបស់បុគ្គល ។

៧-ស្ថានភាពសុខភាពបុគ្គល ។

៨-ពិការភាពរបស់បុគ្គល ។

**មាត្រា ២៦៦.-** អំពើផ្តល់ទ្រព្យ ឬសេវាដោយមានលក្ខខណ្ឌ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យ

ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ចំពោះអំពើដែលផ្ដល់ទ្រព្យសម្បត្តិ ឬសេវាឱ្យដល់បុគ្គលណាមួយដោយមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌដូចតទៅ :

១-ការដែលបុគ្គលនោះជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិ ពន្ធុ ប្រជាជាតិ ឬពូជសាសន៍ណាមួយជាកំណត់ ។

២-ការដែលបុគ្គលនោះជាសមាជិក ឬមិនមែនជាសមាជិកនៃសាសនាណាមួយជាកំណត់ ។

៣-និន្នាការនយោបាយរបស់បុគ្គល ។

៤-សកម្មភាពសហជីពរបស់បុគ្គល ។

៥-ស្ថានភាពគ្រួសាររបស់បុគ្គល ។

៦-ភេទរបស់បុគ្គល ។

៧-ស្ថានភាពសុខភាពបុគ្គល ។

៨-ពិការភាពរបស់បុគ្គល ។

**មាត្រា ២៦៧.-** អំពើបដិសេធនូវការជួលបុគ្គលឱ្យធ្វើការ

ការមិនព្រមជួលបុគ្គលណាម្នាក់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល កាលបើការមិនព្រមជួលនេះផ្អែកទៅលើមូលហេតុដែលមានចែងនៅចំណុចទី ១ ដល់ចំណុចទី ៨ នៃមាត្រា ២៦៥ (អំពើបដិសេធក្នុងការផ្ដល់ទ្រព្យ ឬសេវា) នៃក្រមនេះ ។

**មាត្រា ២៦៨.-** អំពើបដិសេធនូវការជួលបុគ្គលឱ្យធ្វើការ

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើដែលដាក់ការផ្ដល់ការងារឱ្យស្ថិតនៅក្រោមលក្ខខណ្ឌដូចមានចែងនៅចំណុចទី ១ ដល់ចំណុចទី ៨ នៃមាត្រា ២៦៦ (អំពើផ្ដល់ទ្រព្យ ឬសេវាដោយមានលក្ខខណ្ឌ) នៃក្រមនេះ ។

**មាត្រា ២៦៩.-** ទោសដែលអនុវត្តចំពោះការបណ្តេញចេញ ឬដកហូតដោយផ្អែកលើមូលហេតុនៃការរើសអើង

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល សេចក្តីសម្រេចបណ្តេញចេញ ឬដកហូតបុគ្គលណាម្នាក់ ដោយផ្អែកលើមូលហេតុណាមួយ ដូចមានចែងនៅចំណុចទី ១ ដល់ចំណុចទី ៨ នៃមាត្រា ២៦៥ (អំពើបដិសេធក្នុងការផ្តល់ទ្រព្យ ឬសេវា) នៃក្រមនេះ ។

**មាត្រា ២៧០.-** ការរើសអើង ការបដិសេធផ្តល់សិទ្ធិដោយអ្នករាជការ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល អំពើដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈ ស៊ីវិល ឬយោធានៅក្នុងក្របខ័ណ្ឌនៃមុខងារ របស់ខ្លួន ឬក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ដោយបដិសេធចំពោះបុគ្គលណាម្នាក់នូវការទទួលសិទ្ធិណាមួយ កាលបើការបដិសេធនោះផ្អែកលើមូលហេតុណាមួយដូចមានចែងនៅចំណុចទី ១ ដល់ចំណុចទី ៨ នៃមាត្រា ២៦៥ (អំពើបដិសេធក្នុងការផ្តល់ទ្រព្យ ឬសេវា) នៃក្រមនេះ ។

**មាត្រា ២៧១.-** ការរើសអើងដែលអនុញ្ញាតដោយច្បាប់

បទល្មើសដែលកំណត់នៅក្នុងជំពូកនេះ មិនគ្រប់ធាតុផ្សំទេ នៅក្នុងករណីដែលការរើសអើងត្រូវបានអនុញ្ញាតដោយច្បាប់ ។

បទប្បញ្ញត្តិជំពូកនេះមិនអនុវត្តចំពោះករណីដូចខាងក្រោម :

១-ការរើសអើងដែលមានមូលដ្ឋានលើ ស្ថានភាពសុខភាព កាលបើការរើសអើងនេះមានគោលដៅបង្ការភយន្តរាយដល់បូរណភាពបុគ្គល សមត្ថភាពការងារ ឬពិការភាព ។

២-ការរើសអើងដែលមានមូលដ្ឋានលើ ស្ថានភាពសុខភាព ឬពិការភាព កាលបើ ការរើសអើងនេះ ជាការបដិសេធមិនជួលឱ្យធ្វើការងារ ការបណ្តេញឈប់ពីការងារ ដោយមូលហេតុអសមត្ថភាពបញ្ជាក់ដោយវេជ្ជសាស្ត្រ ។

៣-ក្នុងរឿងជួលឱ្យធ្វើការងារ ការរើសអើងដែលមានមូលដ្ឋានលើផ្លូវភេទ កាលបើលក្ខខណ្ឌខាងភេទ ជាលក្ខខណ្ឌចាំបាច់ដើម្បីធ្វើការងារ ឬសកម្មភាពវិជ្ជាជីវៈអ្វីមួយ ។

**មាត្រា ២៧២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការចេញផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សព្វផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៧៣.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តក្នុងមាត្រា ២៦៥ (អំពើបដិសេធក្នុងការផ្ដល់ទ្រព្យ ឬសេវា) និងមាត្រា ២៦៩ (ទោសដែលអនុវត្តចំពោះការបណ្ដេញចេញ ឬដកហូតដោយផ្អែកលើមូលហេតុនៃការរើសអើង) ។

នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

២-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៣-បិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

៤-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## ជំពូកទី ៣
## លក្ខខណ្ឌការងារផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស

**មាត្រា ២៧៤.-** អំពើដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស

អំពើដែលដាក់បុគ្គលណាម្នាក់ ដោយរំលោភទៅលើភាពទន់ខ្សោយ ឬលើស្ថានភាពនៃអនិស្សរភាពរបស់បុគ្គលនោះ ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារ ដែលប៉ះពាល់នឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ២៧៥.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសមជ្ឈិមដែលមានចែងនៅក្នុងមាត្រា ២៧៤ (អំពើដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស) ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ២៧៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សព្វផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៧៧.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តិក្នុងមាត្រា ២៧៤ (អំពើដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស) ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ១.០០០.០០០ (មួយលាន) ទៅ ១០.០០០.០០០ (ដប់លាន) រៀល ព្រមទាំងបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្តេញចេញពីអាបណសញ្ញា តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) ។

៦-បិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) ។

៧-ហាមឃាត់ការធ្វើអាជីវកម្មលើ គ្រឹះស្ថានដែលបើកចំហសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាម ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៩-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

១១-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

១២-ចុះផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## ជំពូកទី ៤
## អំពើពុករលួយនៃនិយោជិត

**មាត្រា ២៧៨.-** អំពើស៊ីសំណូកនៃនិយោជិត

អំពើប្រព្រឹត្តដោយនិយោជិតដែលទទួចសុំ ឬយល់ព្រមទទួលអំណោយ ការសន្យា ឬអត្ថប្រយោជន៍ណាមួយដើម្បីបំពេញ ឬមិនបំពេញកិច្ចណាមួយនៃមុខងាររបស់ខ្លួន ដោយនិយោជកមិនបានដឹង និងគ្មានការព្រមព្រៀងពីនិយោជកទេនោះ ត្រូវផ្ដន្ទាទោសដាក់ ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៧៩.-** អំពើសូកប៉ាន់ចំពោះនិយោជិត

បុគ្គលដែលប្រគល់ឱ្យនិយោជិតនូវអំណោយ ឬជូនជំនូន ធ្វើការសន្យាជាមួយ ឬយល់ព្រមឱ្យអត្ថប្រយោជន៍អ្វីមួយដល់និយោជិត ដើម្បីឱ្យបំពេញ ឬមិនបំពេញកិច្ចអ្វីមួយ នៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹង ហើយគ្មានការព្រមព្រៀងពីនិយោជកទេ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៨០.-** អំពើស៊ីសំណូករបស់អភិបាល ជាអាទិ៍

១-បើបុគ្គលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ នៃមាត្រា ៣៩៦ (ការរំលោភទំនុកចិត្តពិសេស ដោយអភិបាល ឬបុគ្គលផ្សេងទៀត) ឬអធិការបានទទួលផលប្រយោជន៍ជាទ្រព្យសម្បត្តិ ឬបានទាមទារ ឬបានសន្យាទទួលផលប្រយោជន៍នោះ ដោយបានទទួលការពឹងពាក់ខុសច្បាប់ បុគ្គលនោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

២-បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបុគ្គលដែលបានផ្តល់នូវផលប្រយោជន៍ដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនោះ ឬបានស្នើសុំផ្តល់ ឬសន្យាផ្តល់នូវផលប្រយោជន៍នោះ ។

៣-ផលប្រយោជន៍ជាទ្រព្យសម្បត្តិដូចបានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ នឹងត្រូវដកហូត ។ បើមិនអាចដកហូតទាំងមូល ឬផ្នែកខ្លះនៃផលប្រយោជន៍នោះ ភាគដែលខ្វះនោះ ត្រូវទារឱ្យថែមជាប្រាក់ ។

**មាត្រា ២៨១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងមាត្រា ២៧៨ (អំពើស៊ីសំណូកនៃនិយោជិត) និងមាត្រា ២៧៩ (អំពើសូកប៉ាន់ចំពោះនិយោជិត) ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ២៨២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សព្វផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៨៣.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តិក្នុងមាត្រា ២៧៩ (អំពើសូកប៉ាន់ចំពោះនិយោជិត) ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ៥.០០០.០០០ (ប្រាំលាន) ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ព្រមទាំងបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្តេញចេញពីអាបណសញ្ញា តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) ។

៦-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៧-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

៨-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

# ជំពូកទី ៥
# សព្វាវកម្ម

**មាត្រា ២៨៤.-** សព្វារកម្ម

សព្វារកម្ម គឺជាអំពើ :

១-ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់អ្នកដទៃ ។

២-ជួយ ឬការពារអំពើពេស្យាចាររបស់អ្នកដទៃ ឬរៀបចំ តាមគ្រប់មធ្យោបាយនូវសកម្មភាពពេស្យាចារ ។

៣-ជ្រើសរើស ពង្រត់ ឬអូសទាញបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ ។

៤-ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ ។

សព្វារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ២៨៥.-** អន្តរការរវាងបុរស ឬស្ត្រីពេស្យា និងសព្វារិក ឬសព្វារិកា

អំពើធ្វើជាអន្តរការី រវាងបុរស ឬស្ត្រីពេស្យា និងសព្វារិក ឬសព្វារិកា ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ២៨៦.-** ការបញ្ជាក់អំពីធនធានដោយសន្មត

អំពើរបស់ជនណាដែលបានជួយសម្រួល ឬបិទបាំងនូវធនធានដែលខ្លួនបានដឹងថាបានមកពីអំពើសព្វារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដូចគ្នាផងដែរ ចំពោះបុគ្គលដែលមិនអាចបញ្ជាក់អំពីប្រភពធនធានរបស់ខ្លួន ដោយរស់នៅជាមួយជនដែលធ្វើសកម្មភាពពេស្យាចារជាទម្លាប់

ឬដោយសារ មានទំនាក់ទំនងជាទម្លាប់ជាមួយជនម្នាក់ ឬច្រើននាក់ដែលធ្វើសកម្មភាពពេស្យាចារ ។

**មាត្រា ២៨៧.-** អំពើរារាំងដល់ការបង្ការអំពើពេស្យាចារ

អំពើរារាំងដល់ការបង្ការ ការជួយ ឬការអប់រំជាថ្មី ដោយសេវាសាធារនៈ ឬដោយអង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីអនុគ្រោះដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬកំពុងមានគ្រោះដោយការធ្វើពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ២៨៨.-** ស្ថានទម្ងន់ទាក់ទងទៅនឹងសញ្ចារិក

សញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចខាងក្រោមនេះ :

១-កាលបើសញ្ចារិក សញ្ចារិកា ឬជនជាមេពេស្យាជាបុព្វញាតិ ឬបច្ឆាញាតិរបស់បុគ្គលដែលធ្វើពេស្យាចារ ។

២-កាលបើសញ្ចារិក សញ្ចារិកា ឬជនជាមេពេស្យារំលោភអំណាចដែលមុខងាររបស់ខ្លួនផ្តល់ឱ្យទៅលើបុគ្គលដែលធ្វើពេស្យាចារ ។

៣-កាលបើសញ្ចារិក សញ្ចារិកា ឬជនជាមេពេស្យាប្រើហិង្សា ឬការបង្ខិតបង្ខំចំពោះបុគ្គលដែលធ្វើពេស្យាចារ ។

៤-កាលពើសញ្ចារកម្មត្រូវបានប្រព្រឹត្តជាក្រុមមានការចាត់តាំង ។

៥-កាលពើសញ្ចារកម្មត្រូវបានប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ ។

**មាត្រា ២៨៩.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនរងគ្រោះ

សញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបុគ្គលដែលធ្វើពេស្យាចារនោះជាអនីតិជន ។

**មាត្រា ២៩០.-** ស្ថានទម្ងន់ដែលបណ្តាលមកពីការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

សញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ

កាលបើសញ្ជារិក សញ្ជារិកា ឬមេពេស្យាបានប្រើប្រាស់ទារុណកម្ម ឬអំពើឃោរឃៅ ចំពោះបុគ្គលដែលធ្វើពេស្យាចារ ។

**មាត្រា ២៩១.-** អំពើដឹកនាំគ្រប់គ្រងគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារ

អំពើគ្រប់គ្រងធ្វើអាជីវកម្ម ដឹកនាំធ្វើឱ្យដំណើរការ ឬចេញប្រាក់ឱ្យគ្រឹះស្ថានពេស្យាចារដោយផ្ទាល់ តាមរយៈអន្តរការី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ២៩២.-** អំពើយល់ព្រមឱ្យធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថានមួយ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើរបស់អ្នកដែលគ្រប់គ្រង ធ្វើអាជីវកម្ម ដឹកនាំ ឬធ្វើឱ្យដំណើរការនូវគ្រឹះស្ថានណាមួយដែលបើកចំហដល់សាធារណជនដោយផ្ទាល់ ឬតាមអន្តរការី បានយល់ព្រម ឬបាន អនុគ្រោះ :

១-ឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តជាប្រចាំនូវពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬនៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន ។

២-ឱ្យបុគ្គលណាម្នាក់រកជាប្រចាំនូវភ្ញៀវ ដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬ នៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន ។

**មាត្រា ២៩៣.-** អំពើដាក់ឱ្យប្រើប្រាស់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះបុគ្គលដែលលក់ ឬដាក់ឱ្យបុគ្គលណាម្នាក់ប្រើប្រាស់ទីកន្លែងដែលមិនមែនប្រើប្រាស់ដោយសាធារណជន ដោយដឹងជាក់ច្បាស់ថាបុគ្គលនោះ នឹងប្រើប្រាស់ទីកន្លែងនោះ សម្រាប់ធ្វើសកម្មភាពពេស្យាចារ ។

**មាត្រា ២៩៤.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិម ។

**មាត្រា ២៩៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៧-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្តឡើង ។

៩-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១១-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬប្រព្រឹត្តបទល្មើស ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១២-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៤-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៥-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៩៦.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តិនៅក្នុងជំពូកនេះ ។

នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ ១០.០០០.០០០ (ដប់លាន) ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-បិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) ។

៥-ហាមឃាត់ការធ្វើអាជីវកម្មលើ គ្រឹះស្ថានដែលបើកចំហសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាម ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៧-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៨-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៩-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

១០-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## ជំពូកទី ៦
## ការប៉ះពាល់ផ្សេងទៀតដល់សេចក្តីថ្លៃថ្នូរ

**មាត្រា ២៩៧.-** ការស្រវឹងជាក់ស្តែង

បុគ្គលណាដែលស្ថិតនៅក្នុងសភាពស្រវឹងយ៉ាងជាក់ស្តែងនៅលើផ្លូវសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ២៩៨.-** អំពើហៅអ្នកដទៃនៅទីសាធារណៈ

បុគ្គលណាដែលហៅអ្នកដទៃនៅទីសាធារណៈ ដើម្បីញុាំងឱ្យមានទំនាក់ទំនងផ្លូវភេទ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ៥០.០០០ (ប្រាំម៉ឺន) រៀល ។

## មាតិកាទី ៦
## ការប៉ះពាល់ដល់បុគ្គលភាព
## ជំពូកទី ១
## ការប៉ះពាល់ដល់ជីវភាពឯកជន

**មាត្រា ២៩៩.-** អំពើរំលោភលំនៅឋាន

អំពើប្រព្រឹត្តដោយមានហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬឧបាយកលចូលទៅក្នុងលំនៅឋានអ្នកដទៃនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល លើកលែងតែក្នុងករណីដែលច្បាប់អនុញ្ញាត ។

**មាត្រា ៣០០.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងចារី

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ស៊ីវិល ឬយោធា នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ចូលទៅក្នុងលំនៅឋានរបស់អ្នកដទៃដោយគ្មានការយល់ព្រមពីម្ចាស់ផ្ទះទេនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ

ពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល លើកលែងតែករណីដែលច្បាប់អនុញ្ញាត ។

**មាត្រា ៣០១.-** អំពើស្តាប់ ឬថតពាក្យសំដីឯកជន

អំពើស្តាប់ ឬថតសំដីដែលនិយាយជាឯកជន ឬជាការសំងាត់ ដោយគ្មានការយល់ព្រមពីបុគ្គលដែលមានការពាក់ព័ន្ធនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល លើកលែងតែករណីដែលច្បាប់អនុញ្ញាត ។

ត្រូវបានសន្មតជាការព្រមព្រៀង ប្រសិនបើបុគ្គលដែលពាក់ព័ន្ធនេះបានទទួលដំណឹងអំពីការស្តាប់ ឬថតហើយ បុគ្គលនោះមិនបានជំទាស់ទេនោះ ។

**មាត្រា ៣០២.-** ការប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល

អំពើថតរូបភាពនៃបុគ្គលនៅក្នុងទីកន្លែងឯកជន ដោយគ្មានការព្រមព្រៀងអំពីបុគ្គលនេះទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យ ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល លើកលែងតែករណីដែលច្បាប់បានអនុញ្ញាត ។

ត្រូវបានសន្មតជាការព្រមព្រៀង ប្រសិនបើបុគ្គលដែលពាក់ព័ន្ធនេះ បានទទួលដំណឹងអំពីការថតហើយ បុគ្គលនេះមិនបានជំទាស់ទេនោះ ។

**មាត្រា ៣០៣.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣០៤.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការបរិហារកេរ្តិ៍ និងការជេរប្រមាថ

**មាត្រា ៣០៥.-** អំពើបរិហារកេរ្តិ៍ជាសាធារណៈ

គ្រប់ទឡ្ហីករណ៍បំផ្លើស ឬការទំលាក់កំហុសដោយអសុទ្ធិចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬដល់កិត្តិស័ព្ទនៃបុគ្គល ឬស្ថាប័នគឺជាការបរិហារកេរ្តិ៍ ។

ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ការបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមមធ្យោបាយណាមួយ ដូចតទៅ :

១-ដោយសំដី ទោះជាប្រភេទណាក៏ដោយ ដែលបញ្ចេញនៅទីសាធារណៈ ឬនៅ ក្នុងសាលប្រជុំសាធារណៈ ។

២-តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬដាក់តាំងឱ្យសាធារណជនមើល ។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ដែលសម្រាប់សាធារណជន ។

**មាត្រា ៣០៦.-** អំពើបរិហារកេរ្តិ៍តាមសារព័ត៌មាន

ការបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ

នៃច្បាប់ស្ដីពីរបបសារព័ត៌មាន ។

**មាត្រា ៣០៧.-** អំពើជេរប្រមាថជាសាធារណៈ

គ្រប់ពាក្យប្រមាថ គ្រប់ពាក្យមើលងាយ ឬគ្រប់ពាក្យទ្រគោះ ដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយគឺជាការជេរប្រមាថ ។

ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បទជេរប្រមាថដែលប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយដូចតទៅ :

១-ដោយពាក្យសំដី ទោះជាប្រភេទណាក៏ដោយ ដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងពេលប្រជុំសាធារណៈ ។

២-តាមលិខិតស្នាម ឬគំនូរ ទោះជាប្រភេទណាក៏ដោយ ដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬដាក់តាំងឱ្យសាធារណជនមើល ។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ដែលសម្រាប់សាធារណជន ។

**មាត្រា ៣០៨.-** អំពើជេរប្រមាថតាមសារព័ត៌មាន

ការជេរប្រមាថដែលប្រព្រឹត្តតាមសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីរបបសារព័ត៌មាន ។

**មាត្រា ៣០៩.-** នីតិវិធីបណ្ដឹងចំពោះបទបរិហារកេរ្ដិ៍ និងជេរប្រមាថ

ក្នុងករណីដែលមានការបរិហារកេរ្ដិ៍ ឬការជេរប្រមាថ ចំពោះសមាជិករាជរដ្ឋាភិបាល មន្ត្រីរាជការសាធារណៈ ឬពលរដ្ឋដែលទទួលបន្ទុកបេសកកម្មសាធារណៈ ឬអាណត្តិសាធារណៈ ការចោទប្រកាន់នឹងត្រូវធ្វើឡើងតាមបណ្ដឹងរបស់សាមីខ្លួន ឬបណ្ដឹងរបស់ប្រធានស្ថាប័នសាមី ។

ក្នុងករណីដែលមានការបរិហារកេរ្ដិ៍ ឬការជេរប្រមាថ ចំពោះបុគ្គលឯកជន ការចោទប្រកាន់នឹងត្រូវធ្វើឡើងតាមបណ្ដឹងរបស់សាមីខ្លួនដែលទទួលរងនូវការបរិហារកេរ្ដិ៍ ឬការជេរប្រមាថនោះ ។ ការបញ្ជូនទៅជំនុំជម្រះ ត្រូវធ្វើឡើងដោយ

បណ្ដឹងទាមទាររបស់ អ្នកប្ដឹងទៅតុលាការដោយផ្ទាល់ ដោយត្រូវបញ្ជាក់អំពីការជ្រើសរើសលំនៅឋានរបស់ខ្លួន នៅក្នុងខេត្ត ក្រុង ដែលជាទីតាំងនៃតុលាការដែលទទួលបណ្ដឹង ហើយនិងត្រូវជូនដំណឹងទៅជនជាប់ចោទ និងអយ្យការ ។

ក៏ប៉ុន្តែការចោទប្រកាន់អាចនឹងត្រូវធ្វើឡើងជាស្វ័យប្រវត្តដោយព្រះរាជអាជ្ញា កាលបើការបរិហារកេរ្តិ៍ ឬជេរប្រមាថនោះ ត្រូវបានធ្វើឡើងប្រឆាំងនឹងបុគ្គលម្នាក់ ឬបុគ្គល មួយក្រុម ដោយមូលហេតុដើមកំណើត ជាតិពន្ធុ ពូជសាសន៍ សញ្ជាតិ ឬសាសនារបស់ បុគ្គលនោះ ។ ក្នុងករណីនេះ នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះ ត្រូវអនុលោមតាម បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ក្រោយពីបានទទួលបណ្ដឹងតាមនីតិវិធីខាងលើ តុលាការអាចបង្គាប់ឱ្យអ្នកប្ដឹង បង់ប្រាក់តម្កល់ទុកបាន ។ លក្ខខណ្ឌ និងនីតិវិធីនៃការបង់ប្រាក់តម្កល់ទុក ដែលអនុវត្តដោយចៅក្រមស៊ើបសួរ ដែលមានចែងនៅក្នុងមាត្រា ១៨០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តចំពោះតុលាការដែលទទួលបណ្ដឹង ។

ទម្រង់បែបបទទាំងនេះ ត្រូវគោរពជាដាច់ខាត បើមិនដូច្នេះទេ ការចោទប្រកាន់ នឹងត្រូវទុកជាមោឃៈ ។

**មាត្រា ៣១០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ។

២-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៣-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

ទោសបន្ថែមដូចមាននៅក្នុងចំណុច ៣ ខាងលើនេះ អាចត្រូវប្រកាសសម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៣
## ការប្ដឹងបរិហារបង្កាច់កេរ្តិ៍

**មាត្រា ៣១១.-** អំពើប្ដឹងបរិហារបង្កាច់កេរ្តិ៍

ការប្ដឹងបរិហារបង្កាច់កេរ្តិ៍ គឺជាអំពើបរិហារពីអំពើដែលគេដឹងថាមិនពិត ហើយដែលនាំឱ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬវិន័យ កាលបើការប្ដឹងបរិហារនេះត្រូវបានផ្ញើទៅដល់ :

១-អាជ្ញាធរមមានសមត្ថកិច្ច ដើម្បីចាត់ការដូចជាចៅក្រម មន្ត្រីនគរបាលយុត្តិធម៌ ឬនិយោជក ។

២-ឬបុគ្គលដែលមានអំណាចប្ដឹងអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៣១២.-** ទោសដែលត្រូវអនុវត្ត និងលក្ខខណ្ឌនៃការចោទប្រកាន់

ការប្ដឹងបរិហារបង្កាច់កេរ្តិ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

បណ្ដឹងអាជ្ញានៃបទល្មើសនេះ ផុតអាជ្ញាយុកាលក្នុងរយៈពេល ១ (មួយ) ឆ្នាំ ។

ចំណុចចាប់ផ្ដើមនៃអាជ្ញាយុកាលនេះ ត្រូវចាប់គិតពីថ្ងៃដែលបណ្ដឹងបរិហារបង្កាច់កេរ្តិ៍បានមកដល់ ឬថ្ងៃដែលបានដាក់ពាក្យប្ដឹងមកអាជ្ញាធរមានសមត្ថកិច្ច ។

នៅក្នុងករណីដែលអំពើប្ដឹងបរិហារបង្កាច់កេរ្តិ៍នេះ នាំឱ្យមានការចោទប្រកាន់ខាងព្រហ្មទណ្ឌ នីតិវិធីដែលផ្ដើមអំពីបទប្ដឹងបរិហារបង្កាច់កេរ្តិ៍នោះ នាំឱ្យផ្អាកអាជ្ញាយុកាល រហូតដល់ពេលបញ្ចប់កិច្ចចោទប្រកាន់ ។

**មាត្រា ៣១៣.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការបិទផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

២-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៣-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៤
## ការប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ

**មាត្រា ៣១៤.-** អំពើប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ

បុគ្គលដែលកាន់កាប់ព័ត៌មានដែលមានលក្ខណៈអាថ៌កំបាំង ដោយមូលហេតុនៃស្ថានភាព មុខរបរ មុខងារ ឬបេសកកម្មរបស់ខ្លួនត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ប្រសិនបើបុគ្គលនោះបង្ហាញព័ត៌មាននេះឱ្យដល់បុគ្គលដែលគ្មានសមត្ថកិច្ចដើម្បីដឹងពីព័ត៌មាននេះ ។

មិនមែនជាបទល្មើសទេ ក្នុងករណីដែលច្បាប់អនុញ្ញាត ឬតម្រូវឱ្យបង្ហាញនូវអាថ៌កំបាំង ។

**មាត្រា ៣១៥.-** បដិប្បញ្ញត្តិក្នុងករណីមានការលាតត្រដាងការប្រព្រឹត្តអំពើអាក្រក់

បទល្មើសមជ្ឈិមដែលមានចែងនៅមាត្រា ៣១៤ (អំពើប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ) មិនត្រូវបានចាត់ទុកថាជាបទល្មើសទេ បុគ្គលណាម្នាក់បានដឹងហេតុនេះ ក្នុងឱកាសប្រកបវិជ្ជាជីវៈរបស់ខ្លួន ហើយបង្ហាញដល់អាជ្ញាធរតុលាការ រដ្ឋបាល ឬ វេជ្ជសាស្ត្រ អំពីការធ្វើបាបអនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៣១៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

២-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៣-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៥

## ការប៉ះពាល់ដល់ការសម្ងាត់នៃការឆ្លងឆ្លើយតាមលិខិត និងទូរគមនាគមន៍

**មាត្រា ៣១៧.-** អំពើប៉ះពាល់ដល់ការឆ្លើយឆ្លងតាមលិខិត

អំពើបើក បំបាត់ចោល ធ្វើឱ្យយឺតយ៉ាវ ឬបង្វែរលិខិតឆ្លើយឆ្លងដែលផ្ញើទៅតតិយជនដោយគំនិតទុច្ចរិត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ត្រូវបានផ្ដន្ទាទោសដូចគ្នា ចំពោះអំពើប្រព្រឹត្តដោយទុច្ចរិត មើលលិខិតឆ្លើយឆ្លងដែលផ្ញើទៅតតិយជន ។

**មាត្រា ៣១៨.-** អំពើប៉ះពាល់ដល់ការសម្ងាត់នៃការសន្ទនាតាមទូរស័ព្ទ

អំពើប្រព្រឹត្តដោយគំនិតទុច្ចរិត ស្ដាប់ ឬធ្វើឱ្យច្របូកច្របល់ការសន្ទនាតាមទូរស័ព្ទ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ត្រូវផ្ដន្ទាទោសដូចគ្នា ចំពោះអំពើប្រព្រឹត្តដោយទុច្ចរិត ចាប់ ឬធ្វើឱ្យច្របូកច្របល់ សារដែលផ្សាយចេញតាមផ្លូវទូរគមនាគមន៍ ឬស្ដាប់សារនេះ ។

**មាត្រា ៣១៩.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣២០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ

អាចត្រូវបានប្រកាស ៖

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់អនុវត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៣-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## គន្ថីទី ៣

## ការប៉ះពាល់ដល់អនីតិជន និងគ្រួសារ

## មាតិកាទោល

## ការប៉ះពាល់ដល់អនីតិជន និងគ្រួសារ

## ជំពូកទី ១

## អំពើបោះបង់អនីតិជន

**មាត្រា ៣២១.-** អំពើបោះបង់អនីតិជន

អំពើរបស់បុគ្គលដែលមានអំណាចថែរក្សា ដែលបោះបង់អនីតិជនអាយុតិច ជាង ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើអំពើបោះបង់បណ្ដាលឱ្យអន្តរាយដល់សុខភាព ឬសន្តិសុខ របស់អនីតិជននោះ ។

**មាត្រា ៣២២.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣២៣.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការបោះបង់គ្រួសារ

**មាត្រា ៣២៤.-** អំពើបោះបង់គ្រួសារ

ការមិនគោរពតាមសេចក្តីសម្រេចស្ថាពររបស់តុលាការ ដោយមិនព្រមបង់ក្នុងរយៈពេល ២ (ពីរ) ខែ យ៉ាងតិច នូវអាហារកាតព្វកិច្ចដល់សហព័ទ្ធ ឬអតីតសហព័ទ្ធរបស់ខ្លួន ដល់កូនជាអនីតិជន ដល់បច្ឆាញាតិ ឬដល់បុព្វញាតិ ឬញាតិផ្សេងទៀត របស់ខ្លួននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៣២៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៣
## ការប៉ះពាល់ដល់ការថែរក្សាអនីតិជន

**មាត្រា ៣២៦.-** អំពើមិនព្រមប្រគល់អនីតិជន

អំពើប្រព្រឹត្តដោយគំនិតទុច្ចរិត មិនព្រមប្រគល់កុមារជាអនីតិជនឱ្យទៅបុគ្គលដែលមានសិទ្ធិទាមទារនោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៣២៧.-** អំពើដកយកកុមារ

អំពើដកយកកុមារជាអនីតិជនដោយផ្ទុយច្បាប់ ពីបុគ្គលដែលថែរក្សាស្របច្បាប់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

បទល្មើសនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ប្រសិនបើកុមារជាអនីតិជនត្រូវបានរក្សាទុកនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣២៨.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣២៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៤
## ការប៉ះពាល់ដល់បុត្តភាព

**មាត្រា ៣៣០.-** អំពើញុះញង់ឱ្យបោះបង់កុមារ

អំពើប្រព្រឹត្តនៅក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្ដាយ ឬដល់ឪពុក ឬម្ដាយឱ្យបោះបង់ទារកដែលកើតមកហើយ ឬដែលនឹងកើត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៣៣១.-** អន្តរការសុំកូន ឬបោះបង់កូន

អំពើប្រព្រឹត្តនៅក្នុងគោលដៅចង់បានកំរៃ ធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬប្ដីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹម និងឪពុកម្ដាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលនឹងកើត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៣៣២.-** អន្តរការរវាងអ្នកសុំកូន និងស្ត្រីពរពោះ

អំពើប្រព្រឹត្តនៅក្នុងគោលបំណងចង់បានកំរៃ ធ្វើជាអន្តរការរវាងបុគ្គលម្នាក់

ឬប្ដី ប្រពន្ធ ដែលចង់សុំកូនយកមកចិញ្ចឹម និងស្ត្រីម្នាក់យល់ព្រមពរពោះ ដើម្បីនឹងប្រគល់កូន នោះឱ្យទៅអ្នកសុំ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយ លាន) រៀល ។

**មាត្រា ៣៣៣.-** អំពើជំនួស ក្លែង ឬលាក់បំបាំងអត្តិភាពនៃទារក

អំពើដែលយកទារកមួយជំនួសទារកមួយទៀត ក្លែង ឬលាក់បំបាំងអត្តិភាពនៃទារក កាលបើអំពើនេះនាំឱ្យមានការក្លែងបន្លំអត្រានុកូលដ្ឋាន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៣៣៤.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទមជ្ឈិមដែរ ។

**មាត្រា ៣៣៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៣៣៦.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើស

ដែលបញ្ញត្តិក្នុងមាត្រា ៣៣០ (អំពើញុះញង់ឱ្យបោះបង់កុមារ) មាត្រា ៣៣១ (អន្តរការសុំកូន ឬបោះបង់កូន) និងមាត្រា ៣៣២ (អន្តរការរវាងអ្នកសុំ និងស្ត្រីពរពោះ) ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ១.០០០.០០០ (មួយលាន) ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ព្រមទាំងបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

២-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៣-បិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) ។

៤-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៥-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

៦-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## ជំពូកទី ៥
## ការដាក់អនីតិជនឱ្យស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់
## ផ្នែកទី ១
## ការប៉ះពាល់ដល់សុខភាព ចិត្តសាស្ត្រ និងការអប់រំ

**មាត្រា ៣៣៧.-** អំពើបង្អត់អាហារ ឬគ្មានការថែទាំអនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ

អំពើរបស់ជនគ្រប់រូប ដែលមានអំណាចទៅលើអនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ដែលបង្អត់អាហារ ឬគ្មានការថែទាំរហូតដល់ខូចសុខភាពអនីតិជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៣៨.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមរណភាពនៃជនរងគ្រោះ

បទល្មើសដែលមានចែងនៅមាត្រា ៣៣៧ (អំពើបង្អត់អាហារ ឬគ្មានការថែទាំអនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះនាំឱ្យជនរងគ្រោះស្លាប់ ។

**មាត្រា ៣៣៩.-** អំពើដាក់អនីតិជនស្ថិតក្នុងលក្ខខណ្ឌការងារដែលបណ្តាលឱ្យខូចសុខភាព

អំពើដែលដាក់អនីតិជនឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារ បណ្តាលឱ្យខូចដល់សុខភាព ឬការលូតលាស់ដល់រាងកាយរបស់អនីតិជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៤០.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមរណភាពនៃអនីតិជន

បទល្មើសដែលមានចែងនៅក្នុងមាត្រា ៣៣៩ (អំពើដាក់អនីតិជនស្ថិតនៅក្នុងលក្ខខណ្ឌការងារដែលបណ្តាលឱ្យខូចសុខភាព) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី

៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនោះនាំឱ្យជនរងគ្រោះស្លាប់ ។

**មាត្រា ៣៤១.-** អំពើអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ

អំពើរបស់នីតិជនដែលប្រព្រឹត្តអំពើអាសទៅលើអនីតិជនអាយុតិចជាង ១៥ (ដប់ ប្រាំ) ឆ្នាំ ដោយគ្មានប្រើហិង្សា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៤២.-** ស្ថានទម្ងន់

បទល្មើសដែលមានចែងនៅមាត្រា ៣៤១ (អំពើអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើបទល្មើសនេះបានប្រព្រឹត្ត :

១-ដោយបុព្វញាតិ ។

២-ដោយបុគ្គលដែលមានអំណាចលើអនីតិជន ។

៣-ដោយបុគ្គលច្រើនរូប ដែលធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិត ។

៤-ដោយការបង់លាភការ ។

**មាត្រា ៣៤៣.-** អំពើមិនបញ្ជូនអនីតិជនឱ្យចូលរៀន

អំពើរបស់អ្នកថែរក្សាអនីតិជន ដោយបានបំពានទៅលើវិធានការជាធរមានដែលទាក់ទងដល់អាយុ និងរយៈពេលនៃការចូលរៀនរបស់អនីតិជននោះ ដែលមិនបញ្ជូនអនីតិជនចូលរៀនដោយគ្មានមូលហេតុសមស្រប ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

## ផ្នែកទី ២
## ការជម្រុញឱ្យអនីតិជនប្រព្រឹត្តអំពើខុសច្បាប់ ឬអំពើគ្រោះថ្នាក់

**មាត្រា ៣៤៤.-** អំពើញុះញង់អនីតិជនប្រើប្រាស់គ្រឿងញៀន

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៤៥.-** អំពើញុះញង់អនីតិជនឱ្យដឹកជញ្ជូន រក្សាទុក ឬផ្តល់គ្រឿងញៀន

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យដឹកជញ្ជូន រក្សាទុក ឬផ្តល់គ្រឿងញៀន ត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៤៦.-** អំពើញុះញង់អនិតិជនឱ្យបរិភោគជាប្រចាំ និងយ៉ាងច្រើននូវគ្រឿងស្រវឹង

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យបរិភោគជាប្រចាំ និងយ៉ាងច្រើននូវគ្រឿងស្រវឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ ២ (ពីរ) ឆ្នាំ និងពីន័យជាប្រាក់ ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៣៤៧.-** អំពើញុះញង់អនីតិជនឱ្យដើរសុំទាន

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យសុំទាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៣៤៨.-** អំពើញុះញង់អនីតិជនឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី

៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៤៩.-** អំពើរៀបចំបង្ហាញភេទ ឬទំនាក់ទំនងខាងផ្លូវភេទដោយមានការចូលរួមរបស់អនីតិជន

អំពើរបស់នីតិជនដែលរៀបចំការជួបជុំ ដែលរួមមាន ការបង្ហាញ ឬមានទំនាក់ទំនងខាងផ្លូវភេទ ដែលមានអនីតិជនបានមើល ឬចូលរួមផងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

## ផ្នែកទី ៣
## ការរំលោភអំណាចមេបា

**មាត្រា ៣៥០.-** អំពើរំលោភអំណាចមេបា

អំពើរបស់អ្នកមានអំណាចមេបា ឬអ្នកមានអំណាចអាណាព្យាបាល ដែលដកហូតសេរីភាពរបស់អនីតិជន ដោយរំលោភអំណាចរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល កាលបើអំពើនេះធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង ដល់សុខភាព សុវត្ថិភាព ផ្លូវចិត្ត ឬការអប់រំរបស់អនីតិជននោះ ។

## ផ្នែកទី ៤
## ការប៉ុនប៉ង និងឧសណ្ឋកម្ម

**មាត្រា ៣៥១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣៥២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៦

## ការប៉ះពាល់ផ្សេងទៀតដល់គ្រួសារ

**មាត្រា ៣៥៣.-** ទ្វេពន្ធភាព

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើដែលចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មី មុនការរំលាយអាពាហ៍ពិពាហ៍ចាស់ ។

ត្រូវផ្តន្ទាទោសដូចគ្នា មន្ត្រីអត្រានុកូលដ្ឋានដែលដឹងហេតុការណ៍នោះច្បាស់ នៅតែអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ ឬចុះបញ្ជីអាពាហ៍ពិពាហ៍នេះ មុនការរំលាយអាពាហ៍ពិពាហ៍ចាស់ ។

**មាត្រា ៣៥៤.-** ការប៉ះពាល់ខាងផ្លូវភេទដល់អនីតិជន ដោយបុព្វញាតិ

អំពើរួមភេទជាមួយអនីតិជនក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើចារីជាបុព្វញាតិរបស់អនីតិជននោះ ។

**មាត្រា ៣៥៥.-** ការប៉ះពាល់ខាងផ្លូវភេទរវាងញាតិលោហិត

អំពើរួមភេទរវាងញាតិលោហិត ឬញាតិពន្ធក្នុង ៣ (បី) ថ្នាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យ ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

## ភាគទី ៣

## បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ

## គន្ថីទី ១

## ការយកទ្រព្យសម្បត្តិគេមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត

## មាតិកាទី ១

## ការលួច និងបទល្មើសប្រហាក់ប្រហែល

## ជំពូកទី ១

## ការលួច

**មាត្រា ៣៥៦.-** និយមន័យនៃអំពើលួច

អំពើលួច គឺជាអំពើដកហូត ដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

**មាត្រា ៣៥៧.-** អំពើលួចថាមពល

ត្រូវចាត់ទុកជាអំពើលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល ដែលនាំឱ្យខូចប្រយោជន៍អ្នកដទៃ ។

**មាត្រា ៣៥៨.-** អភ័យឯកសិទ្ធិគ្រួសារ

មិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបានទេ :

១-អំពើលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ ។

២-អំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ ។

**មាត្រា ៣៥៩.-** ទោសដែលត្រូវអនុវត្ត

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៦០.-** ស្ថានទម្ងន់ដែលបណ្តាលមកពីការប្រព្រឹត្តអំពើហិង្សា

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចតទៅ :

១-អំពើលួចនេះ ប្រព្រឹត្តឡើងមុន ក្នុងពេលជាមួយ ឬបន្ទាប់ពីការប្រើហិង្សា ។

២-អំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ ។

**មាត្រា ៣៦១.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមានការកាត់អវៈយវៈ ឬពិការភាព

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុន ក្នុងពេលជាមួយ ឬបន្ទាប់ពីការប្រើហិង្សា ដែលនាំឱ្យមានការកាត់អវៈយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ។

**មាត្រា ៣៦២.-** ស្ថានទម្ងន់ដែលបណ្តាលមកពីការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះ ប្រព្រឹត្តមុន ក្នុងពេលជាមួយ ឬបន្ទាប់ពីការប្រើទារុណកម្ម ឬអំពើឃោរឃៅ ។

**មាត្រា ៣៦៣.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមរណភាពរបស់ជនរងគ្រោះ

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ប្រសិនបើអំពើនេះប្រព្រឹត្តមុន ក្នុងពេលជាមួយ ឬបន្ទាប់ពីការប្រើហិង្សា ដែលបណ្តាលឱ្យមានមរណភាព ដោយគ្មានបំណងចង់ឱ្យមានមរណភាព ។

**មាត្រា ៣៦៤.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣៦៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ហាមឃាត់ចំពោះការបើកបរយាន ទោះបីជាយានប្រភេទណាក៏ដោយ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសនូវវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៨-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងផ្ទះដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬប្រព្រឹត្តបទល្មើសជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់សាធារណជន ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការកំហែងយក

**មាត្រា ៣៦៦.-** អំពើកំហែងយក

អំពើកំហែងយក គឺជាអំពើដែលប្រព្រឹត្តដោយប្រើហិង្សា គំរាមកំហែងថានឹងប្រើហិង្សា ឬការបង្ខិតបង្ខំ ដើម្បីទទួលបាននូវ :

១-ហត្ថលេខា ។

២-ការសន្យា ឬការបោះបង់ចោលអ្វីមួយ ។

៣-ការបង្ហាញអាថ៌កំបាំងណាមួយ ។

៤-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

**មាត្រា ៣៦៧.-** ទោសដែលត្រូវអនុវត្ត

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៦៨.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនរងគ្រោះ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះបានប្រព្រឹត្តទៅលើ :

១-បុគ្គលណាម្នាក់ជាពិសេសដែលទន់ខ្សោយដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬដែលជនល្មើសបានដឹង ។

៣-បុគ្គលដែលជាពិសេសទន់ខ្សោយដោយមូលហេតុនៃជម្ងឺ ឬភាពពិការ កាលបើស្ថានភាពបុគ្គលនេះ ត្រូវបានគេឃើញជាក់ស្តែង ឬដែលជនល្មើសបានដឹង ។

**មាត្រា ៣៦៩.-** ស្ថានទម្ងន់ដោយសារការប្រើប្រាស់អាវុធ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះ បានប្រព្រឹត្តដោយមានការប្រើប្រាស់ ឬដោយការគំរាមកំហែងនឹងអាវុធ ។

**មាត្រា ៣៧០.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមានការកាត់អវៈយវៈ ឬពិការភាព

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុន ក្នុងពេលជាមួយ ឬបន្ទាប់ពីការប្រើហិង្សាដែលនាំឱ្យមានការកាត់អវៈយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ។

**មាត្រា ៣៧១.-** ស្ថានទម្ងន់ដោយមានការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុន ក្នុងពេលជាមួយ ឬបន្ទាប់ពីការប្រើទារុណកម្ម ឬអំពើឃោរឃៅ ។

**មាត្រា ៣៧២.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមរណភាពរបស់ជនរងគ្រោះ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តឡើងមុន ក្នុងពេលជាមួយ ឬបន្ទាប់ពីការប្រើហិង្សាដែលបណ្តាលឱ្យស្លាប់ ដោយគ្មានបំណងចង់ឱ្យជនរងគ្រោះស្លាប់ទេ ។

**មាត្រា ៣៧៣.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោស

ដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣៧៤.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសនូវវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៧-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងផ្ទះដែលបទល្មើសនោះបានប្រព្រឹត្ត ។

៩-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១១-ការបិទផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១២-ការផ្សាយសេចក្ដីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៣-ការផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៣
## ការគំរាមកំហែងហែកកេរ្តិ៍

**មាត្រា ៣៧៥.-** អំពើគំរាមកំហែងហែកកេរ្តិ៍

អំពើគំរាមកំហែងហែកកេរ្តិ៍ គឺជាអំពើប្រព្រឹត្តដោយគំរាមកំហែងបើកកកាយ ឬទម្លាក់កំហុសទៅលើអំពើដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬការរាប់អាន ដើម្បីទទួលបាននូវ :

១-ហត្ថលេខា ។

២-ការសន្យា ឬការបោះបង់ចោលអ្វីមួយ ។

៣-ការបង្ហាញអាថ៌កំបាំងណាមួយ ។

៤-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

**មាត្រា ៣៧៦.-** ទោសដែលត្រូវអនុវត្ត

អំពើគំរាមកំហែងហែកកេរ្តិ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៧៧.-** ស្ថានទម្ងន់ដោយផ្អែកលើការអនុវត្តជាក់ស្ដែងនូវការគំរាមកំហែង

កាលបើអំពើគំរាមកំហែងហែកកេរ្តិ៍ ឬការទម្លាក់កំហុសដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬការរាប់អាន ត្រូវបានស្ដែងចេញជាអំពើជាក់ស្ដែង ចារីត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៣៧៨.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣៧៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសនូវវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៧-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងផ្ទះដែលបទល្មើសនោះបានប្រព្រឹត្ត ។

៩-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ២

## ការឆបោក និងអំពើប្រហាក់ប្រហែល

## ជំពូកទី ១

## ការឆបោក

**មាត្រា ៣៨០.-** អំពើឆបោក

អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវ :

១-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

២-ការផ្តត់ផ្គង់សេវា ។

៣-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច ។

**មាត្រា ៣៨១.-** ទោសដែលត្រូវអនុវត្ត

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៨២.-** ស្ថានទម្ងន់ដែលទាក់ទងទៅនឹងជនរងគ្រោះ

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ :

១-បុគ្គលណាម្នាក់ដែលជាពិសេសទន់ខ្សោយដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬដែលជនល្មើសបានដឹង ។

៣-បុគ្គលដែលជាពិសេសទន់ខ្សោយដោយមូលហេតុនៃជម្ងឺ ឬភាពពិការ កាលបើស្ថានភាពបុគ្គលនោះ ត្រូវបានគេឃើញជាក់ស្តែង ឬដែលជនល្មើសបានដឹង ។

**មាត្រា ៣៨៣.-** ស្ថានទម្ងន់ផ្សេងទៀត

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្ត :

១-ដោយអ្នករាជការសាធារណៈ ស៊ីវិល ឬយោធា នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

២-ដោយបុគ្គលដែលតាំងខ្លួនជាអ្នករាជការសាធារណៈ ។

៣-ដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណជន ដើម្បីបោះពុម្ពចេញឱ្យប្រើប្រាស់នូវមូលប័ត្រ ។

៤-ដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណជន ដើម្បីអង្គាសមូលនិធិសម្រាប់ជាជំនួយមនុស្សធម៌ ឬសង្គមកិច្ច ។

៥-ជាក្រុមមានការចាត់តាំង ។

**មាត្រា ៣៨៤.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣៨៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសនូវវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៧-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងផ្ទះដែលបទល្មើសនោះបានប្រព្រឹត្ត ។

៩-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១១-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១២-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៣-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## បទល្មើសប្រហាក់ប្រហែលនៃការឆបោក
### ផ្នែកទី ១
### ការទាញយកប្រយោជន៍ដោយរំលោភលើភាពទន់ខ្សោយ

**មាត្រា ៣៨៦.-** អំពើទាញយកប្រយោជន៍ដោយរំលោភលើភាពទន់ខ្សោយ

អំពើទាញយកប្រយោជន៍ដោយចេតនាដោយរំលោភលើភាពល្ងង់ខ្លៅ ឬភាពទន់ខ្សោយនៃបុគ្គលនេះ ពីស្ថានភាពមានគភ៌ ជម្ងឺ ឬពិការភាព ដោយបង្ខំបុគ្គលនេះឱ្យប្រព្រឹត្តអំពើ ឬមិនប្រព្រឹត្តអំពើដែលធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់បុគ្គលនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

### ផ្នែកទី ២
### ការបន្លំ

**មាត្រា ៣៨៧.-** អំពើបន្លំ

អំពើបន្លំ គឺជាអំពើរបស់បុគ្គលដែលដឹងខ្លួនថាគ្មានលទ្ធភាពដាច់ខាតនឹងបង់ថ្លៃ ឬដែលសម្រេចចិត្តមិនបង់ថ្លៃ ៖

១-ឱ្យគេបម្រើម្ហូបអាហារ ឬភេសជ្ជៈនៅក្នុងរង្គសាល ភោជនីយដ្ឋាន ឬនៅក្នុងគ្រឹះស្ថានដទៃទៀត ដែលបើកចំហសម្រាប់សាធារណជន ។

២-ឱ្យគេប្រគល់បន្ទប់មួយ និងកាន់កាប់បន្ទប់នេះនៅក្នុងសណ្ឋាគារ ឬគ្រឹះស្ថានដទៃទៀត ដែលបើកចំហសម្រាប់សាធារណជន ។

៣-ឱ្យគេដឹកជញ្ជូនខ្លួនតាមត្រីចក្រយាន តាមរថយន្តឈ្នួល ឬតាមមធ្យោបាយដឹកជញ្ជូនផ្សេងទៀត ។

អំពើបន្ទំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ៣៨៨.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣៨៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងផ្នែកនេះ ទោសបន្ថែមដូច តទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៣
## ការប៉ះពាល់ដល់សេរីភាពនៃការលក់ដេញថ្លៃ

**មាត្រា ៣៩០.-** អំពើដេញថ្លៃមិនត្រឹមត្រូវ

អំពើប្រព្រឹត្ត នៅក្នុងការលក់ជាសាធារណៈ តាមការដេញថ្លៃ ដើម្បីកំចាត់អ្នកដេញថ្លៃ ឬធ្វើឱ្យខូចការចេញថ្លៃដោយអំណោយ ការសន្យា ការព្រមព្រៀង ឬតាមគ្រប់មធ្យោបាយទុច្ចរិតដទៃទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៣៩១.-** អំពើជាឧបសគ្គដល់សេរីភាពនៃការលក់ដេញថ្លៃ

អំពើប្រព្រឹត្ត នៅក្នុងការលក់ជាសាធារណៈតាមការដេញថ្លៃ ដើម្បីធ្វើជាឧបសគ្គដល់សេរីភាពនៃការដេញថ្លៃ ដោយប្រើហិង្សា ឬដោយការគំរាមកំហែង ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៩២.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣៩៣.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិមដែលមានចែងនៅក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣- ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៥-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ៣

## ការរំលោភលើទំនុកចិត្ត និងអំពើប្រហាក់ប្រហែល

## ជំពូកទី ១

## ការរំលោភលើទំនុកចិត្ត

**មាត្រា ៣៩៤.-** អំពើរំលោភលើទំនុកចិត្ត

អំពើរំលោភលើទំនុកចិត្ត គឺជាអំពើគៃបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះ បានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយក មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់ ។

**មាត្រា ៣៩៥.-** ទោសដែលត្រូវអនុវត្ត

អំពើរំលោភលើទំនុកចិត្ត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៩៦.-** ការរំលោភទំនុកចិត្តពិសេស ដោយអភិបាល ឬបុគ្គលផ្សេងទៀត

គ្រប់អភិបាល ឬអ្នកត្រួតពិនិត្យរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលមូលនិធិ ឬបុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឱ្យធ្វើជំនួស

នូវកិច្ចការរបស់អ្នកទាំងនេះ ឬនិយោជិតដែលទទួលអាណត្តិពីនីតិបុគ្គល ដែលប្រព្រឹត្ត អំពើណាមួយដែលជាការរំលោភទំនុកចិត្ត ក្នុងគោលបំណងទទួលផលប្រយោជន៍ ដល់ខ្លួន ឬតតិយជន ឬក្នុងគោលបំណងធ្វើឱ្យខូចខាតដល់នីតិបុគ្គល ហើយបាន បណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកជម្រះបញ្ជីរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលមូលនិធិ ឬបុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឱ្យធ្វើជំនួសនូវកិច្ចការ របស់អ្នកជម្រះបញ្ជី បានប្រព្រឹត្តអំពើដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយបានបណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ។

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ នឹងត្រូវផ្តន្ទាទោសដូចគ្នាដែរ ។

**មាត្រា ៣៩៧.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនល្មើស

អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើបទល្មើសនេះបានប្រព្រឹត្តឡើង ៖

១-ដោយបុគ្គលណាម្នាក់ដែលបានធ្វើការអំពាវនាវដល់សាធារណជន ដើម្បី ទទួលបានមូលនិធិ ឬតម្លៃសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន ឬជាផលប្រយោជន៍របស់ សហគ្រាសឧស្សាហកម្ម ពាណិជ្ជកម្ម ។

២-ដោយអាណត្តិគាហករបស់តុលាការ ឬអ្នកជំនួយរបស់តុលាការនៅក្នុង ក្របខ័ណ្ឌ នៃមុខងាររបស់ខ្លួន ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

៣-ដោយអ្នករាជការសាធារណៈ ស៊ីវិល ឬយោធា នៅក្នុងក្របខ័ណ្ឌនៃ មុខងាររបស់ខ្លួន ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ៣៩៨.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៣៩៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសនូវវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៥-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងផ្ទះដែលបទល្មើសនោះបានប្រព្រឹត្ត ។

៧-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការបង្វែរវត្ថុរឹបអូស ឬដែលដាក់ធានា

**មាត្រា ៤០០.-** អំពើបង្វែរវត្ថុរឹបអូស ឬដែលដាក់ធានា

អំពើរបស់កូនបំណុលដែលគៃបំបាត់ ឬបំផ្លាញវត្ថុដែលបានឃាត់ទុក រឹបអូស ដោយអាជ្ញាធរមាននីតិសម្បទា ឬដាក់ដើម្បីធានានូវសិទ្ធិលើបំណុល ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៤០១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

## មាតិកាទី ៤
## បទល្មើសបំពេញបន្ថែម
## ជំពូកទី ១
## ការទទួលផលចោរកម្ម

**មាត្រា ៤០២.-** អំពើទទួលផលចោរកម្ម

អំពើទទួលផលចោរកម្ម គឺជាអំពើទទួលលាក់បំបាំង រក្សាទុក ឬជញ្ជូនរបស់ អ្វីមួយ ដោយដឹងថារបស់នោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

ត្រូវចាត់ទុកជាអំពើទទួលផលចោរកម្មផងដែរ :

១-អំពើធ្វើជាអន្តរការី ដើម្បីបញ្ជូនរបស់អ្វីមួយ ដោយដឹងថារបស់នោះបាន មកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

២-អំពើដែលបានទទួលកំរៃពីផលនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយបានដឹង ហេតុការណ៍ច្បាស់ ។

**មាត្រា ៤០៣.-** ទោសដែលត្រូវអនុវត្ត

អំពើទទួលផលចោរកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥

(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤០៤.-** ស្ថានទម្ងន់

អំពើទទួលផលចោរកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តឡើង ៖

១-ជាទម្លាប់ ។

២-ដោយប្រើប្រាស់ភាពងាយស្រួល ដែលការប្រកបសកម្មភាពវិជ្ជាជីវៈផ្តល់ឱ្យ ។

៣-ជាក្រុមមានការចាត់តាំង ។

**មាត្រា ៤០៥.-** អតិបរមានៃទោសពិន័យ

អតិបរមានៃទោសពិន័យ អាចត្រូវស្មើនឹងតម្លៃនៃទ្រព្យសម្បត្តិនៃអំពើទទួលផលចោរកម្ម ។

**មាត្រា ៤០៦.-** ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ហាមឃាត់ចំពោះការបើកបរយាន ទោះបីជាយានប្រភេទណាក៏ដោយ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសនូវវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៨-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងផ្ទះដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬប្រព្រឹត្តបទល្មើសជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់សាធារណជន ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

# ជំពូកទី ២
# ការសំអាតប្រាក់កខ្វក់

**មាត្រា ៤០៧.-** និយមន័យនៃការសំអាតប្រាក់កខ្វក់

ការសំអាតប្រាក់កខ្វក់ ជាអំពើផ្ដល់ឱ្យតាមគ្រប់មធ្យោបាយនូវយុត្តិកម្មកុហក ដើម្បីលាក់បំបាំងអត្ថប្រយោជន៍ផ្ទាល់ ឬប្រយោលនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

ត្រូវចាត់ជាការសំអាតប្រាក់កខ្វក់ផងដែរ គឺអំពើជួយដល់ប្រតិបត្តិការនៃការបណ្ដាក់ទុន ការលាក់បំបាំង ឬការផ្លាស់ប្ដូរផលិតផលផ្ទាល់ ឬប្រយោលនៃបទឧក្រិដ្ឋ ឬបទ មជ្ឈិម ។

**មាត្រា ៤០៨.-** ទោសដែលត្រូវអនុវត្ត

ការសំអាតប្រាក់កខ្វក់ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល រហូតស្មើនឹងតម្លៃមូលនិធិ តម្លៃ ទ្រព្យសម្បត្តិដែលជាគោលដៅនៃការសំអាតប្រាក់កខ្វក់ ។

ក្នុងករណីដែលបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិ ឬមូលនិធិដែលជាគោលដៅនៃការសំអាតប្រាក់កខ្វក់ ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារធ្ងន់ជាងទោសដាក់ពន្ធនាគារដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ នោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារដូចបទល្មើសដែលចារីបានដឹង ហើយបើករណី បទល្មើសមានភ្ជាប់មកជាមួយនូវស្ថានទម្ងន់ទោសច្រើន នោះចារីត្រូវទទួលទណ្ឌកម្ម ដោយយោងទៅតាមស្ថានទម្ងន់ទោសដែលខ្លួនបានដឹងប៉ុណ្ណោះ ។

**មាត្រា ៤០៩.-** ស្ថានទម្ងន់

ការសំអាតប្រាក់កខ្វក់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្ត ៖

១-ជាទម្លាប់ ។

២-ដោយប្រើភាពងាយស្រួល ដែលការប្រកបនូវសកម្មភាពវិជ្ជាជីវៈផ្ដល់ឱ្យ ។

៣-ជាក្រុមមានការចាត់តាំង ។

**មាត្រា ៤១០.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោស ដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៤១១.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសនូវវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៥-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងផ្ទះដែលបទល្មើស នោះបានប្រព្រឹត្ត ។

៧-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៤១២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមាន

ចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើស ដែលបញ្ញត្តិក្នុងមាត្រា ៤០៧ (និយមន័យនៃការសំអាតប្រាក់កខ្វក់) ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ១០០.០០០.០០០ (មួយរយលាន) ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្តេញចេញពីអាបណសញ្ញា តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) ។

៦-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៨-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

៩-ចុះផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## គន្ថីទី ២

## ការប៉ះពាល់ដល់ទ្រព្យសម្បត្តិ

## មាតិកាទី ១

## ការបំផ្លិចបំផ្លាញ ការធ្វើឱ្យទ្រុឌទ្រោម និងការធ្វើឱ្យខូចខាត

## ជំពូកទី ១

## ការបំផ្លិចបំផ្លាញ ការធ្វើឱ្យទ្រុឌទ្រោម និងការធ្វើឱ្យខូចខាត

**មាត្រា ៤១៣.-** អំពើធ្វើឱ្យខូចខាតដោយចេតនា

អំពើប្រព្រឹត្តដោយចេតនា ដោយបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃនោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល លើកលែងតែការអន្តរាយមានលក្ខណៈស្រាល ។

**មាត្រា ៤១៤.-** ស្ថានទម្ងន់

បទល្មើសដែលមានចែងនៅក្នុងមាត្រា ៤១៣ (អំពើធ្វើឱ្យខូចខាតដោយចេតនា) ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល នៅក្នុងករណីដូចតទៅ :

១-កាលបើបទល្មើសនេះបានប្រព្រឹត្តដោយបុគ្គលច្រើនរូបធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិត ។

២-កាលបើបទល្មើសនេះ បានប្រព្រឹត្តនៅក្នុងទីកន្លែងជាលំនៅឋាន ។

៣-កាលបើបទល្មើសនេះ បានប្រព្រឹត្តនៅក្នុងទីកន្លែង សម្រាប់តម្កល់មូលនិធិ តម្លៃ ទំនិញ ឬសម្ភារៈ ។

៤-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ដល់សំណង់គ្រឹះស្ថានសាធារណៈ ឬផ្លូវសាធារណៈ ។

៥-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ដល់ផលដំណាំ ឬកសិផល ។

**មាត្រា ៤១៥.-** ស្ថានទម្ងន់ដែលទាក់ទងទៅនឹងជនរងគ្រោះ

បទល្មើសដែលមានចែងក្នុងមាត្រា ៤១៣ (អំពើធ្វើឱ្យខូចខាតដោយចេតនា) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល នៅក្នុងករណីដូចតទៅ :

១-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ របស់ចៅក្រម អ្នករាជការសាធារណៈ ឬមេធាវី ដើម្បីជះឥទ្ធិពលលើគំនិតមារយាទ នៅក្នុងការបំពេញមុខងាររបស់ខ្លួន ។

២-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឃាត់កុំឱ្យប្តឹងពីបទល្មើស ឬសុំធ្វើការជួសជុលការខូចខាត ។

៣-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍របស់សាក្សី ដើម្បីឃាត់កុំឱ្យផ្តល់ភស្តុតាងក្នុងពេលស៊ើបអង្កេត ក្នុងពេលស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃ បណ្តឹងផ្សេងទៀត ឬដើម្បីធ្វើឱ្យមានឥទ្ធិពលទៅលើសាក្ខីកម្មនេះ ។

៤-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះបុគ្គលនេះបានប្តឹងពីបទល្មើស ឬបានសុំឱ្យធ្វើការជួសជុលនូវការខូចខាត ។

៥-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍របស់សាក្សី ដោយមូលហេតុភស្តុតាង ដែលសាក្សីនេះបានផ្តល់នៅក្នុងពេលស៊ើបអង្កេត ពេលស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ៤១៦.-** ស្ថានទម្ងន់ដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល

អំពើប្រព្រឹត្តដោយចេតនា ដើម្បីបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាត ឬធ្វើឱ្យទ្រុឌទ្រោម

ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ដោយអានុភាពនៃគ្រឿងផ្ទុះ នៃអគ្គីភ័យ ឬគ្រប់វិធីដទៃទៀត ដែលអាចនាំឱ្យគ្រោះថ្នាក់ដល់បុគ្គល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤១៧.-** ស្ថានទម្ងន់ដែលបណ្តាលមកពីការបង្ករបួសស្នាមដល់អ្នកដទៃ

បទល្មើសដែលបញ្ញត្តិដោយមាត្រា ៤១៦ (ស្ថានទម្ងន់ដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះបង្កឱ្យមានរបួសដល់អ្នកដទៃ ។

**មាត្រា ៤១៨.-** ស្ថានទម្ងន់ដែលបណ្តាលមកពីការកាត់អវៈយវៈ ឬពិការភាព

បទល្មើសដែលបញ្ញត្តិដោយមាត្រា ៤១៦ (ស្ថានទម្ងន់ដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវៈយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ។

**មាត្រា ៤១៩.-** ស្ថានទម្ងន់ដោយសារការប្រព្រឹត្តបទល្មើសដោយមានការចាត់តាំង

បទល្មើសដែលមានចែងនៅក្នុងមាត្រា ៤១៦ (ស្ថានទម្ងន់ដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តឡើងជាក្រុមមានការចាត់តាំង ។

**មាត្រា ៤២០.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមរណភាពរបស់អ្នកដទៃ

បទល្មើសដែលមានចែងនៅក្នុងមាត្រា ៤១៦ (ស្ថានទម្ងន់ដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ បណ្តាលឱ្យមានមរណភាព ដោយគ្មានចេតនានឹងឱ្យជនរងគ្រោះទទួលមរណភាពទេ ។

**មាត្រា ៤២១.-** អំពើធ្វើឱ្យមានការខូចខាតស្រាល

អំពើប្រព្រឹត្តដោយចេតនា ដើម្បីបំផ្លាញ ធ្វើឱ្យខូចខាត ឬធ្វើឱ្យទ្រុឌទ្រោមទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ប្រសិនបើការខូចខាតមានលក្ខណៈស្រាល ។

បទប្បញ្ញត្តិនៃមាត្រានេះ មិនត្រូវអនុវត្តទៅលើទ្រព្យសម្បត្តិវប្បធម៌សាធារណៈ ឬឯកជន ដែលជាផ្នែកនៃបេតិកភ័ណ្ឌជាតិរបស់ព្រះរាជាណាចក្រកម្ពុជាទេ ។

**មាត្រា ៤២២.-** អំពើធ្វើឱ្យខូចខាតផ្សេងទៀត ដោយការខ្វះការប្រុងប្រយ័ត្ន ឬការមិនគោរពបទបញ្ជា

អំពើបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាត ឬធ្វើឱ្យទ្រុឌទ្រោមទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃដោយអានុភាពនៃគ្រឿងផ្ទុះ ឬអគ្គីភ័យ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល កាលបើអំពើនេះ បណ្តាលមកពី :

១-ការមិនប្រុងប្រយ័ត្ន ការមិនយកចិត្តទុកដាក់ ឬការធ្វេសប្រហែស ។

២-ការរំលោភបំពានលើកាតព្វកិច្ច សន្តិសុខ ឬការប្រុងប្រយ័ត្នដែលច្បាប់បានតម្រូវ ។

**មាត្រា ៤២៣.-** អំពើធ្វើឱ្យខូចខាតប័ណ្ណប្រកាស ឬសេចក្តីជូនដំណឹងជាផ្លូវការ

អំពើប្រព្រឹត្តដោយចេតនាដោយបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាត ឬធ្វើឱ្យទ្រុឌទ្រោមប័ណ្ណប្រកាស ឬសេចក្តីជូនដំណឹងជាផ្លូវការរបស់រដ្ឋបាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៤២៤.-** ការប៉ុនប៉ង

លើកលែងតែបទល្មើសកំណត់ក្នុងមាត្រា ៤២២ (អំពើធ្វើឱ្យខូចខាតផ្សេងទៀត

ដោយការខ្វះការប្រុងប្រយ័ត្ន ឬការមិនគោរពបទបញ្ញា) ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៤២៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ហាមឃាត់ចំពោះការបើកបរយាន ទោះបីជាយានប្រភេទណាក៏ដោយ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសនូវវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៨-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងផ្ទះដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬប្រព្រឹត្តបទល្មើសជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់សាធារណជន ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២

## ការគំរាមកំហែងថានឹងធ្វើការបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាត ឬធ្វើឱ្យទ្រុឌទ្រោម

**មាត្រា ៤២៦.-** អំពើគំរាមកំហែងថានឹងធ្វើឱ្យខូចខាត

អំពើគំរាមកំហែងថានឹងប្រព្រឹត្តនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូចខាត ឬការធ្វើឱ្យទ្រុឌទ្រោម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ប្រសិនបើការគំរាមកំហែងនេះបានធ្វើម្តងហើយម្តងទៀត ឬដោយបានស្តែងចេញតាមលិខិត តាមរូបភាព ឬវត្ថុដទៃទៀត ។

ក្នុងករណីដែលទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃអំពើគំរាមកំហែងនឹងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាត ធ្វើឱ្យទ្រុឌទ្រោម មានតម្លៃតិចតួច ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៤២៧.-** អំពើគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ

អំពើគំរាមកំហែង តាមមធ្យោបាយណាក៏ដោយ ថានឹងប្រព្រឹត្តនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូចខាត ឬការធ្វើឱ្យទ្រុឌទ្រោម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ប្រសិនបើការគំរាមកំហែងនេះមាន បញ្ជាឱ្យបំពេញ ឬមិនបំពេញកិច្ចអ្វីមួយ ។

**មាត្រា ៤២៨.-** អំពើក្លែងព័ត៌មាន

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល អំពើផ្តល់ ឬបើកកកាយព័ត៌មានក្លែងដើម្បីធ្វើឱ្យជឿថា នឹងកើតមានឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូចខាត ឬការធ្វើឱ្យទ្រុឌទ្រោម ប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស ។

**មាត្រា ៤២៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងមាតិកានេះ ទោសបន្ថែម ដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ហាមឃាត់ចំពោះការបើកបរយាន ទោះបីជាយានប្រភេទណាក៏ដោយ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសនូវវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៨-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងផ្ទះដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬប្រព្រឹត្តបទល្មើសជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់សាធារណជន ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

# មាតិកាទី ២
# បទល្មើសប៉ះពាល់ដល់ទ្រព្យសម្បត្តិផ្សេងទៀត
## ជំពូកទី ១
## បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា

**មាត្រា ៤៣០.-** អំពើចូលទៅដល់ ឬនៅនឹងប្រព័ន្ធនៃប្រព្រឹត្តិកម្មជាស្វ័យប្រវត្តិនៃទិន្នន័យ

អំពើចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធនៃប្រព្រឹត្តិកម្មជាស្វ័យប្រវត្តិនៃទិន្នន័យដោយទុច្ចរិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

កាលបើអំពើនោះជាហេតុបណ្តាលឱ្យមានការលុបបំបាត់ ឬកែប្រែទិន្នន័យដែលមាននៅក្នុងប្រព័ន្ធ ឬឱ្យមានការខូចខាតនូវដំណើរការនៃប្រព័ន្ធ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៤៣១.-** អំពើបង្អើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មជាស្វ័យប្រវត្តិនៃទិន្នន័យ

អំពើបង្អើតជាឧបសគ្គ ធ្វើឱ្យខូចដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មជាស្វ័យប្រវត្តិនៃទិន្នន័យ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៤៣២.-** អំពើបញ្ចូល លុបបំបាត់ ឬកែប្រែដោយទុច្ចរិតនូវទិន្នន័យ

អំពើបញ្ចូល លុបបំបាត់ ឬកែប្រែដោយទុច្ចរិតនូវទិន្នន័យទៅក្នុងប្រព័ន្ធនៃប្រព្រឹត្តិកម្មជាស្វ័យប្រវត្តិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ)

ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៤៣៣.-** អំពើចូលរួមទៅក្នុងក្រុមប្រមូលផ្តុំ ឬក្នុងការព្រមព្រៀង ដើម្បីរៀបចំប្រព្រឹត្តបទល្មើស

អំពើចូលរួមទៅក្នុងក្រុមប្រមូលផ្តុំ ឬទៅក្នុងសន្ធិដ្ឋភាព ដែលបង្កើតឡើងដើម្បីរៀបចំប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៤៣៤.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៤៣៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសនូវវត្ថុ ឬមូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៥-ការរឹបអូសនូវផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសឧបភោគភ័ណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងផ្ទះដែលបទល្មើសនោះបានប្រព្រឹត្ត ។

៧-ការរឹបអូសនូវយានរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## បទល្មើសប្រឆាំងនឹងសត្វ

**មាត្រា ៤៣៦.-** អំពើធ្វើទុក្ខបុកម្នេញ ឬប្រព្រឹត្តអំពើឃោរឃៅចំពោះបសុសត្វដែលផ្សាំង ឬដែលដាក់ក្នុងទ្រុង

អំពើជាសាធារណៈ ឬមិនមែនជាសាធារណៈ ដែលធ្វើទុក្ខបុកម្នេញដ៏ធ្ងន់ធ្ងរ ឬប្រព្រឹត្តអំពើឃោរឃៅចំពោះបសុសត្វ សត្វដែលផ្សាំង ឬដែលជាប់ក្នុងទ្រុង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៤៣៧.-** អំពើធ្វើបាបបសុសត្វ សត្វដែលផ្សាំង ឬដាក់ក្នុងទ្រុង

អំពើគ្មានការចាំបាច់ជាសាធារណៈ ឬមិនមែនជាសាធារណៈប្រព្រឹត្តដោយចេតនាធ្វើបាបលើបសុសត្វ សត្វដែលផ្សាំង ឬជាប់ក្នុងទ្រុង ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៤៣៨.~** អំពើសម្លាប់បសុសត្វ សត្វដែលផ្សាំង ឬដាក់ក្នុងទ្រុងដោយគ្មានការចាំបាច់

អំពើគ្មានការចាំបាច់ជាសាធារណៈ ឬមិនមែនជាសាធារណៈ សម្លាប់បសុសត្វ សត្វដែលផ្សាំង ឬជាប់ក្នុងទ្រុង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៤៣៩.~** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសសម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

# ភាគទី ៤
# បទល្មើសប្រឆាំងនឹងប្រជាជាតិ
## គន្ថីទី ១
## ការប៉ះពាល់ដល់ស្ថាប័នចម្បងរបស់រដ្ឋ
### មាតិកាទី ១
### ការប៉ះពាល់ដល់ព្រះមហាក្សត្រ
### ជំពូកទី ១
### រាជឃាតកម្ម និងអំពើរំលោភបំពានចំពោះព្រះមហាក្សត្រ

**មាត្រា ៤៤០.-** រាជឃាតកម្ម

រាជឃាតកម្ម គឺជាឃាតកម្មលើព្រះមហាក្សត្រ ។

រាជឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៤៤១.-** ទារុណកម្ម ឬអំពើឃោរឃៅចំពោះព្រះមហាក្សត្រ

ទារុណកម្ម ឬអំពើឃោរឃៅចំពោះព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ៤៤២.-** អំពើហិង្សាចំពោះព្រះមហាក្សត្រ

អំពើហិង្សាប្រព្រឹត្តដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៤៤៣.-** ស្ថានទម្ងន់ដែលបណ្តាលមកពីការកាត់អវៈយវៈ ឬពិការភាព

អំពើហិង្សាប្រព្រឹត្តដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវៈយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ដល់ព្រះមហាក្សត្រ ។

**មាត្រា ៤៤៤.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមរណភាព

អំពើហិង្សាប្រព្រឹត្តដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ)

ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានមរណភាព ដោយគ្មានចេតនានឹងធ្វើឱ្យមានមរណភាពទេ ។

## ជំពូកទី ២
## ការប្រមាថចំពោះព្រះមហាក្សត្រ

**មាត្រា ៤៤៥.-** អំពើប្រមាថចំពោះព្រះមហាក្សត្រ

អំពើប្រមាថចំពោះព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើប្រមាថនេះ បានប្រព្រឹត្តឡើង :

១-ដោយសំដី តាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីកន្លែងសាធារណៈ ឬនៅក្នុងពេលប្រជុំជាសាធារណៈ ។

២-ដោយសំណេរ ឬគំនូរ តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយនៅក្នុងសាធារណជន ឬដាក់ឱ្យសាធារណជនមើល ។

**មាត្រា ៤៤៦.-** អំពើប្រមាថដែលប្រព្រឹត្តតាមផ្លូវសារព័ត៌មាន

អំពើប្រមាថដែលប្រព្រឹត្តតាមផ្លូវសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។

**មាត្រា ៤៤៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងមាតិកានេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមចំពោះការប្រកបវិជ្ជាជីវៈ កាលបើអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងនៅក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេស ចំពោះការចូលមក ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៨-ការបិទផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្ដីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ២
## ការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ
### ជំពូកទី ១
### អំពើក្បត់ជាតិ និងចារកម្ម

**មាត្រា ៤៤៨.-** អំពើក្បត់ និងចារកម្ម

បទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ជាអំពើក្បត់ជាតិ កាលបើបទល្មើសបានប្រព្រឹត្តដោយពលរដ្ឋខ្មែរ ឬដោយយោធិនខ្មែរ និងជាបទចារកម្ម កាលបើបទល្មើសនេះបានប្រព្រឹត្តដោយបុគ្គលដទៃទៀត ។

**មាត្រា ៤៤៩.-** អំពើប្រគល់ឱ្យរដ្ឋបរទេស នូវដែនដីជាតិទាំងស្រុង ឬមួយផ្នែក

អំពើប្រគល់ឱ្យរដ្ឋបរទេស ឬភ្នាក់ងារបរទេស នូវដែនដីជាតិទាំងស្រុង ឬមួយផ្នែក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៤៥០.-** អំពើប្រគល់ឱ្យរដ្ឋបរទេសនូវកងទ័ពជាតិកម្ពុជា

អំពើប្រគល់ឱ្យរដ្ឋបរទេស ឬភ្នាក់ងារបរទេស នូវកងទ័ពជាតិកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៤៥១.-** អំពើប្រគល់ឱ្យរដ្ឋបរទេស នូវសម្ភារៈ ជាអាទិ៍សម្រាប់ការការពារជាតិ

អំពើប្រគល់ឱ្យរដ្ឋបរទេស ឬភ្នាក់ងារបរទេស នូវសម្ភារៈសំណង់ បរិក្ខារ ឋបនីយភ័ណ្ឌ ឬគ្រឿងយន្តដែលសម្រាប់ការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៥២.-** ចារកម្ម

អំពើត្រូវរ៉ូវគ្នាដោយសម្ងាត់ជាមួយរដ្ឋបរទេស ឬភ្នាក់ងារបរទេស ដើម្បីបង្កើតឱ្យមានប្រទូសរ៉ាយ ឬឱ្យមានអំពើឈ្លានពានប្រឆាំងនឹងប្រទេសកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៥៣.-** អំពើប្រគល់ឱ្យរដ្ឋបរទេសនូវមធ្យោបាយធ្វើការប្រទូសរ៉ាយ ឬឈ្លានពាន

អំពើប្រគល់ឱ្យរដ្ឋបរទេស ឬភ្នាក់ងារបរទេស នូវមធ្យោបាយសម្រាប់ធ្វើការប្រទូសរ៉ាយ ឬឈ្លានពានប្រឆាំងនឹងប្រទេសកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៥៤.-** អំពើប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មាន ជាអាទិ៍ ដែលអាចធ្វើឱ្យអន្តរាយដល់ការការពារជាតិ

អំពើប្រគល់ ឬធ្វើឱ្យងាយស្រួលធ្លាក់ដល់ដៃរដ្ឋបរទេស ឬភ្នាក់ងារបរទេស នូវព័ត៌មាន វិធី វត្ថុ ឯកសារ ទិន្នន័យ ព័ត៌មានវិទ្យា ឬសលាកប័ត្រ ដែលអាចធ្វើឱ្យអន្តរាយដល់ការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៤៥៥.-** អំពើប្រមូលផ្ដុំនូវព័ត៌មាន ជាអាទិ៍ ដែលអាចធ្វើឱ្យអន្តរាយដល់ការការពារជាតិ

អំពើទទួល ឬប្រមូលផ្ដុំដើម្បីផ្ដល់អំណាចទៅឱ្យរដ្ឋបរទេស ឬភ្នាក់ងារបរទេស នូវព័ត៌មាន វិធី វត្ថុ ឯកសារ ទិន្នន័យ ព័ត៌មានវិទ្យា ឬសលាកប័ត្រ ដែលអាចធ្វើឱ្យអន្តរាយដល់ការការពារជាតិ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៤៥៦.-** អំពើបំផ្លិចបំផ្លាញ ជាអាទិ៍ នូវសម្ភារៈដែលអាចធ្វើឱ្យអន្តរាយដល់ការការពារជាតិ

អំពើបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាត ឬគែបំបាត់ឯកសារ សម្ភារៈ សំណង់ បរិក្ខារ ថបនីយភ័ណ្ឌ គ្រឿងយន្ត គ្រឿងគាំពារខាងបច្ចេកទេស ឬប្រព័ន្ធនៃប្រព្រឹត្តិកម្មស្វ័យប្រវត្តិនៃទិន្នន័យ ឬការធ្វើឱ្យរាំងស្ទះដល់ដំណើរការជា ប្រក្រតីរបស់ឧបករណ៍ទាំងនោះ កាលបើអំពើនេះអាចនាំឱ្យអន្តរាយដល់ការការពារជាតិ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៤៥៧.-** ការផ្ដល់ព័ត៌មានមិនពិត

អំពើផ្ដល់ដល់អាជ្ញាធរស៊ីវិល ឬយោធាខ្មែរនូវព័ត៌មានមិនពិតដែលអាចធ្វើឱ្យអន្តរាយដល់ការការពារជាតិ ដើម្បីបំរើផលប្រយោជន៍នៃរដ្ឋបរទេស ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៥៨.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងមាត្រា ៤៥៧ (ការផ្ដល់ព័ត៌មានមិនពិត) ត្រូវបានផ្ដន្ទាទោសដូចបទមជ្ឈិមដែរ ។

**មាត្រា ៤៥៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះ បទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូល ឬស្នាក់អាស្រ័យនៅ លើដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ឧបឃាត ការរួមគំនិតក្បត់

**មាត្រា ៤៦០.-** ឧបឃាត

ឧបឃាត គឺជាការប្រព្រឹត្តអំពើហិង្សាមួយ ឬច្រើន ក្នុងគោលដៅបង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឱ្យប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ ។

ឧបឃាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៦១.-** ស្ថានទម្ងន់ដែលទាក់ទងទៅនឹងជនល្មើស

ឧបឃាតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត កាលបើអំពើនេះបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ ។

**មាត្រា ៤៦២.-** អំពើរួមគំនិតក្បត់

ការរួមគំនិតក្បត់ គឺជាគម្រោងដែលបង្កើតឡើងដោយមនុស្សច្រើននាក់ ដើម្បីប្រព្រឹត្តឧបឃាត កាលបើគម្រោងនេះ ត្រូវបានស្តែងចេញជារូបរាងច្បាស់លាស់ដោយអំពើជាក់ស្តែងមួយ ឬច្រើន ។

ការរួមគំនិតក្បត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើបទល្មើសនេះ ត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ ។

**មាត្រា ៤៦៣.-** ការលើកលែងឱ្យរួចទោស

បុគ្គលណាដែលបានចូលរួមក្នុងអំពើរួមគំនិតិក្បត់ ត្រូវលើកលែងឱ្យរួចផុតពីការទទួលទោស ប្រសិនបើមុនការចោទប្រកាន់បុគ្គលនោះបានបង្ហាញប្រាប់ដល់អាជ្ញាធរមានសមត្ថកិច្ច ពីអត្ថិភាពនៃអំពើនេះ ហើយដែលនាំឱ្យស្គាល់អត្តសញ្ញាណនៃអ្នកចូលរួមដទៃទៀត ។

**មាត្រា ៩៦៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូល ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៣

## ក្បួនកម្ម

**មាត្រា ៤៦៥.-** កុបកម្ម

កុបកម្ម គឺជាអំពើហិង្សាជាសមូហភាព ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬធ្វើឱ្យប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ ។

**មាត្រា ៤៦៦.-** ទោសដែលត្រូវអនុវត្ត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ការចូលរួមនៅក្នុងចលនាកុបកម្ម :

១-ដោយសាងសង់គ្រឿងរារាំងផ្លូវ គ្រឿងការពារ ឬដោយធ្វើការងារ ដែលមានកម្មវត្ថុរារាំងសកម្មភាពកម្លាំងសាធារណៈ ។

២-ដោយកាន់កាប់អាគារ ឬថបនីយភ័ណ្ឌដោយកម្លាំង ឬដោយកលល្បិច ។

៣-ដោយបំផ្លិចបំផ្លាញអាគារ ឬថបនីយភ័ណ្ឌ ។

៤-ដោយរាំងការដឹកជញ្ជូន ឬការផ្គត់ផ្គង់ពស្តុភារឱ្យកុបករ ។

៥-ដោយញុះញង់ដោយផ្ទាល់ឱ្យមានការប្រមូលផ្តុំកុបករ ។

៦-ដោយមានកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ។

៧-ដោយតាំងខ្លួនជំនួសអាជ្ញាធរស្របច្បាប់ ។

**មាត្រា ៤៦៧.-** ស្ថានទម្ងន់នៃកុបកម្ម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ អំពើចូលរួមនៅក្នុងចលនាកុបកម្ម :

១-ដោយដណ្តើមយក ដោយប្រើកម្លាំង គ្រាប់រំសេវ គ្រឿងផ្ទុះ ឬសារជាតិដទៃទៀត ដែលមានគ្រោះថ្នាក់ដល់បុគ្គល ។

២-ដោយផ្តល់ដល់កុបករ នូវអាវុធ គ្រាប់រំសេវ គ្រឿងផ្ទុះ ឬសារជាតិដទៃទៀតដែលមានគ្រោះថ្នាក់ដល់បុគ្គល ។

**មាត្រា ៤៦៨.-** អំពើដឹកនាំកុបកម្ម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ អំពើដឹកនាំចលនាកុបកម្ម ។

**មាត្រា ៤៦៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះ បទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូល ឬស្នាក់អាស្រ័យនៅ លើដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៤
## ការដណ្ដើមយកអំណាចបញ្ជា និងការបង្កើតកងកម្លាំងប្រដាប់អាវុធ

**មាត្រា ៤៧០.-** អំពើដណ្ដើមយកអំណាចបញ្ជា

អំពើដណ្ដើមយកអំណាចបញ្ជាយោធា ដោយគ្មានសិទ្ធិ ឬគ្មានការអនុញ្ញាតពីអាជ្ញាធរស្របច្បាប់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៧១.-** អំពើរក្សាទុកដោយខុសច្បាប់នូវអំណាចបញ្ជា

អំពើរក្សាទុកអំណាចបញ្ជាយោធា ប្រឆាំងនឹងបញ្ជារបស់អាជ្ញាធរស្របច្បាប់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៧២.-** អំពើបង្កើតដោយខុសច្បាប់នូវកម្លាំងប្រដាប់អាវុធ

អំពើបង្កើតកម្លាំងប្រដាប់អាវុធដោយគ្មានសិទ្ធិ ឬគ្មានការអនុញ្ញាតពីអាជ្ញាធរស្របច្បាប់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៧៣.-** អំពើញុះញង់ឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងអាជ្ញាធររដ្ឋ

អំពើញុះញង់ដោយផ្ទាល់ឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងអាជ្ញាធរស្របច្បាប់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

កាលបើការញុះញង់នេះបានសម្រេចផលបទល្មើស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៧៤.-** អំពើបង្កឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងប្រជាពលរដ្ឋមួយផ្នែក

អំពើញុះញង់ដោយផ្ទាល់ ឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងប្រជាពលរដ្ឋមួយផ្នែកទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

កាលបើការញុះញង់នេះបានសម្រេចផលបទល្មើស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៧៥.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៤៧៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូល ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៥
## ការប៉ះពាល់ដល់សន្តិសុខនៃកងកម្លាំងប្រដាប់អាវុធ

**មាត្រា ៤៧៧.-** អំពើបង្កឱ្យយោធិនចូលបំរើអំណាចបរទេស

អំពើញុះញង់ឱ្យយោធិនដែលជាកងកម្លាំងប្រដាប់អាវុធកម្ពុជាដោយផ្ទាល់ ឱ្យចូលបំរើអំណាចបរទេស ដើម្បីធ្វើឱ្យវិនាសដល់ការការពារជាតិ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៤៧៨.-** អំពើរារាំងដល់ដំណើរការជាធម្មតានៃសម្ភារៈយោធា

អំពើរារាំងដល់ដំណើរការជាធម្មតានៃសម្ភារៈយោធា ដើម្បីធ្វើឱ្យវិនាសដល់ការការពារជាតិ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ

និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៧៩.-** អំពើរារាំងដល់ចលនានៃបុគ្គលិក ឬសម្ភារៈយោធា

អំពើរារាំងដល់ចលនានៃបុគ្គលិក ឬសម្ភារៈយោធា ដើម្បីធ្វើឱ្យវិនាសដល់ការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៨០.-** អំពើញុះញង់យោធិនកុំឱ្យស្តាប់បង្គាប់

អំពើញុះញង់ដោយផ្ទាល់ដល់យោធិនកុំឱ្យស្តាប់បង្គាប់ ដើម្បីធ្វើឱ្យវិនាសដល់ការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៨១.-** អំពើធ្វើឱ្យខូចទឹកចិត្តកងទ័ព

អំពើចូលរួមក្នុងការធ្វើឱ្យខូចទឹកចិត្តកងទ័ព ដើម្បីធ្វើឱ្យវិនាសដល់ការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៨២.-** អំពើចូលដោយទុច្ចរិតក្នុងទីលានយោធា

អំពើចូលដោយឧបាយកលទៅក្នុងទីលាន សំណង់ ឬឧបករណ៍ ដែលប្រគល់ទៅឱ្យអាជ្ញាធរយោធា ឬដែលស្ថិតនៅក្រោមការត្រួតត្រារបស់អាជ្ញាធរយោធា ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៤៨៣.-** អំពើរារាំងដល់ដំណើរការនៃសេវាសម្រាប់ការការពារជាតិ

អំពើប្រព្រឹត្ត ដើម្បីធ្វើឱ្យវិនាសដល់ការការពារជាតិ ដោយរារាំងដំណើរការធម្មតានៃសេវាគ្រឹះស្ថាន ឬសហគ្រាសសាធារណៈ ឬឯកជន ដែលមានប្រយោជន៍ដល់ការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៤៨៤.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៤៨៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូល ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៦
## ការប៉ះពាល់ដល់ការសម្ងាត់នៃការការពារជាតិ

**មាត្រា ៤៨៦.-** គោលការណ៍នៃការការពារការសម្ងាត់ខាងការពារជាតិ

ព័ត៌មាន វិធី វត្ថុ ឯកសារ សលាកប័ត្រ ឬទិន្នន័យព័ត៌មានវិទ្យា ដែលការបើក កកាយអាចធ្វើឱ្យវិនាសដល់ការការពារជាតិ អាចត្រូវធ្វើជាកម្មវត្ថុនៃវិធានការការពារ សម្រាប់បន្ថយការផ្សព្វផ្សាយ ។

បែបបទនៃការរៀបចំវិធានការការពារនេះ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

**មាត្រា ៤៨៧.-** និយមន័យនៃការសម្ងាត់នៃការការពារជាតិ

មានលក្ខណៈជាការសម្ងាត់នៃការការពារជាតិគឺ ព័ត៌មាន វិធី វត្ថុ ឯកសារ សលាកប័ត្រ ឬទិន្នន័យព័ត៌មានវិទ្យា ដែលការផ្សព្វផ្សាយត្រូវបានកម្រិត ។

**មាត្រា ៤៨៨.-** អំពើលាតត្រដាងដោយចេតនា ឬអចេតនា នូវការសម្ងាត់នៃការ ការពារជាតិ

បុគ្គលគ្រប់រូបដែលកាន់កាប់ព័ត៌មាន វិធី វត្ថុ ឯកសារ សលាកប័ត្រ ឬទិន្នន័យ ព័ត៌មានវិទ្យា ដែលមានលក្ខណៈជាការសម្ងាត់នៃការការពារជាតិ ដោយមូលហេតុ

នៃស្ថានភាពរបស់ខ្លួន នៃមុខរបរ នៃមុខងារ ឬបេសកកម្មរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើបុគ្គលនេះបង្ហាញការសម្ងាត់នេះ ដល់បុគ្គលគ្មានគុណសម្បត្តិដើម្បីដឹងទេ ។

កាលបើការប៉ះពាល់ដល់ការសម្ងាត់នៃការការពារជាតិ កើតចេញពីការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការមិនគោរពបទបញ្ជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៤៨៩.-** អំពើកាន់កាប់ការសម្ងាត់នៃការការពារជាតិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើរបស់បុគ្គលដែលគ្មានគុណសម្បត្តិដែលកាន់កាប់ដោយចេតនានូវព័ត៌មាន វិធី វត្ថុ ឯកសារ សលាកប័ត្រ ឬទិន្នន័យព័ត៌មានវិទ្យា ដែលមានលក្ខណៈជាការសម្ងាត់នៃការការពារជាតិ ។

**មាត្រា ៤៩០.-** អំពើបំផ្លិចបំផ្លាញ ឬផលិតឡើងវិញនូវការសម្ងាត់នៃការការពារជាតិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើបំផ្លិចបំផ្លាញ ឬចម្លងព័ត៌មាន វិធី វត្ថុ ឯកសារ សលាកប័ត្រ ឬទិន្នន័យព័ត៌មានវិទ្យា ដែលមានលក្ខណៈជាការសម្ងាត់នៃការការពារជាតិ ។

**មាត្រា ៤៩១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៤៩២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ

អាចត្រូវបានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ៣
## ការប៉ះពាល់ដល់សន្តិសុខសាធារណៈ
## ជំពូកទី ១
## ក្រុមប្រយុទ្ធ

**មាត្រា ៤៩៣.-** និយមន័យនៃក្រុមប្រយុទ្ធ

ក្រុមប្រយុទ្ធ គឺជាក្រុមបុគ្គលដែលមានកាន់កាប់អាវុធ មានការចាត់តាំងជា លំដាប់ថ្នាក់ ដែលអាចនាំឱ្យច្របូកច្របល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ។

**មាត្រា ៤៩៤.-** អំពើចូលរួមក្នុងក្រុមប្រយុទ្ធ

អំពើចូលរួមក្នុងក្រុមប្រយុទ្ធ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៤៩៥.-** អំពើរៀបចំចាត់តាំងក្រុមប្រយុទ្ធ

អំពើរៀបចំចាត់តាំងក្រុមប្រយុទ្ធ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ

ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៩៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះ បទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## បទល្មើសក្នុងវិស័យអាវុធ គ្រាប់រំសេវ និងគ្រឿងផ្ទុះ

**មាត្រា ៤៩៧.-** ការផលិត ឬធ្វើចរាចរអាវុធគ្រឿងផ្ទុះ ឬស្រដៀងគ្នា

ការផលិត ការនាំចូល នាំចេញ និងសន្និធិគ្រឿងអាវុធ គ្រាប់រំសេវ និងគ្រឿងផ្ទុះគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

អាវុធសំដៅដល់កាំភ្លើងគ្រប់ប្រភេទដែលផលិត ឬកែច្នៃតម្លើង ដែលអាចប្រើប្រាស់សម្លាប់ ឬធ្វើឱ្យរបួស ឬធ្វើឱ្យប៉ះពាល់ខូចខាតដល់ទ្រព្យសម្បត្តិ ។

គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សំដៅដល់ឧបករណ៍ សម្ភារៈដែលគេផលិត ឬកែច្នៃ ដែលអាចប្រើប្រាស់សម្លាប់ ឬធ្វើឱ្យរបួស ឬធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ ។

អាវុធគីមី អាវុធជីវសាស្ត្រគ្រប់ប្រភេទ ឬគ្រាប់ដទៃទៀត ដែលផ្ទុកជាតិគីមី ផ្ទុកជីវសាស្ត្រសំដៅដល់សារធាតុ ដែលគេផលិត ឬកែច្នៃតម្លើង អាចបង្កគ្រោះថ្នាក់ដល់សុខភាព អាយុជីវិត ឬទ្រព្យសម្បត្តិ និងបរិស្ថាន ។

**មាត្រា ៤៩៨.-** ការផលិត ឬធ្វើចរាចរអាវុធសម្រាប់ប្រហារផ្សេងទៀត

ការផលិត ការនាំចូល នាំចេញ និងសន្និធិ អាវុធសម្រាប់ប្រហារផ្សេងទៀត ដូចជា ចំពុះទុង ស្នាប់ដៃ ជាអាទិ៍ សម្រាប់សម្លាប់ ឬធ្វើឱ្យរបួស ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៩៩.-** ការកាន់កាប់ ឬដឹកជញ្ជូនអាវុធ ដោយគ្មានការអនុញ្ញាត

គ្រប់បុគ្គលដែលនៅក្រៅលំនៅឋានរបស់ខ្លួន យកតាមខ្លួន ឬដឹកជញ្ជូននូវអាវុធ គ្រាប់រំសេវ ឬគ្រឿងផ្ទុះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

ត្រូវផ្តន្ទាទោសដូចគ្នា គ្រប់បុគ្គលដែលនៅក្រៅលំនៅឋានរបស់ខ្លួន យកតាមខ្លួន ឬដឹកជញ្ជូន អាវុធ ដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៥០០ (ការផលិត ឬធ្វើចរាចរអាវុធសម្រាប់ប្រហារផ្សេងទៀត) ។

**មាត្រា ៥០០.-** ការបោះបង់អាវុធក្នុងទីកន្លែងសាធារណៈ

អំពើបោះបង់អាវុធ ឬវត្ថុដទៃទៀតដែលមានគ្រោះថ្នាក់ដល់បុគ្គល នៅក្នុងទីកន្លែងសាធារណៈ ឬទីកន្លែង ដែលសាធារណជនអាចចូលទៅបាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥០១.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូល ឬស្នាក់អាស្រ័យនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៥០២.-** ការរឹបអូស ក្នុងករណីមានការបោះបង់អាវុធក្នុងទីកន្លែងសាធារណៈ

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៥០០ (ការបោះបង់អាវុធក្នុងទីកន្លែងសាធារណៈ) តុលាការអាចប្រកាសរឹបអូសអាវុធ ឬវត្ថុដែលមានគ្រោះថ្នាក់ចំពោះបុគ្គល ។

## ជំពូកទី ៣

## ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស

**មាត្រា ៥០៣.-** លក្ខខណ្ឌអត្ថិភាពនៃការញុះញង់

ដើម្បីអនុវត្តជំពូកនេះ ការញុះញង់អាចត្រូវផ្ដន្ទាទោស កាលបើអំពើនេះបានប្រព្រឹត្ត ៖

១-ដោយសំដីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីកន្លែងសាធារណៈ ឬនៅក្នុងពេលប្រជុំជាសាធារណៈ ។

២-ដោយសំណេរ ឬគំនូរ ឬតាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយនៅក្នុងសាធារណជន ឬតាំងឱ្យសាធារណជនមើល ។

៣-ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៥០៤.-** អំពើញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ

អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ តាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដែលមានចែងនៅក្នុងមាត្រា ៥០៣ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ ។

**មាត្រា ៥០៥.-** អំពើញុះញង់ឱ្យមានការរើសអើង

អំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា ៥០៣ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) ឱ្យប្រព្រឹត្តការរើសអើង ការគុំគួន ឬហិង្សាចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយ ដោយមូលហេតុបុគ្គលនេះ ជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិពន្ធ នៃប្រជាជាតិ ពូជសាសន៍ ឬសាសនាណាមួយជាកំណត់នោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ ។

**មាត្រា ៥០៦.-** អំពើញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន

បទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ដែលប្រព្រឹត្តតាមផ្លូវសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។

**មាត្រា ៥០៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៤
## សមាគមន៍ជនទុច្ចរិត

**មាត្រា ៥០៨.-** ធាតុផ្សំនៃសមាគមន៍នៃជនទុច្ចរិត និងទោសដែលត្រូវអនុវត្ត

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ការចូលរួមក្នុងក្រុម ឬសន្និដ្ឋភាពដែលត្រូវបង្កើតឡើងដើម្បី :

១-ប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬច្រើន ប្រឆាំងនឹងបុគ្គលដែលមានចែងនៅក្នុងមាតិកាទី ២ ស្ដីពី ការប៉ះពាល់ដោយអចេតនាដល់ជីវិត ដល់មាតិកាទី ៦ ស្ដីពី ការប៉ះពាល់ដល់បុគ្គលភាព ក្នុងគន្ថីទី ២ ស្ដីពី ការប៉ះពាល់ជីវិតមនុស្ស នៃភាគទី ២ ស្ដីពី បទល្មើសប្រឆាំងនឹងបុគ្គល នៃក្រមនេះ ។

២-ប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬច្រើន ប្រឆាំងនឹងទ្រព្យសម្បត្តិ ដែលមានចែងនៅក្នុងភាគទី ៣ នៃក្រមនេះ ។

**មាត្រា ៥០៩.-** ការលើកលែងឱ្យរួចទោស

ត្រូវបានលើកលែងឱ្យរួចពីការទទួលទោស បុគ្គលណាដែលបានចូលរួមនៅក្នុងក្រុម ឬសន្និដ្ឋភាព នៅពេលមុនការចោទប្រកាន់ បានបង្ហាញពីក្រុម ឬ

សន្និដ្ឋភាពដល់អាជ្ញាធរមានសមត្ថកិច្ច និងដែលនាំឱ្យកត់សម្គាល់បានអត្តសញ្ញាណរបស់អ្នកចូលរួមដទៃទៀត ។

**មាត្រា ៥១០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំយ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ៤
## ការប៉ះពាល់ដល់អាជ្ញាធររបស់រដ្ឋ
## ជំពូកទោល
## ការប្រមាថ និងឧទ្ទាមកម្ម

**មាត្រា ៥១១.-** ធាតុផ្សំនៃការប្រមាថ និងទោសដែលត្រូវអនុវត្ត

ការប្រមាថ គឺជាវាចារ កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរនៃបុគ្គល ។

ការប្រមាថចំពោះអ្នករាជការសាធារណៈ ឬចំពោះពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៥១២.-** ធាតុផ្សំនៃឧទ្ទាមកម្ម និងទោសដែលត្រូវអនុវត្ត

ឧទ្ទាមកម្ម គឺជាអំពើប្រឆាំង ដោយប្រើការតទល់ដោយហិង្សា ទៅលើអ្នករាជការសាធារណៈ ដែលធ្វើសកម្មភាព ដើម្បីអនុវត្តច្បាប់ បញ្ជារបស់ អាជ្ញាធរសាធារណៈ ឬសេចក្ដីសម្រេចរបស់តុលាការ ។

ឧទ្ទាមកម្ម ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ៥១៣.-** ស្ថានទម្ងន់នៃឧទ្ទាមកម្ម

ឧទ្ទាមកម្ម ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល នៅក្នុងករណីដូចតទៅ :

១-ឧទ្ទាមកម្ម បានប្រព្រឹត្តដោយបុគ្គលច្រើនរូបធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិត ។

២-ចារីមានពាក់អាវុធ ។

**មាត្រា ៥១៤.-** ការញុះញង់ឱ្យប្រព្រឹត្តឧទ្ទាមកម្ម

ការញុះញង់ដោយផ្ទាល់ ឱ្យប្រព្រឹត្តឧទ្ទាមកម្ម ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៥១៥.-** ការប្រឆាំងនឹងការអនុវត្តការងារសាធារណៈ

អំពើប្រឆាំងដោយហិង្សាទៅលើការអនុវត្តការងារសាធារណៈ ឬការងារដែលមានប្រយោជន៍ជាសាធារណៈ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ៥១៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

# មាតិកាទី ៥

# ការប៉ះពាល់ដល់សាសនារបស់រដ្ឋ

## ជំពូកទី ១

## បទល្មើសប្រឆាំងនឹងព្រះពុទ្ធសាសនា

**មាត្រា ៥១៧.-** ការប្រារព្ធពិធីបែបព្រះពុទ្ធសាសនា ដោយគ្មាននីតិសម្បទា

ដោយអនុលោមតាមមាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

អំពើប្រារព្ធនៅក្នុងគ្រឹះស្ថានសាសនា ដែលបើកចំហដល់សាធារណជននូវពិធីតាមសាសនាព្រះពុទ្ធ ដោយគ្មានបានទទួលនីតិសម្បទាពីអាជ្ញាធរសាសនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល អំពើស្លៀកពាក់ជាសាធារណៈ ដោយគ្មានសិទ្ធិនឹងស្លៀកពាក់នូវសំលៀកបំពាក់សម្រាប់សាសនា ។

**មាត្រា ៥១៨.-** ការលួចវត្ថុសម្រាប់បូជាចំពោះព្រះពុទ្ធសាសនា

ដោយមិនទាន់គិតដល់ទោសដែលធ្ងន់ជាងគេដែលចែងក្នុងក្រមនេះ ការលួចវត្ថុដែលបូជាដល់សាសនាព្រះពុទ្ធ ដែលប្រព្រឹត្តនៅក្នុងគ្រឹះស្ថានសាសនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥១៩.-** ការធ្វើឱ្យខូចខាតដល់គ្រឹះស្ថានសាសនា ឬវត្ថុសម្រាប់បូជា

ដោយមិនទាន់គិតដល់ទោសធ្ងន់ជាងគេដែលចែងក្នុងក្រមនេះ អំពើដែលប្រព្រឹត្តដោយចេតនាបំផ្លាញ ធ្វើឱ្យខូចខាត ឬឱ្យទ្រុឌទ្រោមនូវគ្រឹះស្ថានសាសនាដែលបូជាដល់សាសនាព្រះពុទ្ធ ឬវត្ថុបូជាដល់សាសនានេះ ត្រូវផ្តន្ទាទោសដាក់

ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥២០.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៥២១.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

# ជំពូកទី ២
# បទល្មើសប្រឆាំងនឹងព្រះសង្ឃ ដូនជី ឬតាជី
## ផ្នែកទី ១
## អំពើហិង្សា

**មាត្រា ៥២២.-** អំពើហិង្សាដោយចេតនា

អំពើហិង្សាប្រព្រឹត្តដោយចេតនា ចំពោះព្រះសង្ឃ ដូនជី ឬតាជី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥២៣.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមានការកាត់អវៈយវៈ ឬពិការភាព

អំពើហិង្សាប្រព្រឹត្តដោយចេតនា ចំពោះព្រះសង្ឃ ដូនជី ឬតាជី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវៈយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ។

**មាត្រា ៥២៤.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមរណភាពរបស់ជនរងគ្រោះ

អំពើហិង្សាប្រព្រឹត្តដោយចេតនា ចំពោះព្រះសង្ឃ ដូនជី ឬតាជី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ បណ្តាលឱ្យមានការស្លាប់ជនរងគ្រោះ ដោយគ្មានចេតនានឹងឱ្យស្លាប់ទេ ។

## ផ្នែកទី ២
## ការប្រមាថ

**មាត្រា ៥២៥.-** ការប្រមាថចំពោះព្រះសង្ឃ ដូនជី និងតាជី

ការប្រមាថដូចបញ្ញត្តិក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១១(ធាតុផ្សំនៃការប្រមាថ និងទោសដែលត្រូវអនុវត្ត) នៃក្រមនេះ ដែលប្រព្រឹត្តឡើងចំពោះព្រះសង្ឃ ដូនជី ឬតាជី នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬក្នុងឱកាសនៃការបំពេញមុខងារ ត្រូវផ្តន្ទាទោស

ដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

# គន្ថីទី ២

# ការប៉ះពាល់ដល់យុត្តិធម៌

## មាតិកាទី ១

## ការប៉ះពាល់ដល់អាជ្ញាធរតុលាការ

### ជំពូកទី ១

### ការប៉ះពាល់ដល់ចៅក្រម និងអ្នកជំនួយតុលាការ

**មាត្រា ៥២៦.-** អំពើស៊ីសំណូកប្រព្រឹត្តដោយចៅក្រម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ អំពើរបស់ចៅក្រមដែលទទូចសុំ ឬយល់ព្រមដោយគ្មានសិទ្ធិ ដោយផ្ទាល់ ឬដោយប្រយោល ទទួលអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយដើម្បី :

១-បំពេញកិច្ចនៅក្នុងមុខងាររបស់ខ្លួន ។

២-ឬមិនបំពេញកិច្ចនៅក្នុងមុខងាររបស់ខ្លួន ។

**មាត្រា ៥២៧.-** អំពើសូកប៉ាន់ចំពោះចៅក្រម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បុគ្គលណាដែលគ្មានសិទ្ធិ ដោយផ្ទាល់ ឬដោយប្រយោល ប្រគល់ជូនចៅក្រមនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីឱ្យចៅក្រមនេះ :

១-បំពេញកិច្ចនៅក្នុងមុខងាររបស់ខ្លួន ។

២-ឬមិនបំពេញកិច្ចនៅក្នុងមុខងាររបស់ខ្លួន ។

**មាត្រា ៥២៨.-** អំពើសម្លុតចៅក្រម ឬមេធាវី

គ្រប់អំពើសម្លុតចៅក្រម មេធាវី ដើម្បីជះឥទ្ធិពលទៅលើការប្រព្រឹត្តរបស់ចៅក្រម ឬមេធាវី នៅក្នុងការបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះ ស្តែងចេញជាលទ្ធផល ។

**មាត្រា ៥២៩.-** ការប្រមាថចំពោះចៅក្រម

ការប្រមាថដូចមានចែងក្នុងមាត្រា ៥១១ (ធាតុផ្សំនៃការប្រមាថ និងទោសដែលត្រូវអនុវត្ត) នៃក្រមនេះ ចំពោះចៅក្រម នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

ប្រសិនបើការប្រមាថនេះ បានប្រព្រឹត្តនៅក្នុងសវនាការនៃតុលាការ អំពើនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

## ជំពូកទី ២
## ការប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ

**មាត្រា ៥៣០.-** អំពើជ្រៀតជ្រែកក្នុងការបំពេញមុខងាររបស់តុលាការ

អំពើរបស់អ្នករាជការសាធារណៈ យោធិន ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលជ្រៀតជ្រែកទៅក្នុងការបំពេញមុខងារតុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥៣១.-** ការបដិសេធនូវការអនុវត្តសេចក្តីសម្រេចរបស់តុលាការ

អំពើរបស់អ្នករាជការសាធារណៈ យោធិនក្នុងមុខការរបស់ខ្លួន ដែលមិនព្រមអនុវត្តសាលដីកា សាលក្រម ដីកា ឬរាល់បញ្ជារបស់អាជ្ញាធរតុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥៣២.-** ការផ្តល់ដោយខុសច្បាប់នូវបញ្ជាឱ្យឃុំ ឬដោះលែង

អំពើរបស់អ្នករាជការសាធារណៈ យោធិន ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលក្រោមរូបភាពណាក៏ដោយ ចេញបញ្ជាឱ្យឃុំ ឬឱ្យដោះលែងជនជាប់ឃុំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៥៣៣.-** ការផ្សព្វផ្សាយនូវការអត្ថាធិប្បាយ ដើម្បីធ្វើសំពាធលើយុត្តាធិការ

ការផ្សព្វផ្សាយមុនសេចក្តីសម្រេចជាស្ថាពររបស់តុលាការ នូវអត្ថាធិប្បាយដោយមានគោលដៅធ្វើការគាបសង្កត់ទៅលើតុលាការដែលត្រូវប្តឹង ដើម្បីជះឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់តុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥៣៤.-** ការធ្វើឱ្យ បាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ

អំពើរិះគន់លិខិត ឬសេចក្តីសម្រេចរបស់តុលាការ ក្នុងគោលដៅបង្កឱ្យមានភាពវឹកវរដល់សណ្តាប់ធ្នាប់សាធារណៈ ឬក៏បង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

អំពើដែលមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ត្រូវផ្តន្ទាទោសដូចគ្នានឹងទោសដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

**មាត្រា ៥៣៥.-** ការប្តឹងបរិហារ ដោយភូតកុហកដល់អាជ្ញាធរតុលាការ

អំពើដែលប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ ឬអាជ្ញាធររដ្ឋបាលនូវហេតុជាបទល្មើស កាលបើអំពើនេះនាំឱ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥៣៦.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៥៣២ (អំពើជ្រៀតជ្រែកក្នុងការបំពេញមុខងាររបស់តុលាការ)និងមាត្រា ៥៣៧ (ការប្ដឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ) នៃក្រមនេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៥៣៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន ។

៦-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៥៣៨.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌនៃនីតិបុគ្គល) ចំពោះបទល្មើស

ដែលបញ្ញត្តក្នុងមាត្រា ៥២៦(អំពើស៊ីសំណូកប្រព្រឹត្តដោយចៅក្រម)។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្តេញចេញពីអាបណសញ្ញា តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) ។

៦-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៨-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

៩-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## មាតិកាទី ២

## ការប៉ះពាល់ដល់សកម្មភាពរបស់តុលាការ

### ជំពូកទី ១

### ការប្តឹងទៅតុលាការ

**មាត្រា ៥៣៩.-** អំពើសម្លុតកុំឱ្យដាក់ពាក្យបណ្តឹង

អំពើគំរាមកំហែងសម្លុត ដើម្បីញុះញង់ជនរងគ្រោះ កុំឱ្យដាក់ពាក្យបណ្តឹង ឬដកពាក្យបណ្តឹងរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើបទល្មើសនេះមានប្រសិទ្ធភាព ។

**មាត្រា ៥៤០.-** ការមិនប្តឹងបរិហារបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយភ្នាក់ងារសាធារណៈ

អំពើរបស់អ្នករាជការសាធារណៈ យោធិន ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលមិនបានប្តឹងដល់អាជ្ញាធរតុលាការពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលខ្លួនបានដឹងនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៤១.-** ការបង្ក្រាប និងការលើកលែងទោស ចំពោះការមិនបរិហារបទឧក្រិដ្ឋ

រាល់បុគ្គលណាដែលបានដឹងពីបទឧក្រិដ្ឋ ដែលអាចនឹងបង្ការ ឬបន្ថយអានុភាពរបស់បទល្មើសបាន ហើយមិនប្ដឹងដល់អាជ្ញាធរតុលាការ ឬអាជ្ញាធររដ្ឋបាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ប៉ុន្តែត្រូវបានលើកលែងឱ្យផុតពីទោសគឺ :

១-បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៃបទឧក្រិដ្ឋ ។

២-សហព័ទ្ធរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតនៃបទឧក្រិដ្ឋ ។

៣-បុគ្គលដែលច្បាប់តម្រូវឱ្យរក្សាការអាថ៌កំបាំងនៃវិជ្ជាជីវៈ ។

**មាត្រា ៥៤២.-** ការមិនបរិហារការធ្វើបាបអនីតិជន

រាល់បុគ្គលណាដែលបានដឹងពីការធ្វើបាប ឬការបៀតបៀនខាងផ្លូវភេទលើអនីតិជនអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ មិនផ្តល់ព័ត៌មានដល់អាជ្ញាធរតុលាការ ឬអាជ្ញាធររដ្ឋបាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

## ជំពូកទី ២
## ការប្ដឹងទៅតុលាការ

**មាត្រា ៥៤៣.-** អំពើលាក់បំបាំងសាកសព

អំពើដែលធ្វើឱ្យបាត់ ឬលាក់បំបាំងសាកសពបុគ្គលណាម្នាក់ដែលរងគ្រោះពីបទមនុស្សឃាត ឬទទួលមរណភាពបន្ទាប់ពីអំពើហិង្សា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៤៤.-** អំពើលាក់បំបាំងតំរុយ

អំពើកែប្រែ ឬលុបបំបាត់តំរុយ ឬស្លាកស្នាមនៅលើទីកន្លែងនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ក្នុងគោលបំណងធ្វើជាឧបសគ្គដល់ការស្វែងរកឱ្យឃើញនូវការពិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៤៥.-** អំពើលុបបំបាត់វត្ថុតាង

អំពើលុបបំបាត់ ឬផ្លាស់ប្តូរទីកន្លែង ឬយកវត្ថុណាមួយក៏ដោយ នៅលើទីកន្លែងនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមក្នុងគោលបំណងធ្វើជាឧបសគ្គដល់ការស្វែងរកឱ្យឃើញនូវការពិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៤៦.-** អំពើបំផ្លិចបំផ្លាញឯកសារ

អំពើប្រព្រឹត្តដោយចេតនាក្នុងការបំផ្លិចបំផ្លាញ លួចយក ឬកែប្រែឯកសារ ឬវត្ថុអ្វីមួយ ដែលអាចនាំឱ្យមានការងាយស្រួលដល់ការរកឃើញបទឧក្រិដ្ឋ ឬបទមជ្ឈិម ការរកឃើញអត្តសញ្ញាណនៃចារី ឬការចាប់ខ្លួនចារី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៤៧.-** អំពើបំបែកបន្ទះស្លាកល័ក្ខ

អំពើបំបែកស្លាកល័ក្ខដែលបោះត្រាដោយអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៤៨.-** អំពើបំផ្លិចបំផ្លាញ ឬគៃបំបាត់វត្ថុដែលមានជាប់បន្ទះសិពត់ភ្ជាប់ស្លាកល័ក្ខ

អំពើបំផ្លិចបំផ្លាញ ឬគៃបំបាត់វត្ថុដែលមានស្លាកល័ក្ខបោះត្រាដោយអាជ្ញាធរ

មានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៤៩.-** អំពើបដិសេធការផ្តល់ចម្លើយ

រាល់បុគ្គលណាដែលបានប្រកាសជាសាធារណៈថាខ្លួនស្គាល់ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិតនៅក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយប្រកែកមិនព្រមឆ្លើយនឹងសំណួរដែលចៅក្រមបានសួរពីរឿងនេះដល់ខ្លួននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៥៥០.-** អំពើបដិសេធក្នុងការចូលខ្លួន

រាល់បុគ្គលណា ដែលត្រូវបានកោះហៅឱ្យមកឆ្លើយជាសាក្សីនៅមុខអយ្យការ ឬចៅក្រមស៊ើបសួរ ឬមុខតុលាការព្រហ្មទណ្ឌ ហើយមិនព្រមចូលខ្លួនតាមដីកាកោះហៅនោះដោយគ្មានមូលហេតុសមស្រប ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥៥១.-** ទណ្ឌកម្ម និងការលើកលែងទោស

រាល់បុគ្គលណា ដែលមានភស្តុតាងបង្ហាញឱ្យឃើញភាពស្លូតត្រង់របស់ជនជាប់ចោទ ឬទណ្ឌិត ហើយមិនផ្តល់ភស្តុតាងនោះដល់អាជ្ញាធរតុលាការ ឬអាជ្ញាធររដ្ឋបាលទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

ប៉ុន្តែត្រូវបានលើកលែងឱ្យផុតពីទោស :

១-ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៃបទល្មើសដែលចោទប្រកាន់ ។

២-បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិត ។

៣-សហព័ទ្ធរបស់ចារី សហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិត ។

៤-បុគ្គលដែលត្រូវរក្សារអាថ៌កំបាំងខាងវិជ្ជាជីវៈ ។

**មាត្រា ៥៥២.-** ការប្រើប្រាស់អត្តសញ្ញាណរបស់អ្នកដទៃ

អំពើយកឈ្មោះតតិយជននៅក្នុងកាលៈទេសៈ ដែលនាំឱ្យមានការចោទប្រកាន់ខាងបទព្រហ្មទណ្ឌចំពោះតតិយជន ឬដែលអាចនាំឱ្យមានការចោទប្រកាន់ខាងបទព្រហ្មទណ្ឌចំពោះតតិយជន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៥៣.-** ការបដិសេធមិនស្ដាប់បង្គាប់បញ្ជា

អ្នកបើកបរយានជំនិះណាមួយ ដែលមិនព្រមស្ដាប់បង្គាប់បញ្ជាឱ្យឈប់របស់នគរបាល ឬកងរាជអាវុធហត្ថដែលមានពាក់សញ្ញាសម្គាល់ឋានៈយ៉ាងច្បាស់របស់នគរបាល ឬកងរាជអាវុធហត្ថ ដើម្បីស្វែងរកភស្ដុតាង អ្នកបើកបរនោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ៥៥៤.-** ការបដិសេធរបស់អ្នកបើកបរ មិនព្រមទទួលការពិនិត្យ

អ្នកបើកបរយានជំនិះណាមួយ ដែលមិនព្រមដាក់ខ្លួនឱ្យធ្វើការត្រួតពិនិត្យលើយាន ឬលើខ្លួនទេ កាលបើការត្រួតពិនិត្យនេះ ត្រូវបានធ្វើឡើងដើម្បីស្វែងរកភស្ដុតាងដោយនគរបាល ឬកងរាជអាវុធហត្ថ ដែលមានពាក់សញ្ញាសម្គាល់ឋានៈយ៉ាងច្បាស់របស់នគរបាល ឬកងរាជអាវុធហត្ថនោះ អ្នកបើកបរនោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ៥៥៥.-** និយមន័យនៃអំពើរត់គេចខ្លួន និងទណ្ឌកម្ម

អំពើប្រព្រឹត្តដោយអ្នកបើកបរយានជំនិះផ្លូវគោក ទន្លេ ឬសមុទ្រ ដោយបានដឹងច្បាស់ថាខ្លួនទើបតែបង្កឱ្យមានគ្រោះថ្នាក់ ឬការខូចខាតហើយមិនព្រមឈប់ដើម្បីគេចខ្លួនពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ដែលខ្លួនអាចនឹងរងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៥៦.-** ទណ្ឌកម្ម និងការលើកលែងទោសចំពោះការផ្តល់ជំនួយដល់ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើដែលផ្តល់ឱ្យដល់ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទឧក្រិដ្ឋនូវ :

១-ទីលំនៅ ។

២-កន្លែងលាក់ខ្លួន ។

៣-មធ្យោបាយសម្រាប់ការរស់នៅ ។

៤-គ្រប់មធ្យោបាយដែលអាចនាំឱ្យមានការងាយស្រួលក្នុងការគេចខ្លួន ឬក៏ឱ្យជននោះគេចផុតពីការស្រាវជ្រាវ ។

ប៉ុន្តែត្រូវបានលើកលែងឱ្យផុតពីទោស :

១-បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីរបស់ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ។

២-សហព័ទ្ធរបស់ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ។

**មាត្រា ៥៥៧.-** ទណ្ឌកម្ម និងការលើកលែងទោសចំពោះសក្ខីកម្មក្លែងក្លាយ

សក្ខីកម្មភូតកុហក ដែលធ្វើក្រោយពីបានស្បថនៅមុខតុលាការ ឬនៅមុខមន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើសកម្មភាពនៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឱ្យសួរចម្លើយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

សាក្សីដែលបានភូតកុហកលើកលែងឱ្យផុតពីទោស ប្រសិនបើសាក្សីនេះប្រែក្រឡាស់ដោយឯកឯងនូវសាក្ខីកម្មរបស់ខ្លួន ហើយនិយាយតែការពិតមុនសេចក្ដីសម្រេចបញ្ចប់នីតិវិធីស៊ើបសួរ ឬនីតិវិធីជំនុំជម្រះ ។

**មាត្រា ៥៥៨.-** អំពើសម្លុតសាក្សី

គ្រប់អំពើសម្លុត ដែលប្រព្រឹត្តដោយចារីតែម្នាក់ឯង ឬដោយមានការព្រមព្រៀងជាមួយតតិយជន ដើម្បីញុំាងឱ្យសាក្សីកុំឆ្លើយ ឬឱ្យផ្ដល់ដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរនូវសក្ខីកម្មភូតកុហក ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះ មានប្រសិទ្ធភាព ។

**មាត្រា ៥៥៩.-** អំពើស៊ីសំណូករបស់សាក្សី ដើម្បីធ្វើសក្ខីកម្មក្លែងក្លាយ

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ អំពើរបស់សាក្សីណាដែលទទួលស៊ី ឬយល់ព្រមទទួលយកដោយផ្ទាល់ ឬប្រយោលនូវអំណោយជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ :

១-ដើម្បីមិនធ្វើជាសាក្សី ។

២-ដើម្បីឱ្យផ្ដល់សក្ខីកម្មភូតកុហក ។

**មាត្រា ៥៦០.-** អំពើសូកប៉ាន់សាក្សី

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ រាល់បុគ្គលណាប្រគល់ឱ្យដល់សាក្សីដោយផ្ទាល់ ឬប្រយោល នូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ :

១-ដើម្បីមិនធ្វើជាសាក្សី ។

២-ដើម្បីឱ្យផ្ដល់សក្ខីកម្មភូតកុហក ។

**មាត្រា ៥៦១.-** ការផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់លើសាក្សី

ការផ្សព្វផ្សាយមុនសេចក្ដីសម្រេចជាស្ថាពររបស់តុលាការ នូវអត្ថាធិប្បាយដែលមានគោលបំណងធ្វើការគាបសង្កត់លើសាក្សី ដើម្បីជះឥទ្ធិពលទៅលើសក្ខីកម្មរបស់សាក្សីនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

## ជំពូកទី ៣
## ការបកប្រែ និងកោសលវិច្ឆ័យ

**មាត្រា ៥៦២.-** ការបំភ្លៃដោយអ្នកបកប្រែ

អំពើប្រព្រឹត្តដោយអ្នកបកប្រែ ដែលបំភ្លៃដោយចេតនានូវខ្លឹមសារនៃភាសា ឬឯកសារដែលបកប្រែ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥៦៣.-** ការក្លែងដោយអ្នកជំនាញ

អំពើប្រព្រឹត្តដោយអ្នកជំនាញ ដែលក្លែងនៅក្នុងរបាយការណ៍ជាលាយល័ក្ខណ៍អក្សរ ឬសេចក្ដីថ្លែងការណ៍ដោយផ្ទាល់មាត់នូវទិន្នន័យ ឬលទ្ធផលនៃកោសលវិច្ឆ័យ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥៦៤.-** អំពើសម្លុតអ្នកជំនាញ ឬអ្នកបកប្រែ

គ្រប់អំពើសម្លុតចំពោះអ្នកជំនាញ ឬអ្នកបកប្រែ ដើម្បីជះឥទ្ធិពលទៅលើការប្រព្រឹត្តរបស់បុគ្គលនេះនៅក្នុងការបំពេញមុខងាររបស់ខ្លួន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះមានប្រសិទ្ធភាព ។

**មាត្រា ៥៦៥.-** អំពើស៊ីសំណូករបស់អ្នកបកប្រែ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ អំពើរបស់អ្នកបកប្រែដែលទទួចសុំ ឬយល់ព្រមទទួលដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីក្លែងសារជាតិនៃភាសា ឬឯកសារដែលបកប្រែ ។

**មាត្រា ៥៦៦.-** អំពើសូកប៉ាន់អ្នកបកប្រែ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ រាល់បុគ្គលណាដែលប្រគល់ឱ្យអ្នកបកប្រែដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីក្លែងសារជាតិនៃភាសា ឬឯកសារដែលបកប្រែ ។

**មាត្រា ៥៦៧.-** អំពើស៊ីសំណូករបស់អ្នកជំនាញ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ អំពើរបស់អ្នកជំនាញដែលទទួចសុំ ឬយល់ព្រមទទួលដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីក្លែងនៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់របស់ខ្លួននូវទិន្នន័យ ឬលទ្ធផលនៃកោសលវិច្ច័យ ។

**មាត្រា ៥៦៨.-** អំពើសូកប៉ាន់អ្នកជំនាញ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បុគ្គលណាដែលប្រគល់ឱ្យអ្នកជំនាញដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីក្លែងនៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់របស់ខ្លួននូវទិន្នន័យ ឬលទ្ធផលនៃកោសលវិច្ច័យ ។

## ជំពូកទី ៤
## ការប៉ុនប៉ង និងទោសបន្ថែម

**មាត្រា ៥៦៩.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងមាត្រា ៥៣៩ (អំពើសម្លុតកុំឱ្យដាក់ពាក្យបណ្ដឹង) មាត្រា ៥៤៣ (អំពើលាក់បំបាំងសាកសព) មាត្រា ៥៤៨ (អំពើបំផ្លិចបំផ្លាញ ឬកែបំបាត់វត្ថុដែលជាប់បន្ទះសំពត់ភ្ជាប់ស្លាកល័ក្ខ) មាត្រា ៥៥២ (ការប្រើប្រាស់អត្តសញ្ញាណរបស់អ្នកដទៃ) និងមាត្រា ៥៥៦ (ទណ្ឌកម្ម និងការលើកលែងទោសចំពោះការផ្ដល់ជំនួយដល់ចារី សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត) នៃក្រមនេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៥៧០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងមាតិកានេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៥៧១.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តិក្នុងមាត្រា ៥៦០ (អំពើសូកប៉ាន់សាក្សី) មាត្រា ៥៦៦ (អំពើសូកប៉ាន់អ្នកបកប្រែ) និងមាត្រា ៥៦៨ (អំពើសូកប៉ាន់អ្នកជំនាញ) នៃក្រមនេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ២០.០០០.០០០ (ម្ភៃលាន) ទៅ ២០០.០០០.០០០ (ពីររយលាន) រៀល ព្រមទាំងបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្តេញចេញពីអាបណសញ្ញា តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្ទុំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្ទុំសំចៃ) ។

៦-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៨-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

៩-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## មាតិកាទី ៣
## បទល្មើសទាក់ទងដល់ការឃុំឃាំង
### ជំពូកទី ១
### ធាតុផ្សំនៃបទល្មើសលួចរត់

**មាត្រា ៥៧២.-** អំពើលួចរត់

អំពើរបស់អ្នកជាប់ឃុំ ដែលលួចរត់ពីការឃុំខ្លួន តាមគ្រប់មធ្យោបាយ ។

ការលួចរត់ចេញពីទីឃុំឃាំង ត្រូវចាត់ទុកថាគ្រប់លក្ខណៈដែរ ទោះបីជាមធ្យោបាយខាងលើនេះ ជាអំពើរបស់តតិយជនក៏ដោយ ។

ត្រូវចាត់ទុកថាជាជនជាប់ឃុំឃាំងគឺ :

១-បុគ្គលដែលគេឃាត់ខ្លួនទុក ។

២-បុគ្គលដែលគេហៀបនឹងនាំទៅបង្ហាញខ្លួន ឬកំពុងតែនាំទៅបង្ហាញខ្លួន ដល់អាជ្ញាធរតុលាការក្រោយពីការឃាត់ខ្លួន ឬដោយអនុវត្តដីកានាំខ្លួន ឬឱ្យចាប់ខ្លួន ។

៣-បុគ្គលដែលបានទទួលលិខិតឱ្យដំណឹងពីដីកាឱ្យឃុំ ឬឱ្យចាប់ខ្លួន ។

៤-បុគ្គលដែលអនុវត្តទោសដាក់ពន្ធនាគារ ឬដែលត្រូវគេចាប់ខ្លួន ដើម្បីអនុវត្តទោសនេះ ។

៥-បុគ្គលដែលត្រូវគេឃុំខ្លួននៅក្នុងក្របខ័ណ្ឌនៃនីតិវិធីបត្យាប័ន ។

៦-ជនដែលស្ថិតក្នុងរបបពាក់កណ្តាលសេរីភាពតាមបញ្ញត្តិនៃមាត្រា ១២៧ (លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព) នៃក្រមនេះ ។

**មាត្រា ៥៧៣.-** ទោសដែលត្រូវអនុវត្ត

អំពើលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៧៤.-** អំពើដែលប្រដូចទៅនឹងអំពើលួចរត់

ត្រូវចាត់ទុកថាជាអំពើលួចរត់ និងត្រូវផ្តន្ទាទោសដូចគ្នា ៖

១-អំពើរបស់អ្នកជាប់ឃុំឃាំងដាក់នៅក្នុងគ្រឹះស្ថានសុខាភិបាល ឬមន្ទីរពេទ្យ ឬទីកន្លែងផ្សេងទៀត ដូចជា តុលាការ ស្នងការដ្ឋាននគរបាល ជាអាទិ៍ ដែលគេចខ្លួនចេញពីការតាមឃ្លាំមើលដែលស្ថិតនៅពីលើខ្លួន ។

២-អំពើរបស់ទណ្ឌិតដែលបានទទួលរបបពាក់កណ្តាលសេរីភាព របបព្យួរទោស ឬរបបបែងជាប្រភាគនៃទោស ឬនៃការអនុញ្ញាតឱ្យចេញក្រៅពន្ធនាគារ ហើយមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតរយៈកាលនៃសេរីភាព ។

# ជំពូកទី ២
# ស្ថានទម្ងន់នៃអំពើលួចរត់ និងការជួយសម្រួលដល់ការលួចរត់

**មាត្រា ៥៧៥.-** អំពើគំរាមកំហែងដោយអាវុធ ឬដោយសកម្មភាពដែលមានការព្រមព្រៀង

អំពើលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះបានប្រព្រឹត្តនៅក្នុងកាលៈទេសៈណាមួយដូចខាងក្រោម :

១-ដោយមានការគំរាមកំហែងនឹងអាវុធ ឬដោយសារជាតិផ្ទុះ ។

២-នៅក្នុងក្របខ័ណ្ឌនៃសកម្មភាពព្រមព្រៀងគ្នារវាងអ្នកជាប់ឃុំច្រើននាក់ ។

**មាត្រា ៥៧៦.-** ការប្រើប្រាស់អាវុធ

អំពើលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើមានប្រើប្រាស់អាវុធ ឬសារជាតិផ្ទុះ ។

**មាត្រា ៥៧៧.-** ការផ្តល់មធ្យោបាយលួចរត់

អំពើផ្តល់ឱ្យអ្នកជាប់ឃុំនូវគ្រប់មធ្យោបាយសម្រាប់លួចរត់ ឬសម្រាប់សម្រួលដល់ការលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៧៨.-** ស្ថានទម្ងន់នៃអំពើផ្តល់នូវមធ្យោបាយលួចរត់

អំពើផ្តល់ឱ្យអ្នកជាប់ឃុំនូវអាវុធ ឬសារជាតិផ្ទុះ ឬសារជាតិបង្កអគ្គីភ័យ ឬសារជាតិពុល ឬអាស៊ីដដើម្បីប្រើប្រាស់ជាមធ្យោបាយ ឬសម្រួលដល់ការលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥៧៩.-** អំពើជួយសម្រួលដល់ការលួចរត់ ដោយអ្នកត្រួតពិនិត្យ

អំពើរបស់បុគ្គលដែលទទួលភារកិច្ចខាងការថែរក្សា ដែលសម្រួល ឬត្រៀមរៀបចំឱ្យអ្នកជាប់ឃុំរត់ចេញ ទោះជាតាមអំពើអកម្មដោយចេតនាក៏ដោយ ក៏ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៥៨០.-** ស្ថានទម្ងន់នៃអំពើជួយសម្រួលដល់ការលួចរត់ ដោយអ្នកត្រួតពិនិត្យ

អំពើរបស់បុគ្គលដែលទទួលភារកិច្ចខាងការថែរក្សា ដែលផ្តល់ឱ្យអ្នកជាប់ឃុំនូវអាវុធ ឬសារធាតុផ្ទុះ ឬសារធាតុបង្កអគ្គីភ័យ ឬសារធាតុពុល ឬអាស៊ីដ ដើម្បីប្រើប្រាស់ជាមធ្យោបាយ ឬសម្រួលដល់ការលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៥៨១.-** អំពើជួយសម្រួលដល់ការលួចរត់ ប្រព្រឹត្តដោយបុគ្គលដែលបានទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ

អំពើរបស់បុគ្គលដែលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារដែលសម្រួល ឬត្រៀមរៀបចំឱ្យជនជាប់ឃុំរត់ចេញ ទោះជាតាមអំពើអកម្មដោយចេតនាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៥៨២.-** ស្ថានទម្ងន់នៃអំពើជួយសម្រួលដល់ការលួចរត់ ប្រព្រឹត្តដោយបុគ្គលដែលបានទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ

អំពើរបស់បុគ្គលដែលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារដែលផ្តល់ឱ្យអ្នកជាប់ឃុំនូវអាវុធ ឬសារធាតុផ្ទុះ ឬសារធាតុបង្កអគ្គីភ័យ ឬសារធាតុពុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

## ជំពូកទី ៣
## ការប្រគល់ដោយខុសច្បាប់នូវទឹកប្រាក់ និងវត្ថុ ដល់អ្នកជាប់ឃុំ

**មាត្រា ៥៨៣.-** អំពើប្រគល់ដោយខុសច្បាប់ និងស្ថានទម្ងន់

អំពើប្រគល់ ឬផ្ញើឱ្យដល់អ្នកជាប់ឃុំនូវទឹកប្រាក់ លិខិតឆ្លើយឆ្លង វត្ថុ ឬសារធាតុ

អ្វីមួយ ក្រៅពីករណីដែលបានអនុញ្ញាតដោយបទបញ្ជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

បទល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល កាលបើបទល្មើសនេះត្រូវបានប្រព្រឹត្តដោយ ៖

១-បុគ្គលទទួលបន្ទុកខាងការថែរក្សាជនជាប់ឃុំ ។

២-បុគ្គលដែលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ ។

**មាត្រា ៥៨៤.-** អំពើទទួលដោយខុសច្បាប់ និងស្ថានទម្ងន់

អំពើទទួលពីអ្នកជាប់ឃុំនូវទឹកប្រាក់ លិខិតឆ្លើយឆ្លង វត្ថុ ឬសារជាតិអ្វីមួយ ក្រៅពីករណីដែលបានអនុញ្ញាតដោយបទបញ្ជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

បទល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល កាលបើបទល្មើសនេះត្រូវបានប្រព្រឹត្តដោយ ៖

១-បុគ្គលទទួលបន្ទុកខាងការថែរក្សាជនជាប់ឃុំ ។

២-បុគ្គលដែលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ ។

## ជំពូកទី ៤
## ការប៉ុនប៉ង និងទណ្ឌកម្ម

**មាត្រា ៥៨៥.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៥៨៦.-** ការលើកលែងឱ្យផុតពីទោស

រាល់បុគ្គលណា ក្នុងឋានៈជាចារី សហចារី អ្នកផ្ដើមគំនិត ឬជាអ្នកសមគំនិត ដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយដែលកំណត់នៅក្នុងមាត្រា ៥៧៣ (ទោសដែលត្រូវអនុវត្ត) និងមាត្រា ៥៧៥ (អំពើគំរាមកំហែងដោយអាវុធ ឬដោយសកម្មភាពដែលមានការព្រមព្រៀង) ដល់មាត្រា ៥៨០ (ស្ថានទម្ងន់នៃអំពើជួយសម្រួលដល់ការលួចរត់ ប្រព្រឹត្តដោយបុគ្គលដែលបានទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ) នឹងត្រូវលើកលែងឱ្យផុតពីទោស ប្រសិនបើបុគ្គលនេះបានឱ្យដំណឹងដល់អាជ្ញាធរតុលាការ ឬអាជ្ញាធររដ្ឋបាល ដើម្បីចៀសវាងកុំឱ្យការលួចរត់នេះបានសម្រេចលទ្ធផល ។

**មាត្រា ៥៨៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំយ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ៤

## ការបំពានលើសេចក្តីសម្រេចខ្លះៗ របស់តុលាការ

## ជំពូកទោល

## ការមិនអនុវត្តទោសខ្លះៗ ដែលកំណត់ដោយតុលាការ

**មាត្រា ៥៨៨.-** អំពើរំលោភបំពានបំរាមស្នាក់នៅ

អំពើរបស់ជនដែលត្រូវហាមឃាត់ពីការស្នាក់អាស្រ័យនៅ ដែលបញ្ញត្តិដោយអាជ្ញាធរតុលាការ ហើយមានមុខនៅកន្លែងដែលគេហាមឃាត់ដល់ខ្លួននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៨៩.-** ការមិនគោរពតាមវិធានការត្រួតពិនិត្យ

អំពើរបស់ជនដែលត្រូវហាមឃាត់ពីការស្នាក់អាស្រ័យនៅ ដែលគេចវេះពីវិធានការត្រួតពិនិត្យ ដែលបញ្ញត្តិដោយអាជ្ញាធរតុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៩០.-** ការរំលោភបំពានទោសបិទផ្សាយ

នៅក្នុងករណីដែលទោសបិទផ្សាយសេចក្តីសម្រេចរបស់តុលាការ ត្រូវបានប្រកាស អំពើបំបាត់ចោល លាក់បំបាំង ឬហែកចោល ប័ណ្ណប្រកាសត្រូវផ្តន្ទាទោស

ដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥៩១.-** ការរំលោភបំពានទោសហាមឃាត់ផ្នែកវិជ្ជាជីវៈ

នៅក្នុងករណីដែលទោសហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ត្រូវបានប្រកាសដោយអាជ្ញាធរតុលាការ អំពើបំពានលើការហាមឃាត់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៩២.-** ការរំលោភបំពានទោសដែលកម្រិតសិទ្ធិខ្លះ

គ្រប់ការបំពានដោយទណ្ឌិតទៅលើកាតព្វកិច្ច ឬការហាមឃាត់ ដែលជាលទ្ធផលនៃទោសព្យួរលិខិតបើកបរ ទោសហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ទោសហាមឃាត់ចំពោះការចេញមូលប្បទានប័ត្រ ទោសបិទទ្វារគ្រឹះស្ថាន ឬទោសបណ្តេញចេញពីអាបណសញ្ញាសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៩៣.-** ការមិនគោរពការរឹបអូស

អំពើបំផ្លិចបំផ្លាញ លាក់បំបាំង ឬគៃបំបាត់វត្ថុដែលរឹបអូស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៩៤.-** ការបដិសេធប្រគល់ប័ណ្ណបើកបរ

អំពើមិនព្រមប្រគល់ឱ្យដល់អាជ្ញាធរមានសមត្ថកិច្ច នូវលិខិតបើកបរដែលព្យួរ ឬវត្ថុដែលរឹបអូសនោះ ដោយមិនគោរពតាមសេចក្តីសម្រេចរបស់តុលាការ ដែលមានអានុភាពអនុវត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៩៥.-** ការរំលោភកាតព្វកិច្ចការងារសហគមន៍

អំពើបំពានដោយទណ្ឌិតទៅលើកាតព្វកិច្ច ដែលជាលទ្ធផលនៃទោសការងារសហគមន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៩៦.-** ការរំលោភកាតព្វកិច្ចដែលប្រកាសប្រឆាំងនឹងនីតិបុគ្គល

កាលបើកាតព្វកិច្ច ឬការហាមឃាត់ត្រូវបានប្រកាសទៅលើនីតិបុគ្គល ការបំពានដោយរូបវន្តបុគ្គលដែលមានសមត្ថកិច្ចចំពោះកាតព្វកិច្ច ឬការហាមឃាត់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៩៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

# គន្ថីទី ៣
## ការប៉ះពាល់ដល់និយ័តភាពនៃការបោះឆ្នោត
## មាតិកាទោល
## ការប៉ះពាល់ដល់និយ័តភាពនៃការបោះឆ្នោត
## ជំពូកទោល
## ការប៉ះពាល់ដល់និយ័តភាពនៃការបោះឆ្នោត

**មាត្រា ៥៩៨.-** ការប៉ះពាល់ដល់ការអនុវត្តដោយសេរីនូវសិទ្ធិបោះឆ្នោត និងស្ថានទម្ងន់

អំពើប៉ះពាល់ដល់ការប្រើប្រាស់ដោយសេរីនូវសិទ្ធិបោះឆ្នោត ឬដល់និយ័តភាពនៃការបោះឆ្នោត ដោយប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬឧបាយកលទុច្ចរិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើបទល្មើសនេះបានប្រព្រឹត្តដោយមានការប្រើអាវុធ ។

**មាត្រា ៥៩៩.-** ការឃោសនាដំណឹងក្លែង ដើម្បីញុាំងកុំឱ្យមានការបោះឆ្នោត

អំពើឃោសនាអំពីដំណឹងក្លែង ដើម្បីញុាំងអ្នកបោះឆ្នោតកុំឱ្យទៅបោះឆ្នោត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦០០.-** ការចូលរួមក្នុងការបោះឆ្នោត ដោយគ្មានសិទ្ធិបោះឆ្នោត

អំពើប្រព្រឹត្តដោយបុគ្គលដែលគ្មានសិទ្ធិបោះឆ្នោត ទៅចូលរួមក្នុងការបោះឆ្នោត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦០១.-** ការចូលរួមក្នុងការបោះឆ្នោត ដោយប្រើអត្តសញ្ញាណក្លែង

អំពើចូលរួមក្នុងការបោះឆ្នោតដោយប្រើអត្តសញ្ញាណក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦០២.-** ការបញ្ចុះអ្នកបោះឆ្នោត ដោយបេក្ខជន

អំពើរបស់បេក្ខជន ដែលប្រគល់ដល់អ្នកបោះឆ្នោត នូវអំណោយ ឬជំនូន ឬយល់ព្រមផ្តល់អត្ថប្រយោជន៍អ្វីមួយដើម្បីទទួលបានការបោះឆ្នោតមួយជាប្រយោជន៍ដល់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៦០៣.-** ការក្លែងលទ្ធផលបោះឆ្នោត ដោយអ្នកមានភារកិច្ចរាប់សន្លឹកឆ្នោត

អំពើរបស់បុគ្គលទទួលបន្ទុកធ្វើការរាប់សន្លឹកឆ្នោត ឬត្រួតពិនិត្យការបោះឆ្នោតដែលក្លែងលទ្ធផលបោះឆ្នោតតាមមធ្យោបាយណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦០៤.-** ការសម្លុតដល់សមាជិកនៃការិយាល័យបោះឆ្នោត

គ្រប់អំពើសម្លុតចំពោះសមាជិកការិយាល័យបោះឆ្នោត ដើម្បីជះឥទ្ធិពលទៅលើការប្រព្រឹត្តរបស់ខ្លួននៅក្នុងការបំពេញមុខងាររបស់ខ្លួននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦០៥.-** ការក្លែងលទ្ធផលបោះឆ្នោត ដោយអ្នកមានភារកិច្ចរាប់សន្លឹកឆ្នោត

ដោយមិនទាន់គិតដល់ទោសទោសដែលធ្ងន់ជាងនេះទៀត ដែលបញ្ញត្តិដោយក្រមនេះ អំពើហិង្សាដោយចេតនាទៅលើសមាជិកការិយាល័យបោះឆ្នោត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦០៦.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៦០៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំយ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៦០៨.-** ការលួចហិបឆ្នោត

ដោយមិនទាន់គិតដល់ទោសទោសដែលធ្ងន់ជាងនេះទៀត ដែលបញ្ញត្តិដោយក្រមនេះ ការលួចហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅក្នុងនោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦០៩.-** ការបំផ្លាញ ឬធ្វើឱ្យខូចខាតហិបឆ្នោត

ដោយមិនទាន់គិតដល់ទោសទោសដែលធ្ងន់ជាងនេះទៀត ដែលបញ្ញត្តិដោយក្រមនេះ អំពើប្រព្រឹត្តដោយចេតនា ដើម្បីបំផ្លាញ ធ្វើឱ្យខូចខាត ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅក្នុងនោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

# គន្ថីទី ៤
# ការប៉ះពាល់ដល់ដំណើរការរបស់រដ្ឋបាល
## មាតិកាទី ១
## ការប៉ះពាល់ដល់រដ្ឋបាល ដោយអ្នកតំណាងអាជ្ញាធរសាធារណៈ
### ជំពូកទី ១
### ការមិនគោរពភារកិច្ច
#### ផ្នែកទី ១
#### ការរំលោភអំណាច

**មាត្រា ៦១០.-** ការចាត់វិធានការសំដៅរារាំងការអនុវត្តច្បាប់ និងស្ថានទម្ងន់

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋទទួលអាណត្តិសាធារណៈតាមការបោះឆ្នោតនៅក្នុងក្របខ័ណ្ឌ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ចាត់វិធានការសម្រាប់រារាំងការអនុវត្តច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះមានប្រសិទ្ធភាព ។

**មាត្រា ៦១១.-** ការបន្តអនុវត្តមុខងារដោយខុសច្បាប់

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋទទួលអាណត្តិសាធារណៈតាមការបោះឆ្នោតនៅតែបន្តបំពេញមុខងាររបស់ខ្លួន នៅពេលដែលមុខងារនេះត្រូវបានបញ្ចប់ហើយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

## ផ្នែកទី ២
## ការរំលោភអំណាចប្រឆាំងនឹងបុគ្គល

**មាត្រា ៦១២.-** ការប៉ះពាល់ដល់សេរីភាពបុគ្គល

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋទទួលអាណត្តិសាធារណៈតាមការបោះឆ្នោតនៅក្នុងក្របខ័ណ្ឌ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន នៅតែបំពេញដោយខុសច្បាប់នូវកិច្ចការដែលប៉ះពាល់ដល់សេរីភាពឯកត្តជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦១៣.-** ការមិនព្រមដោះលែងបុគ្គលដែលត្រូវបានឃុំដោយខុសច្បាប់

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋទទួលអាណត្តិសាធារណៈតាមការបោះឆ្នោតដែលបានដឹងនៅក្នុងក្របខ័ណ្ឌ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន នូវការដកហូតសេរីភាពដោយខុសច្បាប់នៅតែមិនព្រមបញ្ឈប់ដោយចេតនានូវការដកហូតសេរីភាពនេះទេ ប្រសិនបើខ្លួនជាអ្នកមានអំណាចដើម្បីបញ្ឈប់ការដកហូតសេរីភាពនេះ ឬមិនព្រមសុំឱ្យមានអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦១៤.-** ការឃុំ ឬដោះលែងដោយខុសច្បាប់

អំពើរបស់ភ្នាក់ងាររដ្ឋបាលខាងពន្ធនាគារដែលទទួលឃុំខ្លួន ឬដោះលែងបុគ្គលណាមួយដោយគ្មានដីកា សាលដីកា សាលក្រមបញ្ជាឱ្យឃុំខ្លួន ឬដោះលែងដែលធ្វើឡើងស្របច្បាប់នោះទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦១៥.-** ការអូសបន្លាយការឃុំខ្លួនដោយខុសច្បាប់

អំពើរបស់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ ដែលពន្យារដោយខុសច្បាប់នូវរយៈពេលនៃការឃុំខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

## ជំពូកទី ២
## អំពើពុករលួយ និងបទល្មើសប្រហាក់ប្រហែល
### ផ្នែកទី ១
### វិតិក្រម

**មាត្រា ៦១៦.-** និយមន័យនៃវិតិក្រម

វិតិក្រម គឺជាអំពើរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែល :

១-ទាមទារ ឬទទួល ជាសិទ្ធិ ជាពន្ធ ជាអាករ នូវចំនួនទឹកប្រាក់ដែលខ្លួនបានដឹងថាមិនត្រូវបង់ ឬដែលលើសពីចំនួនដែលគេត្រូវបង់ ។

២-យល់ព្រមក្រោមរូបភាពណាមួយ និងដោយមូលហេតុណាមួយក៏ដោយ ដោយធ្វើការលើកលែង ឬការលោះលាចំពោះការបង់ពន្ធ ឬអាករដែលខ្លួនដឹងថាខុសច្បាប់ ។

**មាត្រា ៦១៧.-** ទោសដែលត្រូវអនុវត្ត

បទវិតិក្រម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

## ផ្នែកទី ២
## អំពើស៊ីសំណូក

**មាត្រា ៦១៨.-** អំពើស៊ីសំណូក

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត ដែលទទូចសុំ ឬយល់ព្រមទទួលដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោល នូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយ ដើម្បី :

១-បំពេញកិច្ចនៃមុខងាររបស់ខ្លួនដែលបង្កភាពងាយស្រួលដោយមុខងាររបស់ខ្លួន ។

២-មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួនដែលបង្កភាពងាយស្រួលដោយមុខងាររបស់ខ្លួន ។

## ផ្នែកទី ៣
## ជំនួញឥទ្ធិពលអកម្ម

**មាត្រា ៦១៩.-** និយមន័យនៃជំនួញឥទ្ធិពល

ជំនួញឥទ្ធិពលអកម្ម គឺជាអំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត ដែលទទូចសុំ ឬយល់ព្រមទទួលដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោល នូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយ ដើម្បីទទួលបានពីស្ថាប័នរដ្ឋ ដោយសារឥទ្ធិពលពិតប្រាកដ ឬសន្មតនូវការងារ អាបណសញ្ញា គ្រឿងសម្គាល់ ឬសេចក្តីសម្រេចអនុគ្រោះផ្សេងៗដទៃទៀត ។

**មាត្រា ៦២០.-** ទោសដែលត្រូវអនុវត្ត

ជំនួញឥទ្ធិពលអកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

## ផ្នែកទី ៤
## ការកេងយកផលប្រយោជន៍ដោយខុសច្បាប់

**មាត្រា ៦២១.-** និយមន័យនៃការកេងយកផលប្រយោជន៍ដោយខុសច្បាប់

ការកេងយកផលប្រយោជន៍ដោយខុសច្បាប់ គឺជាអំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត ដែលយក ទទួល ឬរក្សាទុកដោយផ្ទាល់ ឬដោយប្រយោលនូវផលប្រយោជន៍អ្វីមួយនៅក្នុង :

១-សហគ្រាសណាមួយ ដែលអ្នករាជការ ឬពលរដ្ឋនោះមានភារកិច្ចរ៉ាប់រងទាំងស្រុង ឬមួយផ្នែកនូវការឃ្លាំតាមដាន ការគ្រប់គ្រង ឬការជម្រះបញ្ជី ។

២-ប្រតិបត្តិការណាមួយ ដែលអ្នករាជការ ឬពលរដ្ឋនោះមានភារកិច្ចរ៉ាប់រងទាំងស្រុង ឬមួយផ្នែកនូវការឃ្លាំតាមដាន ឬការទូទាត់ ។

**មាត្រា ៦២២.-** ទោសដែលត្រូវអនុវត្ត

ការកេងយកផលប្រយោជន៍ខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

## ផ្នែកទី ៥
## ការត្រួតសកម្មភាពដោយខុសច្បាប់

**មាត្រា ៦២៣.-** ការត្រួតសកម្មភាពដោយខុសច្បាប់

អំពើរបស់អ្នករាជការសាធារណៈ ដែលធ្វើដោយផ្ទាល់ ឬដោយប្រយោលនូវសកម្មភាពពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

## ផ្នែកទី ៦
## បក្ខានុគ្រោះ

**មាត្រា ៦២៤.-** និយមន័យនៃបក្ខានុគ្រោះ

បក្ខានុគ្រោះ គឺជាអំពើរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលផ្តល់ឱ្យដោយខុសច្បាប់ នូវអត្ថប្រយោជន៍ដល់អ្នកដទៃ នៅក្នុងឱកាសនៃការធ្វើអាបណសញ្ញាសាធារណៈ ។

**មាត្រា ៦២៥.-** ទោសដែលត្រូវអនុវត្ត

បក្ខានុគ្រោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

## ជំពូកទី ៣
## ការបំផ្លាញ និងការបន្លំ

**មាត្រា ៦២៦.-** អំពើបំផ្លាញ និងកែបំបាត់ដោយចេតនា

អ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែលគ្រប់គ្រងនូវលិខិត ប័ណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗ ទៀត ដោយមូលហេតុនៃមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើអ្នករាជការ ឬពលរដ្ឋនោះបំផ្លាញចោលដោយចេតនា ឬកែបំបាត់ដោយទុច្ចរិតនូវលិខិត ប័ណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗ ទៀតនោះ ។

**មាត្រា ៦២៧.-** ការធ្វើឱ្យខូចខាត ឬឱ្យបាត់បង់ដោយអចេតនា

អ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែលគ្រប់គ្រងនូវលិខិត ប័ណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗ ទៀត ដោយមូលហេតុនៃមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី

១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ប្រសិនបើអ្នករាជការ ឬពលរដ្ឋនោះ ធ្វើឱ្យខូចខាត ឬធ្វើឱ្យបាត់បង់ដោយអចេតនានូវលិខិត ប័ណ្ណ មូលនិធិសាធារណៈ មូលនិធិ ឯកជន ឬវត្ថុអ្វីផ្សេងៗ ទៀតនោះ ។

## ជំពូកទី ៤
## ការប៉ុនប៉ង និងទណ្ឌកម្ម
### ផ្នែកទី ១
### ការប៉ុនប៉ង

**មាត្រា ៦២៨.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងមាតិកានេះ លើកលែងតែបទមជ្ឈិមដែលមានចែងនៅក្នុងមាត្រា ៦១៣ (ការមិនព្រមដោះលែងបុគ្គលដែលត្រូវបានឃុំដោយខុសច្បាប់) និងមាត្រា ៦២៧ (ការធ្វើឱ្យខូចខាត ឬឱ្យបាត់បង់ដោយអចេតនា) ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

### ផ្នែកទី ២
### ទោសបន្ថែម

**មាត្រា ៦២៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៥-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៨-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ២

## ការប៉ះពាល់ដល់រដ្ឋបាលសាធារណៈ ធ្វើឡើងដោយបុគ្គលឯកជន

## ជំពូកទី ១

## អំពើពុករលួយ និងបទល្មើសប្រហាក់ប្រហែល

## ផ្នែកទី ១

## អំពើសូកប៉ាន់

**មាត្រា ៦៣០.-** អំពើសូកប៉ាន់

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បុគ្គលដែលគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោល ប្រគល់អំណោយ ឬជំនូនដល់អ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ធ្វើការសន្យាជាមួយ ឬផ្ដល់អត្ថប្រយោជន៍អ្វីមួយដើម្បីឱ្យអ្នករាជការ ឬពលរដ្ឋជាប់ឆ្នោតនោះ :

១-បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬសម្រួលបានដោយសារមុខងាររបស់ខ្លួន ។

២-មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬសម្រួលបានដោយសារមុខងាររបស់ខ្លួន ។

## ផ្នែកទី ២
## ជំនួញឥទ្ធិពលសកម្ម

**មាត្រា ៦៣១.-** ជំនួញឥទ្ធិពលសកម្ម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បុគ្គលដែលគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោល ប្រគល់អំណោយ ឬជំនូនដល់អ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ធ្វើការសន្យាជាមួយ ឬផ្តល់អត្ថប្រយោជន៍អ្វីមួយដល់អ្នករាជការ ឬពលរដ្ឋនោះ ដើម្បីទទួលបានពីស្ថាប័នរដ្ឋដោយសារឥទ្ធិពលពិតប្រាកដ ឬដោយសន្មតរបស់អ្នករាជការ ឬពលរដ្ឋជាប់ឆ្នោតនោះនូវមុខរបរ អាបណសញ្ញា សញ្ញាសម្គាល់កិត្តិយស ឬសេចក្តីសម្រេចអនុគ្រោះផ្សេងទៀត ។

## ផ្នែកទី ៣
## អំពើសម្លុតគំរាម

**មាត្រា ៦៣២.-** អំពើសម្លុតគំរាម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើសម្លុតគំរាម ដែលអនុវត្តទៅលើអ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បី :

១-ឱ្យអ្នករាជការ ឬពលរដ្ឋដែលជាប់ឆ្នោតនោះបំពេញកិច្ចនៃមុខងាររបស់ខ្លួន ។

២-កុំឱ្យអ្នករាជការ ឬពលរដ្ឋដែលជាប់ឆ្នោតនោះបំពេញកិច្ចនៃមុខងាររបស់ខ្លួន ។

៣-ឱ្យអ្នករាជការ ឬពលរដ្ឋដែលជាប់ឆ្នោតនោះរំលោភឥទ្ធិពលរបស់ខ្លួន ដែលមានពិតប្រាកដ ឬដោយសន្មត ដើម្បីនឹងទទួលបានពីរាជការនូវមុខរបរ អាជ្ញាបណ្ណ សញ្ញាសម្គាល់ ឬសេចក្ដីសម្រេចអនុគ្រោះផ្សេងទៀត ។

## ជំពូកទី ២
## ការបំផ្លាញ និងការគៃបំបាត់

**មាត្រា ៦៣៣.-** អំពើបំផ្លិចបំផ្លាញ និងគៃបំបាត់

អំពើបំផ្លិចបំផ្លាញ គៃបំបាត់ ឬលួចយកលិខិត ប័ណ្ណ មូលនិធិសាធារណៈ ឬឯកជន ឬវត្ថុអ្វីផ្សេងៗ ទៀត ដែលរក្សាទុកដោយអ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដោយមូលហេតុនៃមុខងាររបស់ខ្លួននោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

## ជំពូកទី ៣
## ការជ្រៀតជ្រែកក្នុងមុខងារសាធារណៈ និងតំណែងផ្លូវការ

**មាត្រា ៦៣៤.-** អំពើជ្រៀតជ្រែកដោយខុសច្បាប់ទៅក្នុងការបំពេញមុខងារសាធារណៈ

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើជ្រៀតជ្រែកដោយខុសច្បាប់ទៅក្នុងការអនុវត្តមុខងារសាធារណៈណាមួយ ដោយបំពេញកិច្ចណាមួយក្នុងចំណោមកិច្ចទាំងឡាយ ដែលសម្រាប់តែអ្នកមានសិទ្ធិក្នុងមុខងារនេះ ។

**មាត្រា ៦៣៥.-** សកម្មភាពបង្កើតឱ្យមានការយល់ច្រឡំជាមួយការបំពេញមុខងារសាធារណៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល បុគ្គលដែលធ្វើសកម្មភាពនៅក្នុងលក្ខខណ្ឌ ដែលអាចនាំឱ្យសាធារណជនយល់ច្រឡំថាជាការបំពេញមុខងារសាធារណៈ ។

**មាត្រា ៦៣៦.-** ការប្រើប្រាស់លិខិត ឬឯកសារដែលបង្កើតឱ្យមានការភ័ន្តច្រឡំ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រើប្រាស់ដោយគ្មានសិទ្ធិនូវលិខិត ឬឯកសារ ដែលមានភាពប្រហាក់ប្រហែលគ្នានឹងលិខិតរដ្ឋបាល ឬតុលាការ ដែលអាចនឹងបង្កើតឱ្យមានការភ័ន្តច្រឡំនៅក្នុងស្មារតីនៃសាធារណជន ។

**មាត្រា ៦៣៧.-** ការប្រើប្រាស់ដោយខុសច្បាប់ជាអាទិ៍ នូវសំលៀកបំពាក់សម្រាប់អាជ្ញាធរសាធារណៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើស្លៀកពាក់ជាសាធារណៈ ដោយគ្មានសិទ្ធិនឹងស្លៀកពាក់នូវសំលៀកបំពាក់ ឯកសណ្ឋាន ឬគ្រឿងឥស្សរិយយស សម្រាប់អាជ្ញាធរសាធារណៈ ។

**មាត្រា ៦៣៨.-** ការប្រើប្រាស់ដោយខុសច្បាប់នូវឯកសារបញ្ជាក់វិជ្ជាជីវៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រើប្រាស់ជាសាធារណៈ ដោយគ្មានសិទ្ធិនូវឯកសារបញ្ជាក់វិជ្ជាជីវៈ ដែលកំណត់ដោយអាជ្ញាធរសាធារណៈ ។

**មាត្រា ៦៣៩.-** ការប្រើប្រាស់ដោយគ្មានសិទ្ធិនូវសញ្ញាសម្គាល់ដែលកំណត់ដោយអាជ្ញាធរសាធារណៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រើប្រាស់ជាសាធារណៈ ដោយគ្មានសិទ្ធិ នូវសញ្ញាសម្គាល់ដែលកំណត់ដោយអាជ្ញាធរសាធារណៈ ។

**មាត្រា ៦៤០.-** ការប្រើប្រាស់ដោយគ្មានសិទ្ធិនូវរថយន្តដែលមានស្លាកសញ្ញាដូចនគរបាល ឬយោធិន

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រើប្រាស់ដោយគ្មានសិទ្ធិនូវយានយន្ត ដែលមានសញ្ញាសម្គាល់ខាងក្រៅដូចគ្នានឹងសញ្ញាដែលប្រើប្រាស់ដោយភ្នាក់ងារនគរបាល ឬយោធិន ។

**មាត្រា ៦៤១.-** ការប្រើប្រាស់នូវឯកសណ្ឋានជាអាទិ៍ ដែលមានលក្ខណៈដូចនគរបាល ឬយោធា

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រើប្រាស់ជាសាធារណៈ ដោយគ្មានសិទ្ធិនូវសំលៀកបំពាក់ ឯកសណ្ឋាន អត្តសញ្ញាណប័ណ្ណ សញ្ញាសម្គាល់ ឬរថយន្តនគរបាល ឬយោធា មានភាពប្រហាក់ប្រហែលគ្នានឹងសំលៀកបំពាក់ ឯកសណ្ឋាន អត្តសញ្ញាណប័ណ្ណ សញ្ញាសម្គាល់ ឬរថយន្តនគរបាល ឬយោធា ដែលអាចនាំឱ្យមានការភ័ន្តច្រឡំក្នុងស្មារតីនៃសាធារណជន ។

**មាត្រា ៦៤២.-** ស្ថានទម្ងន់ដោយសារមានការត្រៀមរៀបចំបទឧក្រិដ្ឋ ឬបទមជ្ឈិម

បទល្មើសដែលមានចែងនៅក្នុងមាត្រា ៦៣៦ (ការប្រើប្រាស់លិខិត ឬឯកសារដែលបង្កើតឱ្យមានការភ័ន្តច្រឡំ) ដល់មាត្រា ៦៤១ (ការប្រើប្រាស់នូវឯកសណ្ឋាន

ជាអាទិ៍ ដែលមានលក្ខណៈដូចនគរបាល ឬយោធា) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជា ប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦៤៣.-** ការប្រើប្រាស់ដោយគ្មានសិទ្ធិនូវប័ណ្ណបញ្ជាក់តួនាទីក្នុងវិជ្ជាជីវៈកំណត់ដោយអាជ្ញាធរសាធារណៈ

អំពើប្រើប្រាស់ ដោយគ្មានសិទ្ធិ នូវប័ណ្ណបញ្ជាក់តួនាទីក្នុងវិជ្ជាជីវៈណាមួយ ដែលកំណត់ដោយអាជ្ញាធរសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជា ប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦៤៤.-** ការប្រើប្រាស់ដោយគ្មានសិទ្ធិនូវសញ្ញាប័ត្រ

អំពើប្រើប្រាស់ ដោយគ្មានសិទ្ធិនូវសញ្ញាប័ត្រ ឬគុណសម្បត្តិ ដែលលក្ខខណ្ឌនៃការប្រគល់ត្រូវបានកំណត់ដោយអាជ្ញាធរសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជា ប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦៤៥.-** ការប្រើប្រាស់ដោយមិនប្រក្រតីនូវឋានៈណាមួយ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជា ប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រព្រឹត្តដោយអ្នកដឹកនាំសហគ្រាសណាមួយ ដែលធ្វើឱ្យមាន ឬដោយទុកឱ្យមាននៅក្នុងការផ្សព្វផ្សាយ ដើម្បីជាអត្ថប្រយោជន៍នៃសហគ្រាសនេះ នូវឈ្មោះ និងឋានៈរបស់សមាជិក ឬអតីតសមាជិករបស់រាជរដ្ឋាភិបាល សមាជិក ឬអតីតសមាជិករបស់សភា ចៅក្រម ឬអតីតចៅក្រម ។

**មាត្រា ៦៤៦.-** ការប្រើប្រាស់អត្តសញ្ញាណខុសពីអត្តសញ្ញាណផ្លូវការក្នុងកិច្ចសាធារណៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យ

ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល អំពើដែលយកអត្តសញ្ញាណណាមួយ ដែលខុសពីអត្តសញ្ញាណរបស់ខ្លួនជាផ្លូវការ នៅក្នុងលិខិតជាសាធារណៈ ឬដែលសម្រាប់ជូនអាជ្ញាធរសាធារណៈ ។

# ជំពូកទី ៤
# បទល្មើសផ្សេងៗ ទៀត
## ផ្នែកទី ១
## ការរំលោភបទបញ្ជា

**មាត្រា ៦៤៧.-** ការរំលោភបទបញ្ជា

រាល់បុគ្គលណាដែលរំលោភលើបទបញ្ជារបស់អាជ្ញាធររដ្ឋបាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។ ប៉ុន្តែអំពើនេះមិនពេញលក្ខណៈជាបទល្មើសទេ ប្រសិនបើបទបញ្ជានេះផ្ទុយនឹងច្បាប់ ។

## ផ្នែកទី ២
## ការបំលាស់ទីនៃសីមាចារិក

**មាត្រា ៦៤៨.-** ការបំលាស់ទីនៃសីមាចារិក

អំពើដក ឬផ្លាស់ប្តូរទីកន្លែងនៃសីមាចារិក ដែលដាក់ដោយអាជ្ញាធរសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

# ជំពូកទី ៥
# ការប៉ុនប៉ង និងទណ្ឌកម្ម

**មាត្រា ៦៤៩.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងមាតិកានេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៦៥០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៥-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៦៥១.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមាន ចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើស ដែលបញ្ញត្តិក្នុងមាត្រា ៦៣០ (អំពើស្វកប៉ាន់) មាត្រា ៦៣១ (ជំនួញឥទ្ធិពលសកម្ម) និងមាត្រា ៦៣២ (អំពើសម្លុតគំរាម) នៃក្រមនេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ១០.០០០.០០០ (ដប់លាន) ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្តេញចេញពីអាបណសញ្ញា តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) ។

៦-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៨-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

៩-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

# គន្ថីទី ៥

# ការប៉ះពាល់ដល់ទំនុកចិត្តសាធារណៈ

## មាតិកាទី ១

## ការក្លែងបន្លំ

### ជំពូកទី ១

### ការក្លែងឯកសារ

**មាត្រា ៦៥២.-** ធាតុផ្សំនៃការក្លែងបន្លំ

ការក្លែងបន្លំ គឺជាការធ្វើឱ្យខូចខាតដោយចេតនានូវការពិត ដែលសំដែងចេញជាក់ស្តែងនៅក្នុងលិខិត ឬតាមមធ្យោបាយដទៃទៀតនៃការសំដែងនូវគំនិត កាលបើមានគ្រប់លក្ខខណ្ឌដូចតទៅ :

១-ការធ្វើឱ្យខូចនេះមានកម្មវត្ថុ ឬអាចមានអានុភាពធ្វើជាភស្តុតាងនៃសិទ្ធិ ឬនៃអំពើដែលមានផលវិបាកគតិយុត្តិ ។

២-ការធ្វើឱ្យខូចនេះអាចបណ្តាលឱ្យមានព្យសនកម្ម ។

**មាត្រា ៦៥៣.-** ទោសដែលត្រូវអនុវត្ត

ការក្លែងបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦៥៤.-** ការប្រើប្រាស់លិខិតក្លែង

ការប្រើប្រាស់លិខិតក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦៥៥.-** ការក្លែងបន្លំចំពោះឯកសារសាធារណៈ

ការក្លែងបន្លំប្រព្រឹត្តនៅក្នុងលិខិតយថាភូត ឬការក្លែងបន្លំប្រព្រឹត្តនៅក្នុងឯកសារដែលចេញឱ្យដោយរាជការសាធារណៈ ដើម្បីកត់សម្គាល់នូវសិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬយល់ព្រមផ្ដល់ការអនុញ្ញាត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៦៥៦.-** ការប្រើប្រាស់ឯកសារសាធារណៈដែលក្លែង

ការប្រើប្រាស់ឯកសារក្លែងបន្លំ ដែលមានចែងក្នុងមាត្រា ៦៥៥ (ការក្លែងបន្លំចំពោះឯកសារសាធារណៈ) ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៥៧.-** ការផ្ដល់ឯកសារដោយទុច្ចរិត

អំពើផ្ដល់ដល់អ្នកដទៃដោយទុច្ចរិត នូវឯកសារដែលចេញដោយរាជការសាធារណៈ ដើម្បីធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬយល់ព្រមផ្ដល់ការអនុញ្ញាត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៥៨.-** ការធ្វើឱ្យផ្ដល់មកខ្លួននូវឯកសារដោយទុច្ចរិត

អំពើដែលសុំដោយទុច្ចរិតឱ្យរាជការសាធារណៈចេញ នូវឯកសារសម្រាប់ធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬយល់ព្រមផ្ដល់ការអនុញ្ញាត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៦៥៩.-** ការធ្វើប្រតិវេទន៍ដោយភូតភរ

អំពើផ្ដល់ប្រតិវេទន៍ដោយភូតកុហកដល់រាជការសាធារណៈ ដើម្បីទទួលបានវិភាជន៍ការបើកប្រាក់ ឬអត្ថប្រយោជន៍ដោយខុសច្បាប់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ

ពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៦៦០.-** អំពើផ្ដល់លិខិតបញ្ជាក់ក្លែងក្លាយ

ក្រៅពីករណីដែលបញ្ញត្តិក្នុងជំពូកនេះ អំពើដែលធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនប័ត្រ ដែលរៀបរាប់ពីការណភាព ដែលតាមជាក់ស្ដែងមិនមែនជាការពិត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦៦១.-** អំពើក្លែងលិខិតបញ្ជាក់

អំពើក្លែង ឬបន្លំលិខិតបញ្ជាក់ ឬវិញ្ញាបនប័ត្រ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦៦២.-** ការប្រើប្រាស់លិខិតបញ្ជាក់មិនពិត ឬលិខិតបញ្ជាក់ក្លែងក្លាយ

ការប្រើប្រាស់លិខិតបញ្ជាក់មិនពិត ឬក្លែងក្លាយ ឬវិញ្ញាបនប័ត្រមិនពិត ឬក្លែងក្លាយ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦៦៣.-** អំពើស៊ីសំណូកដោយអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើរបស់បុគ្គល ដែលប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនដោយទទួចសុំ ឬយល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនប័ត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្ដែងមិនមែនជាការពិត ។

**មាត្រា ៦៦៤.-** អំពើសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើប្រគល់អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ឱ្យបុគ្គលណាម្នាក់ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនប័ត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត ។

**មាត្រា ៦៦៥.-** អំពើស៊ីសំណូកដោយសមាជិកនៃអង្គសុខាភិបាលដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើរបស់គ្រូពេទ្យ ឬបុគ្គលដែលជាសមាជិកអង្គសុខាភិបាល ដែលទទួចសុំ ឬយល់ព្រមទទួល អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនប័ត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត ។

**មាត្រា ៦៦៦.-** អំពើសូកប៉ាន់ចំពោះសមាជិកអង្គសុខាភិបាលដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើប្រគល់អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដល់គ្រូពេទ្យ ឬបុគ្គលដែលជាសមាជិកនៃគណៈគ្រូពេទ្យ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនប័ត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត ។

**មាត្រា ៦៦៧.-** ការអនុវត្តបទមជ្ឈិមនៃមាត្រា ៦៦៥ និងមាត្រា ៦៦៦ចំពោះគ្រប់វិជ្ជាជីវៈខាងសុខភាព

បទប្បញ្ញត្តិនៃមាត្រា ៦៦៥ (អំពើស៊ីសំណូកដោយសមាជិកនៃអង្គសុខាភិបាលដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) និងមាត្រា ៦៦៦ (អំពើសូកប៉ាន់ចំពោះសមាជិកនៃ

អង្គសុខាភិបាលដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) ត្រូវអនុវត្តទៅលើគ្រប់បុគ្គល ដែលប្រកបវិជ្ជាជីវៈផ្នែកខាងសុខភាព ។

**មាត្រា ៦៦៨.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងមាត្រា ៦៥៨ (ការធ្វើឱ្យផ្តល់មកឱ្យខ្លួននូវឯកសារដោយទុច្ចរិត) មាត្រា ៦៦៤ (អំពើសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) និងមាត្រា ៦៦៦ (អំពើសូកប៉ាន់ចំពោះសមាជិកនៃអង្គសុខាភិបាលដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៦៦៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៦៧០.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) ចំពោះបទល្មើសដែលបញ្ញត្តិក្នុងមាត្រា ៦៦៤ (អំពើសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) និងមាត្រា ៦៦៦ (អំពើសូកប៉ាន់ចំពោះសមាជិកនៃអង្គសុខាភិបាលដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ ១០.០០០.០០០ (ដប់លាន) ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ព្រមទាំងបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-រំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) ។

២-ដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) ។

៣-ហាមឃាត់ការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមចំពោះការធ្វើសកម្មភាព) ។

៤-ការបណ្ដេញចេញពីអាបណសញ្ញា តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្ដេញចេញពីអាបណសញ្ញាសាធារណៈ) ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) ។

៦-ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) ។

៨-ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) ។

៩-ចុះផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨២ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍) ។

## ជំពូកទី ២
## រូបិយវត្ថុក្លែង

**មាត្រា ៦៧១.-** ការក្លែងរូបិយវត្ថុកម្ពុជា ដែលមានតម្លៃជានីត្យានុកូល

ការក្លែង ឬបន្លំរូបិយវត្ថុ ឬធនប័ត្រ ដែលមានតម្លៃជានីត្យានុកូលនៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ៦៧២.-** ការក្លែងរូបិយវត្ថុបរទេស ដែលមានតម្លៃជានីត្យានុកូល

ការក្លែង ឬបន្លំរូបិយវត្ថុ ឬធនប័ត្រ ដែលបោះពុម្ពផ្សាយចេញដោយស្ថាប័នបរទេស ឬអន្តរជាតិ ដែលមាននីតិសម្បទាសម្រាប់រឿងនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ៦៧៣.-** ការដាក់ឱ្យធ្វើចរាចរនូវរូបិយវត្ថុក្លែង

ការដាក់ឱ្យធ្វើចរាចរនូវរូបិយវត្ថុ ឬធនប័ត្រក្លែង ឬបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តជាក្រុមមានការចាត់តាំង ។

**មាត្រា ៦៧៤.-** ការកាន់កាប់រូបិយវត្ថុក្លែង

អំពើកាន់កាប់រូបិយវត្ថុ ឬធនប័ត្រក្លែង ឬបន្លំ ដើម្បីយកទៅដាក់ឱ្យធ្វើចរាចរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៦៧៥.-** ការក្លែងរូបិយវត្ថុ ដែលអស់តម្លៃប្រើប្រាស់តាមផ្លូវច្បាប់

ការក្លែង ឬបន្លំរូបិយវត្ថុ ឬធនប័ត្រកម្ពុជា ឬបរទេសដែលលែងមានតម្លៃជានីត្យានុកូលទៀតនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៧៦.-** ការកាន់កាប់ដោយខុសច្បាប់នូវសម្ភារៈសម្រាប់ផលិតរូបិយវត្ថុ

ការកាន់កាប់ដោយគ្មានការអនុញ្ញាត នូវឧបករណ៍ និងសម្ភារៈដែលជាពិសេសសម្រាប់ធ្វើធនប័ត្រ និងរូបិយវត្ថុ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦៧៧.-** ការដាក់ឱ្យធ្វើចរាចរជាថ្មី នូវរូបិយវត្ថុក្លែង

អំពើរបស់បុគ្គលណាដែលបានទទួលរូបិយវត្ថុ ឬធនប័ត្រក្លែង ឬបន្លំ ហើយយកទៅដាក់ឱ្យធ្វើចរាចរជាថ្មីដោយបានដឹងថាជារបស់ក្លែង ឬបន្លំនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៦៧៨.-** ការលើកលែងឱ្យផុតពីទោស

បុគ្គលណាដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ នឹងត្រូវបានលើកលែងឱ្យផុតពីទោស ប្រសិនបើបុគ្គលនោះ បានធ្វើឱ្យបទល្មើសមិនបានសម្រេច និងនាំឱ្យដឹងពីអត្តសញ្ញាណជាយថាហេតុរបស់ជនល្មើសផ្សេងៗ ទៀត ដោយបានឱ្យដំណឹងដល់អាជ្ញាធររដ្ឋបាល ឬតុលាការ ។

**មាត្រា ៦៧៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ២

## ការក្លែងឯកសាររបស់អាជ្ញាធរសាធារណៈ

## ជំពូកទី ១

## ការក្លែងប័ណ្ណ

**មាត្រា ៦៨០.-** ការក្លែងផលប័ត្រកម្ពុជា

ការក្លែង ឬបន្លំផលប័ត្រដែលបោះពុម្ពផ្សាយដោយព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងត្រារបស់ព្រះរាជាណាចក្រកម្ពុជា ឬជាមួយនឹងសញ្ញារបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៨១.-** ការក្លែងផលប័ត្របរទេស

ការក្លែង ឬបន្លំផលប័ត្រដែលបោះពុម្ពផ្សាយដោយរដ្ឋបរទេស ជាមួយនឹងត្រារបស់រដ្ឋបរទេសសម្រាប់បោះពុម្ព ឬជាមួយនឹងសញ្ញារបស់រដ្ឋបរទេសនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៨២.-** ការប្រើប្រាស់ផលប័ត្រក្លែង ឬបន្លំ

ការប្រើប្រាស់ផលប័ត្រក្លែង ឬបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៨៣.-** ការក្លែងតែមប្រៃសណីយ៍ជាអាទិ៍

ការក្លែង ឬបន្លំតែមប្រៃសណីយ៍ ឬផលិតផលដែលមានតម្លៃហិរញ្ញវត្ថុផ្សេងទៀត ដែលបោះពុម្ពផ្សាយដោយព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៨៤.-** ការប្រើប្រាស់តែមប្រៃសណីយ៍ក្លែងក្លាយជាអាទិ៍

ការប្រើប្រាស់តែមប្រៃសណីយ៍ ឬផលិតផលដែលមានតម្លៃហិរញ្ញវត្ថុផ្សេងទៀត ដែលក្លែង ឬបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៨៥.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៦៨៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការក្លែងសញ្ញាសម្គាល់របស់អាជ្ញាធរ

**មាត្រា ៦៨៧.-** ការក្លែងត្រារបស់ព្រះរាជាណាចក្រកម្ពុជា

ការក្លែង ឬបន្លំត្រារបស់ព្រះរាជាណាចក្រកម្ពុជា ត្រាជាតិ ឬត្រាផ្លូវការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៨៨.-** ការប្រើប្រាស់ត្រាក្លែង

ការប្រើប្រាស់ត្រារបស់ព្រះរាជាណាចក្រកម្ពុជា ត្រាជាតិ ឬត្រាផ្លូវការ ដែលក្លែង ឬបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៨៩.-** ការក្លែងក្រដាសដែលមានក្បាលជាផ្លូវការ

ការក្លែង ឬបន្លំក្រដាស ដែលមានក្បាលជាផ្លូវការប្រើប្រាស់ដោយអាជ្ញាធរសាធារណៈនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៩០.-** ការប្រើប្រាស់ក្រដាសដែលមានក្បាលជាផ្លូវការ

ការប្រើប្រាស់ក្រដាសក្លែង ឬបន្លំដែលមានក្បាលជាផ្លូវការប្រើប្រាស់ដោយអាជ្ញាធរសាធារណៈ ឬត្រាផ្លូវការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៩១.-** ការក្លែងក្រដាសពុម្ពឱ្យដូចគ្នានឹងក្រដាសផ្លូវការ

ការធ្វើ ការលក់ ការចែកចាយ ឬការប្រើប្រាស់ក្រដាសពុម្ព ជាមួយនឹងក្រដាសដែលមានក្បាលជាផ្លូវការប្រើប្រាស់ដោយអាជ្ញាធរសាធារណៈ ដែលមានការដូចគ្នា ហើយអាចនាំឱ្យមានការភាន់ច្រឡំនៅក្នុងស្មារតីរបស់សាធារណជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦៩២.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមដែរ ។

**មាត្រា ៦៩៣.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត ក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាគោលដៅនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធជាតិផ្ទុះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## គន្ថីទី ៦
## ការប៉ះពាល់ដល់ជីវភាពក្នុងសង្គម
## មាតិកាទោល
## ការប៉ះពាល់ដល់ជីវភាពក្នុងសង្គម
## ជំពូកទី ១
## ការប៉ះពាល់បង្កឡើងដោយសត្វ

**មាត្រា ៦៩៤.-** ការលែងសត្វឱ្យដើរទេស

អំពើរបស់ម្ចាស់ ឬអ្នកគង្វាល ដែលលែងសត្វឱ្យដើរទេស ដែលអាចនឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្ស ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ៦៩៥.-** ការពន្យុះសត្វដែលមានលក្ខណៈគ្រោះថ្នាក់

អំពើរបស់ម្ចាស់ ឬអ្នកគង្វាល ដែលពន្យុះ ឬមិនឃុំសត្វ ដែលអាចនឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្ស ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ៦៩៦.-** ការគ្រប់គ្រងសត្វជាបណ្តោះអាសន្ន

ក្នុងករណីផ្តន្ទាទោសពីបទលហុ ដែលមានចែងក្នុងមាត្រា ៦៩៤ (ការលែងសត្វឱ្យដើរទេស) និងមាត្រា ៦៩៥ (ការពន្យុះសត្វដែលមានលក្ខណៈគ្រោះថ្នាក់) តុលាការ អាចបង្គាប់ឱ្យប្រគល់សត្វនេះឱ្យទៅអាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងជាបណ្តោះអាសន្នលើសត្វនេះ ។

# ជំពូកទី ២
# កាកសំណល់ និងការរំខានផ្សេងទៀត
## ផ្នែកទី ១
## កាកសំណល់

**មាត្រា ៦៩៧.-** ការដាក់ដោយខុសច្បាប់នូវសំរាមក្នុងទីសាធារណៈ

អំពើដែលដាក់ បោះបង់ចោល ឬគ្រវែងចោលសំរាម កាកសំណល់ ឬសម្ភារៈសំណង់អ្វីមួយនៅក្នុងកន្លែងសាធារណៈក្រៅពីកន្លែងដែលចង្អុលប្រាប់ដោយរដ្ឋបាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ៦៩៨.-** ការបោះបង់ដោយខុសច្បាប់នូវកំទេចយានយន្ត និងវត្ថុក្នុងកន្លែងសាធារណៈ

អំពើដែលដាក់ បោះបង់ចោល ឬគ្រវែងចោលកំទេចកំទីយានយន្ត ឬសំរាម កាកសំណល់ ឬសម្ភារៈអ្វីមួយដែលដឹកជញ្ជូនដោយរថយន្តនៅក្នុងកន្លែងសាធារណៈក្រៅពីកន្លែងដែលចង្អុលប្រាប់ដោយរដ្ឋបាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៦៩៩.-** ការដាក់សំរាមដោយខុសច្បាប់ក្នុងទីកន្លែងឯកជន

អំពើដែលដាក់ បោះបង់ចោល ឬគ្រវែងចោលសំរាម កាកសំណល់ ឬសម្ភារៈសំណង់អ្វីមួយនៅក្នុងកន្លែងឯកជន ដោយគ្មានការអនុញ្ញាតពីអ្នកកាន់កាប់ទីកន្លែង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ៧០០.-** ការបោះបង់ដោយខុសច្បាប់នូវកំទេចយានយន្ត និងវត្ថុក្នុងកន្លែងឯកជន

អំពើដែលដាក់ បោះបង់ចោល ឬគ្រវែងកំទេចកំទីយានយន្ត ឬសំរាម កាកសំណល់ ឬសម្ភារៈអ្វីមួយដែលដឹកជញ្ជូនដោយរថយន្តនៅក្នុងកន្លែងឯកជន

ដោយគ្មានការយល់ព្រមពីអ្នកកាន់កាប់ទីកន្លែងនោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ៧០១.-** ការបោះបង់ដោយខុសច្បាប់នូវកំទេច ឬវត្ថុ ជាអាទិ៍ នៅលើផ្លូវសាធារណៈ

អំពើដែលធ្វើឱ្យទទឹងទទែងផ្លូវសាធារណៈ ដោយដាក់ ឬទុកចោលដោយគ្មានការចាំបាច់នូវសម្ភារៈសំណង់អ្វីមួយ ឬវត្ថុអ្វីមួយដែលរារាំង បន្ថយការធ្វើចរាចរដោយសេរីនៃមនុស្ស ឬយានយន្ត ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ៧០២.-** ការបង្គាប់ឱ្យដឹកជញ្ជូន ជាបន្ទុករបស់ទណ្ឌិត

ក្នុងករណីផ្តន្ទាទោសពីបទលហុ ដែលមានចែងក្នុងមាត្រា ៦៩៨ (ការបោះបង់ដោយខុសច្បាប់នូវកំទេចយានយន្ត និងវត្ថុក្នុងកន្លែងឯកជន) និងមាត្រា ៧០១ (ការបោះបង់ដោយខុសច្បាប់នូវកំទេច ឬវត្ថុជាអាទិ៍ នៅលើផ្លូវសាធារណៈ) តុលាការអាចបង្គាប់ឱ្យទណ្ឌិតដឹកជញ្ជូនកំទេចកំទី សំរាម កាកសំណល់ ឬសម្ភារៈសំណង់ដោយចេញសោហ៊ុយខ្លួនឯងទៅកាន់កន្លែងមួយដែលតុលាការចាត់តាំង ។

## ផ្នែកទី ២
## សម្លេងរំខាន

**មាត្រា ៧០៣.-** ការធ្វើឱ្យមានសូរស័ព្ទ ឬសូរក្តុងក្តាំង

អំពើបង្កឱ្យមានសូរស័ព្ទ ឬសូរក្តុងក្តាំង ដែលធ្វើឱ្យរំខានដល់ភាពស្ងប់ស្ងាត់របស់អ្នកដទៃ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល ។

# ក្រមព្រហ្មទណ្ឌ

## មាតិកាពិស្តារ

**ទំព័រ**

**ភាគទី ១ គោលការណ៍គ្រឹះ**------------------------------------- ១

**គន្ថីទី ១ គោលការណ៍ទូទៅនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ** ---------------- ១

**មាតិកាទី ១ លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ**------------------- ១

**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ** ------------------------------------- ១

**មាត្រា ១.-** ដែនអនុវត្តនៃក្រមព្រហ្មទណ្ឌ---------------------- ១

**មាត្រា ២.-** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស ------------ ១

**មាត្រា ៣.-** គោលការណ៍នីត្យានុកូលភាព--------------------- ១

**មាត្រា ៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ - ២

**មាត្រា ៥.-** ចេតនាប្រព្រឹត្តបទល្មើស-------------------------- ២

**មាត្រា ៦.-** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ -------------------- ២

**មាត្រា ៧.-** ការប្រកាសទោស ------------------------------ ២

**មាត្រា ៨.-** លក្ខខណ្ឌនៃការអនុវត្តច្បាប់ខ្មែរ ------------------ ២

**មាត្រា ៩.-** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ ----------------------------------- ២

**ជំពូកទី ២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា**------------- ៣

**មាត្រា ១០.-** ការអនុវត្តច្បាប់ដែលស្រាលជាង ----------------- ៣

**មាត្រា ១១.-** ការអនុវត្តច្បាប់ដែលស្រាលជាង ឬធ្ងន់ជាង---------- ៣

**មាត្រា ១២.-** សុពលភាពនៃកិច្ចនីតិវិធី ------------------------ ៣

**ជំពូកទី ៣ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ** -------------------៤

**ផ្នែកទី ១ បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា** -------------------------៤

**មាត្រា ១៣.-** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ------៤

**មាត្រា ១៤.~** ទីកន្លែងប្រព្រឹត្តបទល្មើស ----------------------४
**មាត្រា ១៥.~** បទល្មើសដែលបានប្រព្រឹត្តនៅលើនាវាកម្ពុជា --------៤
**មាត្រា ១៦.~** បទល្មើសដែលបានប្រព្រឹត្តនៅលើនាវាបរទេស -------៤
**មាត្រា ១៧.~** បទល្មើសដែលបានប្រព្រឹត្តនៅលើយន្តហោះកម្ពុជា ----៥
**មាត្រា ១៨.~** ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្តើមប្រព្រឹត្តនៅកម្ពុជា ------------------------៥
**មាត្រា ១៩.~** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល----------៥
**ផ្នែកទី ២ បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា**៥
**មាត្រា ២០.~** បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ ------៥
**មាត្រា ២១.~** ជនរងគ្រោះជាជនជាតិខ្មែរ --------------------៦
**មាត្រា ២២.~** ការធ្វើបណ្តឹងចោទប្រកាន់---------------------៦
**មាត្រា ២៣.~** សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក------៦
**មាត្រា ២៤.~** ការមិនចោទប្រកាន់ត្រួតគ្នា និងទោស------------ ៧
**មាតិកាទី ២ ការទទួលខុសត្រូវព្រហ្មទណ្ឌ** ------------------------- ៧
**ជំពូកទី ១ ចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត** ------------------ ៧
**មាត្រា ២៥.~** និយមន័យនៃចារី------------------------------ ៧
**មាត្រា ២៦.~** និយមន័យនៃសហចារី-------------------------- ៧
**មាត្រា ២៧.~** និយមន័យនៃការប៉ុនប៉ង ------------------------ ៧
**មាត្រា ២៨.~** និយមន័យនៃអ្នកផ្តើមគំនិត -----------------------៨
**មាត្រា ២៩.~** និយមន័យនៃអ្នកសមគំនិត------------------------៨
**មាត្រា ៣០.~** និយមន័យនៃអ្នករាជការសាធារណៈ ពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត --------------៨
**ជំពូកទី ២ មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលនូវ ការទទួលខុសត្រូវព្រហ្មទណ្ឌ** ------------------------------៩

**មាត្រា ៣១.-** មូលហេតុនៃការមិនទទួលខុសត្រូវ
ដោយសារមូលហេតុវិបល្លាស ស្មារតី -------------៩
**មាត្រា ៣២.-** ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ -------------- ១០
**មាត្រា ៣៣.-** ការការពារស្របច្បាប់------------------------ ១០
**មាត្រា ៣៤.-** សច្ចាធារណ៍នៃការពារស្របច្បាប់---------------- ១០
**មាត្រា ៣៥.-** ស្ថានភាពចាំបាច់--------------------------- ១១
**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខំ ------------------ ១១
**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ---------------- ១១
**ជំពូកទី ៣ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌនៃអនីតិជន** ------------- ១២
**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ----------- ១២
**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន ----------------- ១២
**មាត្រា ៤០.-** ប្រភេទនៃវិធានការ -------------------------- ១២
**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ---- ១២
**ជំពូកទី ៤ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល** --------------១៣
**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌនៃនីតិបុគ្គល -----------១៣
**មាតិកា ទី ៣ និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ**----------- ១៤
**ជំពូកទោល ស្ថានទម្ងន់ទោសដោយឡែក** ----------------------- ១៤
**មាត្រា ៤៣.-** ក្រុមមានការចាត់តាំង ------------------------ ១៤
**មាត្រា ៤៤.-** ការគិតទុកជាមុន---------------------------- ១៤
**មាត្រា ៤៥.-** ការកាប់គាស់ទម្លុះទម្លាយ----------------------- ១៤
**មាត្រា ៤៦.-** ការផ្លោះរបងចូល --------------------------- ១៤
**មាត្រា ៤៧.-** អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ -------- ១៤
**មាត្រា ៤៨.-** ការពួនស្ទាក់ ------------------------------ ១៥
**គន្ថីទី ២ ទោស** ------------------------------------ ១៦
**មាតិកាទី ១ ប្រភេទនៃទោស** ----------------------------- ១៦

**ជំពូកទី ១ មូលទោស** ---------------------------------- ១៦

**មាត្រា ៤៩.–** មូលទោស----------------------------------- ១៦

**មាត្រា ៥០.–** អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ------ ១៦

**មាត្រា ៥១.–** ការទម្ងន់ទោស និងការសម្រាលទោស------------ ១៦

**មាត្រា ៥២.–** និយមន័យនៃបទឧក្រិដ្ឋ ------------------------ ១៦

**មាត្រា ៥៣.–** និយមន័យនៃបទមជ្ឈិម ------------------------១៧

**មាត្រា ៥៤.–** និយមន័យនៃបទលហុ --------------------------១៧

**មាត្រា ៥៥.–** ការគណនាអំពីថិរវេលានៃទោសដាក់ពន្ធនាគារ -------១៧

**មាត្រា ៥៦.–** លក្ខខណ្ឌដោយឡែកនៃការបញ្ចប់នៃទោស ----------១៧

**មាត្រា ៥៧.–** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន----១៧

**មាត្រា ៥៨.–** ផលនៃទោសពិន័យ --------------------------- ១៨

**ជំពូកទី ២ ទោសបន្ថែម** ------------------------------- ១៨

**មាត្រា ៥៩.–** ប្រភេទនៃទោសបន្ថែម ------------------------- ១៨

**មាត្រា ៦០.–** លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម ------------- ១៩

**មាត្រា ៦១.–** សិទ្ធិជាពលរដ្ឋដែលអាចដកបាន----------------- ១៩

**មាត្រា ៦២.–** ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ------------២០

**មាត្រា ៦៣.–** ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ - ២០

**មាត្រា ៦៤.–** ការព្យួរលិខិតបើកបរ-------------------------២០

**មាត្រា ៦៥.–** ការហាមឃាត់ចំពោះការស្នាក់នៅកន្លែងមួយចំនួននៅកម្ពុជា
---------------------------------------២០

**មាត្រា ៦៦.–** ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃ
ព្រះរាជាណាចក្រកម្ពុជា-----------------------២១

**មាត្រា ៦៧.–** ការហាមឃាត់ចំពោះការចូល និងស្នាក់នៅលើទឹកដីនៃ
ព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស
---------------------------------------២១

**មាត្រា ៦៨.-** ការរឹបអូស --------------------------------- ២១
**មាត្រា ៦៩.-** ការចាត់ចែងទ្រព្យដែលរឹបអូស ------------------- ២២
**មាត្រា ៧០.-** ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ------------ ២២
**មាត្រា ៧១.-** ការបណ្ដេញចេញពីអាបណសាធារណៈ ----------- ២២
**មាត្រា ៧២.-** ការបិទគ្រឹះស្ថាន ---------------------------- ២៣
**មាត្រា ៧៣.-** ហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ------ ២៣
**មាត្រា ៧៤.-** ការបិទផ្សាយសេចក្ដីសម្រេច ------------------ ២៣
**មាត្រា ៧៥.-** ការចេញផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន សរសេរ ------------------------------------ ២៤
**មាត្រា ៧៦.-** ការផ្សព្វផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសតាមមធ្យោបាយ ទូរគមនាគមន៍សោតទស្សន៍ -------------------- ២៤
**មាត្រា ៧៧.-** ថិរវេលានៃការអនុវត្តទោសបន្ថែម --------------- ២៤
**ជំពូកទី ៣ ទោសជំនួស** ---------------------------------- ២៤
**ផ្នែកទោល ការងារសហគមន៍** ------------------------------ ២៤
**មាត្រា ៧៨.-** និយមន័យនៃការងារសហគមន៍ --------------- ២៤
**មាត្រា ៧៩.-** អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍ ------ ២៥
**មាត្រា ៨០.-** របបគតិយុត្តនៃការងារសហគមន៍--------------- ២៥
**មាត្រា ៨១.-** គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ ----- ២៥
**មាត្រា ៨២.-** របបគតិយុត្តនៃការស្ដីបន្ទោស ---------------- ២៥
**មាតិកាទី ២ ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស** -------------- ២៦
**ជំពូកទី ១ ការមិនរាងចាល** --------------------------------- ២៦
**មាត្រា ៨៣.-** អានុភាពនៃការមិនរាងចាល ------------------- ២៦
**មាត្រា ៨៤.-** លក្ខខណ្ឌនៃការមិនរាងចាល ------------------- ២៦

**មាត្រា ៨៦.-** ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោស
បទឧក្រិដ្ឋ -------------------------------------២៧
**មាត្រា ៨៧.-** ការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោស
បទមជ្ឈិម-------------------------------------២៧
**មាត្រា ៨៨.-** ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោស
បទមជ្ឈិម------------------------------------- ២៨
**មាត្រា ៨៩.-** បទល្មើសប្រដូច ដើម្បីបង្កើតឱ្យមានការមិនរាងចាល -- ២៨
**មាត្រា ៩០.-** ការមិនរាងចាល និងកិច្ចនៃការចោទប្រកាន់--------- ២៨
**មាត្រា ៩១.-** ការមិនរាងចាល និងសេចក្តីសម្រេចស្ថាពរ---------- ២៨
**មាត្រា ៩២.-** បទប្បញ្ញត្តិដោយឡែក ------------------------ ២៩
**ជំពូកទី ២ ស្ថានសម្រាលទោស** --------------------------- ២៩
**មាត្រា ៩៣.-** និយមន័យនៃស្ថានសម្រាលទោស---------------- ២៩
**មាត្រា ៩៤.-** អានុភាពនៃស្ថានសម្រាលទោស ----------------- ២៩
**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាល --៣០
**មាតិកាទី ៣ របបនៃការប្រកាសទោស**-------------------------៣០
**ជំពូកទី ១ របបទូទៅ**-------------------------------------៣០
**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស-------------------៣០
**មាត្រា ៩៧.-** ការប្រកាសមូលទោស ------------------------៣០
**មាត្រា ៩៨.-** ការប្រកាសទោសជំនួស -----------------------៣០
**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស ------------៣១
**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម -----------៣១
**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារ
សហគមន៍ ----------------------------------៣១
**មាត្រា ១០២.-** ចិរវេលា និងអំឡុងពេលនៃការងារសហគមន៍------៣១
**មាត្រា ១០៣.-** បែបបទនៃការអនុវត្តទោសការងារសហគមន៍------ ៣២

**ជំពូកទី ២ ការព្យួរទោសធម្មតា** -------------------------- ៣២

**ផ្នែកទី ១ បទប្បញ្ញត្តិរួម** ---------------------------------- ៣២

**មាត្រា ១០៤.-** ការប្រកាសការព្យួរទោស------------------ ៣២

**មាត្រា ១០៥.-** របបនៃការព្យួរទោស--------------------- ៣២

**ផ្នែកទី ២ ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម** --------- ៣២

**មាត្រា ១០៦.-** លក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសពីមុន ------- ៣២

**មាត្រា ១០៧.-** ទោសអាចនាំឱ្យមានការព្យួរទោស ----------- ៣៣

**មាត្រា ១០៨.-** ការព្យួរទោសមួយផ្នែក-------------------- ៣៣

**មាត្រា ១០៩.-** ការដកហូតការព្យួរទោស------------------ ៣៣

**មាត្រា ១១០.-** ការមិនដកហូត ------------------------- ៣៣

**មាត្រា ១១១.-** ការទុកជាអសារបង់នូវការផ្តន្ទាទោស --------- ៣៣

**ផ្នែកទី ៣ ការចោទប្រកាន់ចំពោះបទលហុ**-------------------៣៤

**មាត្រា ១១២.-** លក្ខខណ្ឌទាក់ទងទៅនឹងការផ្តន្ទាទោសពីមុន------៣៤

**មាត្រា ១១៣.-** ទោសអាចនាំឱ្យមានការព្យួរទោស ------------៣៤

**មាត្រា ១១៤.-** ការដកហូតនៃការព្យួរទោស-----------------៣៤

**មាត្រា ១១៥.-** ការមិនដកហូត --------------------------៣៤

**មាត្រា ១១៦.-** ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស--------៣៥

**ជំពូកទី ៣ ការព្យួរទោសសាកល្បង**--------------------------៣៥

**មាត្រា ១១៧.-** និយមន័យ និងលក្ខខណ្ឌនៃការព្យួរទោសសាកល្បង--៣៥

**មាត្រា ១១៨.-** រយៈពេលនៃការសាកល្បង -------------------៣៥

**មាត្រា ១១៩.-** វិធានការត្រួតពិនិត្យ -------------------------៣៥

**មាត្រា ១២០.-** កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត ---៣៦

**មាត្រា ១២១.-** ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ --- ៣៧

**មាត្រា ១២២.-** ការដកហូតការព្យួរទោសសាកល្បង ----------- ៣៧

**មាត្រា ១២៣.-** ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់ -------៣៨

**ជំពូកទី ៤ ការផ្អាកនៃការប្រកាសទោស** ---------------------- ៣៨
**មាត្រា ១២៤.~** លក្ខខណ្ឌនៃការផ្អាកនៃការប្រកាសទោស ---------- ៣៨
**មាត្រា ១២៥.~** សេចក្តីសម្រេចនៃការផ្អាក -------------------- ៣៨
**មាត្រា ១២៦.~** សវនាការពិនិត្យរឿងដែលបង្អង់ ---------------- ៣៨
**ជំពូកទី ៥ ពាក់កណ្តាលសេរីភាព** ---------------------------- ៣៩
**មាត្រា ១២៧.~** លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព ----------- ៣៩
**មាត្រា ១២៨.~** បែបបទនៃរបបពាក់កណ្តាលសេរីភាព ------------ ៣៩
**មាត្រា ១២៩.~** ការគិតបញ្ចូលរយៈពេលនៃរបបពាក់កណ្តាលសេរីភាព ពីទោស ----------------------------------- ៣៩
**មាត្រា ១៣០.~** ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្តាល សេរីភាព ----------------------------------- ៣៩
**មាត្រា ១៣១.~** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត -------------- ៣៩
**ជំពូកទី ៦ ការបែងចែកទោសជាប្រភាគ** ---------------------- ៤០
**មាត្រា ១៣២.~** លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ --------- ៤០
**មាត្រា ១៣៣.~** បែបបទនៃការបែងចែកទោសជាប្រភាគ ---------- ៤០
**មាត្រា ១៣៤.~** ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ------ ៤០
**មាត្រា ១៣៥.~** លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ---------- ៤០
**មាតិកាទី ៤ វិធានអនុវត្តនៅក្នុងករណីបទល្មើសត្រួតគ្នា** ------------ ៤១
**ជំពូកទី ១ វិធានទូទៅ** ---------------------------------- ៤១
**មាត្រា ១៣៦.~** បទល្មើសត្រួតគ្នា -------------------------- ៤១
**មាត្រា ១៣៧.~** ការចោទប្រកាន់តែមួយ -------------------- ៤១
**មាត្រា ១៣៨.~** ការចោទប្រកាន់ដាច់ពីគ្នា -------------------- ៤១
**ជំពូកទី ២ វិធានដោយឡែក**-------------------------------- ៤២
**មាត្រា ១៣៩.~** ឧប្បត្តិកនៃការលើកលែងទោស និងការបន្ធូរបន្ថយទោស លើការស្រូបទោស -------------------------- ៤២

**មាត្រា ១៤០.~** ការបូកបញ្ចូលគ្នានៃទោសពិន័យ --------------- ៤២

**មាត្រា ១៤១.~** ការមិនស្រូបចូលនៃទោសដែលត្រូវបានប្រកាសចំពោះ
ករណីរត់ចេញពីពន្ធនាគារ--------------------- ៤២

**មាតិកាទី ៥ មូលហេតុទូទៅដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស**--៤៣

**ជំពូកទី ១ អាជ្ញាយុកាលនៃទោស** -----------------------------៤៣

**មាត្រា ១៤២.~** អានុភាពនៃអាជ្ញាយុកាល --------------------៤៣

**មាត្រា ១៤៣.~** ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះ
បទឧក្រិដ្ឋមួយចំនួន--------------------------៤៣

**មាត្រា ១៤៤.~** កំឡុងពេលនៃអាជ្ញាយុកាលបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ
-----------------------------------------៤៣

**មាត្រា ១៤៥.~** ចំណុចចាប់ផ្តើមនៃថិរវេលា -------------------៤៣

**មាត្រា ១៤៦.~** អាជ្ញាយុកាលនៃកាតព្វកិច្ចរដ្ឋប្បវេណីដែលកើតចេញពី
សេចក្តីសម្រេចព្រហ្មទណ្ឌ -------------------- ៤៤

**ជំពូកទី ២ ការអនុគ្រោះទោស** ----------------------------- ៤៤

**មាត្រា ១៤៧.~** និយមន័យ និងអានុភាពនៃការអនុគ្រោះទោស ----- ៤៤

**មាត្រា ១៤៨.~** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការ
អនុគ្រោះទោស------------------------------ ៤៤

**ជំពូកទី ៣ ការលើកលែងទោសជាទូទៅ** ---------------------- ៤៤

**មាត្រា ១៤៩.~** និយមន័យ និងអានុភាពនៃការលើកលែងទោស----- ៤៤

**មាត្រា ១៥០.~** ការលើកលែងទោស និងការដកការព្យួរទោស------ ៤៥

**មាត្រា ១៥១.~** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការ
លើកលែងទោស----------------------------- ៤៥

**ជំពូកទី ៤ ការរៀបចំទោស និងការលុបបំបាត់នូវទោសបន្ថែមខ្លះៗ** --- ៤៥

**មាត្រា ១៥២.~** លក្ខខណ្ឌនៃការកែប្រែទោសបន្ថែមខ្លះៗ ----------- ៤៥

**មាត្រា ១៥៣.~** ការធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ ឬខ្លះៗ- ៤៦

**មាត្រា ១៥៤.~** ការរៀបចំកែប្រែ ឬការលុបចោលនូវការហាមឃាត់-- ៤៦
**មាត្រា ១៥៥.~** ការប្រគល់ឱ្យវិញនូវលិខិតបើកបរ --------------- ៤៦
**មាត្រា ១៥៦.~** ការកែប្រែវិធានការនៃការហាមឃាត់ការស្នាក់នៅ---- ៤៦
**មាត្រា ១៥៧.~** ការកែប្រែការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃ ព្រះរាជាណាចក្រកម្ពុជា ---------------------- ៤៧
**មាត្រា ១៥៨.~** ការកែប្រែការហាមឃាត់ការចូលមកក្នុងដែនដីនៃ ព្រះរាជាណាចក្រកម្ពុជា ---------------------- ៤៧
**មាត្រា ១៥៩.~** ការកែប្រែការបណ្តេញចេញ ការបិទ ការហាមឃាត់ការធ្វើ អាជីវកម្ម ---------------------------------- ៤៧
**មាតិកាទី ៦ ទោសដែលអាចអនុវត្តចំពោះអនីតិជន** ---------------- ៤៨
**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ** -------------------------------- ៤៨
**មាត្រា ១៦០.~** មូលទោសអនុវត្តចំពោះអនីតិជនអាយុលើសពី ១៤ (ដប់បួន) ឆ្នាំ ------------------------------ ៤៨
**មាត្រា ១៦១.~** ទោសបន្ថែម ------------------------------- ៤៨
**មាត្រា ១៦២.~** ទោសការងារសហគមន៍ --------------------- ៤៩
**មាត្រា ១៦៣.~** ការមិនអនុវត្ត ការមិនរាងចាលចំពោះអនីតិជន----- ៤៩
**មាត្រា ១៦៤.~** ការទទួលប្រយោជន៍នៃស្ថានសម្រាល------------- ៤៩
**មាត្រា ១៦៥.~** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង ----------------------------------------- ៥០
**ជំពូកទី ២ បទប្បញ្ញត្តិដោយឡែក** -------------------------- ៥០
**មាត្រា ១៦៦.~** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ ------- ៥០
**មាត្រា ១៦៧.~** ទោសដែលត្រូវរងដោយនីតិបុគ្គល--------------- ៥១
**មាត្រា ១៦៨.~** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល -------------- ៥១
**មាត្រា ១៦៩.~** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម ----------- ៥២
**មាត្រា ១៧០.~** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល -------- ៥២

**មាត្រា ១៧១.-** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ---------------------------------------- ៥២
**មាត្រា ១៧២.-** ការហាមឃាត់ចំពោះការធ្វើសកម្មភាព -----------៥៣
**មាត្រា ១៧៣.-** ការបណ្តេញចេញពីអាបណសាធារណៈ -----------៥៣
**មាត្រា ១៧៤.-** ការហាមចំពោះការធ្វើអំពាវនាវសាធារណៈឱ្យធ្វើការសន្សំសំចៃ --------------------------------៥៣
**មាត្រា ១៧៥.-** ការហាមចំពោះការចេញមូលប្បទានប័ត្រ---------- ៥៤
**មាត្រា ១៧៦.-** ការបិទគ្រឹះស្ថាន---------------------------- ៥៤
**មាត្រា ១៧៧.-** ការហាមចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ------- ៥៤
**មាត្រា ១៧៨.-** ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុដែលរឹបអូស------------------------------------ ៥៤
**មាត្រា ១៧៩.-** ការរឹបអូស និងសិទ្ធិតតិយជន----------------- ៥៥
**មាត្រា ១៨០.-** ការបិទផ្សាយសេចក្តីសម្រេច ------------------ ៥៥
**មាត្រា ១៨១.-** ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍-------------------------------- ៥៥
**មាត្រា ១៨២.-** ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងរូបវន្តបុគ្គល និងនីតិបុគ្គល ------------------------------------------ ៥៦
**ភាគទី ២ បទល្មើសប្រឆាំងនឹងបុគ្គល**------------------------------៥៧
**គន្ថីទី ១ បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម** ---------------------------------------------------------៥៧
**មាតិកាទី ១ បទប្រល័យពូជសាសន៍**---------------------------៥៧
**ជំពូកតែមួយ បទប្រល័យពូជសាសន៍** -----------------------------៥៧
**មាត្រា ១៨៣.-** បទប្រល័យពូជសាសន៍ ----------------------៥៧
**មាត្រា ១៨៤.-** ទោសដែលត្រូវអនុវត្ត ------------------------៥៧
**មាត្រា ១៨៥.-** អំពើត្រៀមរៀបចំក្នុងបទប្រល័យពូជសាសន៍---------៥៧

**មាត្រា ១៨៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៥៨
**មាត្រា ១៨៧.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល -------- ៥៩
**មាតិកាទី ២ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ** ---------------------- ៦០
**ជំពូកទោល បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ** ---------------------- ៦០
**មាត្រា ១៨៨.-** បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ------------------ ៦០
**មាត្រា ១៨៩.-** ទោសដែលត្រូវទទួល ---------------------- ៦១
**មាត្រា ១៩០.-** អំពើត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ---- ៦១
**មាត្រា ១៩១.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៦១
**មាត្រា ១៩២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល -------- ៦២
**មាតិកាទី ៣ បទឧក្រិដ្ឋសង្គ្រាម** ------------------------------ ៦៣
**ជំពូកទោល បទឧក្រិដ្ឋសង្គ្រាម** ------------------------------ ៦៣
**មាត្រា ១៩៣.-** បទឧក្រិដ្ឋសង្គ្រាម -------------------------- ៦៣
**មាត្រា ១៩៤.-** បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត ------------------ ៦៤
**មាត្រា ១៩៥.-** ទោសដែលត្រូវអនុវត្ត ---------------------- ៦៥
**មាត្រា ១៩៦.-** អំពើត្រៀមរៀបចំក្នុងបទឧក្រិដ្ឋសង្គ្រាម ----------- ៦៥
**មាត្រា ១៩៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៦៥
**មាត្រា ១៩៨.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល -------- ៦៦
**គន្ថីទី ២ ការប៉ះពាល់ជីវិតមនុស្ស** ---------------------------- ៦៨
**មាតិកាទី ១ ការប៉ះពាល់ជីវិតមនុស្ស** -------------------------- ៦៨
**ជំពូកទី ១ ការប៉ះពាល់ដោយចេតនាដល់ជីវិតមនុស្ស** -------------- ៦៨
**មាត្រា ១៩៩.-** ឃាតកម្ម ---------------------------------- ៦៨
**មាត្រា ២០០.-** ឃាតកម្មគិតទុកជាមុន ---------------------- ៦៨
**មាត្រា ២០១.-** ឃាតកម្មដែលប្រព្រឹត្តដោយការប្រើថ្នាំពុល -------- ៦៨
**មាត្រា ២០២.-** ឃាតកម្មដែលមានស្ថានទម្ងន់ទាក់ទងនឹងជនរងគ្រោះ - ៦៩
**មាត្រា ២០៣.-** ឃាតកម្មដែលមានស្ថានទម្ងន់អាស្រ័យទៅនឹងគោលដៅ ៦៩

**មាត្រា ២០៤.-** ឃាតកម្មប្រព្រឹត្តដោយមន្ត្រីរាជការ ------------- ៦៩
**មាត្រា ២០៥.-** ឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ
ឬអំពើរំលោភ សេពសន្ថវៈ -------------------- ៧០
**មាត្រា ២០៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៧០
**ជំពូកទី ២ ការប៉ះពាល់ដោយអចេតនាដល់ជីវិត**------------------ ៧១
**មាត្រា ២០៧.-** បទមនុស្សឃាតដោយអចេតនា---------------- ៧១
**មាត្រា ២០៨.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៧១
**មាត្រា ២០៩.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល -------- ៧២
**មាតិកាទី ២ ការប៉ះពាល់ដល់បូរណភាពនៃបុគ្គល** ------------------ ៧៣
**ជំពូកទី ១ ទារុណកម្ម និងអំពើឃោរឃៅ** --------------------- ៧៣
**មាត្រា ២១០.-** ទារុណកម្ម និងអំពើឃោរឃៅ --------------- ៧៣
**មាត្រា ២១១.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនរងគ្រោះ ----------- ៧៣
**មាត្រា ២១២.-** ស្ថានទម្ងន់ទាក់ទងទៅនឹងគោលដៅ------------- ៧៤
**មាត្រា ២១៣.-** ស្ថានទម្ងន់ទាក់ទងទៅនឹងចារី ----------------- ៧៤
**មាត្រា ២១៤.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមានការកាត់ផ្តាច់អវយវៈ
និងពិការភាព ------------------------------ ៧៤
**មាត្រា ២១៥.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមរណភាពនៃជនរងគ្រោះ
---------------------------------------- ៧៤
**មាត្រា ២១៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល----------- ៧៥
**ជំពូកទី ២ អំពើហិង្សា**------------------------------------ ៧៦
**មាត្រា ២១៧.-** អំពើហិង្សាដោយចេតនា-------------------- ៧៦
**មាត្រា ២១៨.-** ស្ថានទម្ងន់ -------------------------------- ៧៦
**មាត្រា ២១៩.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនរងគ្រោះ ------------ ៧៦
**មាត្រា ២២០.-** ស្ថានទម្ងន់ទាក់ទងទៅនឹងគោលដៅ ------------- ៧៧
**មាត្រា ២២១.-** ស្ថានទម្ងន់ទាក់ទងទៅនឹងចារី ----------------- ៧៧

**មាត្រា ២២២.-** អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន ៧៧
**មាត្រា ២២៣.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមានការកាត់ផ្តាច់អវៈយវៈ
និងពិការភាព ---------------------------------- ៧៨
**មាត្រា ២២៤.-** ស្ថានទម្ងន់ដែលបណ្តាលមកពីមរណភាពនៃជនរងគ្រោះ
------------------------------------------ ៧៨
**មាត្រា ២២៥.-** ការប្រដូចការប្រើសារជាតិពុលទៅនឹងអំពើហិង្សាដោយ
ចេតនា-------------------------------------- ៧៨
**មាត្រា ២២៦.-** ការប្រដូចការផ្តល់អាហារដែលមានសារជាតិពុលទៅនឹង
អំពើហិង្សាដោយចេតនា ---------------------- ៧៨
**មាត្រា ២២៧.-** ការប្រដូចការបញ្ចូលសារធាតុជាតិពុលក្នុងទឹកសម្រាប់
បរិភោគទៅនឹងអំពើហិង្សាដោយចេតនា------------ ៧៨
**មាត្រា ២២៨.-** អំពើហិង្សាស្រាល -------------------------- ៧៨
**មាត្រា ២២៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៧៩
**មាត្រា ២៣០.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល-------- ៧៩
**ជំពូកទី ៣ ការគំរាមកំហែង** ---------------------------------- ៨១
**មាត្រា ២៣១.-** អំពើគំរាមកំហែង---------------------------- ៨១
**មាត្រា ២៣២.-** ការគំរាមកំហែងដោយការបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ
------------------------------------------ ៨១
**មាត្រា ២៣៣.-** ការគំរាមកំហែងថានឹងសម្លាប់ ----------------- ៨២
**មាត្រា ២៣៤.-** ការគំរាមថានឹងសម្លាប់ ដោយមានបញ្ជាឱ្យបំពេញ
លក្ខខណ្ឌអ្វីមួយ ----------------------------- ៨២
**មាត្រា ២៣៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៨២
**ជំពូកទី ៤ ការបង្កឱ្យមានរបួសដោយអចេតនា** -------------------៨៣
**មាត្រា ២៣៦.-** អំពើបង្កឱ្យមានរបួសដោយអចេតនា -------------៨៣
**មាត្រា ២៣៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៨៤

**មាត្រា ២៣៨.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល-------- ៨៤
**មាតិកាទី ៣ ការឈ្លានពានខាងផ្លូវភេទ** ------------------------- ៨៥
**ជំពូកទី ១ ការរំលោភសេពសន្ថវៈ**----------------------------- ៨៥
**មាត្រា ២៣៩.-** ធាតុផ្សំបទរំលោភសេពសន្ថវៈ ------------------ ៨៥
**មាត្រា ២៤០.-** ស្ថានទម្ងន់ដោយផ្អែកលើមធ្យោបាយដែលប្រើប្រាស់
ឬទាក់ទងនឹង ជនល្មើស--------------------- ៨៦
**មាត្រា ២៤១.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនរងគ្រោះ ------------ ៨៦
**មាត្រា ២៤២.-** ស្ថានទម្ងន់បណ្ដាលមកពីមានការកាត់អវៈយវៈ
ឬពិការភាព --------------------------------- ៨៧
**មាត្រា ២៤៣.-** ស្ថានទម្ងន់បណ្ដាលមកពីការធ្វើទារុណកម្ម ឬអំពើ
ឃោរឃៅ----------------------------------- ៨៧
**មាត្រា ២៤៤.-** ស្ថានទម្ងន់បណ្ដាលមកពីមរណភាពនៃជនរងគ្រោះ --- ៨៧
**មាត្រា ២៤៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល----------- ៨៧
**ជំពូកទី ២ ការឈ្លានពានផ្លូវភេទដទៃទៀត** --------------------- ៨៨
**មាត្រា ២៤៦.-** អំពើអាស -------------------------------- ៨៨
**មាត្រា ២៤៧.-** ស្ថានទម្ងន់ដោយផ្អែកលើមធ្យោបាយដែលប្រើប្រាស់
ឬទាក់ទងនឹងជនល្មើស ------------------------ ៨៨
**មាត្រា ២៤៨.-** ស្ថានទម្ងន់ទាក់ទងទៅនឹងជនរងគ្រោះ ------------ ៨៩
**មាត្រា ២៤៩.-** ការបង្ហាញកេរភេទ -------------------------- ៨៩
**មាត្រា ២៥០.-** អំពើរុកកួនខាងផ្លូវភេទ ----------------------- ៨៩
**មាត្រា ២៥១.-** ការប៉ុនប៉ង--------------------------------- ៩០
**មាត្រា ២៥២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៩០
**មាតិកាទី ៤ ការប៉ះពាល់ដល់សេរីភាព** -------------------------- ៩១
**ជំពូកទី ១ ការចាប់ ការឃុំឃាំង និងការបង្ខាំងខុសច្បាប់** ------------ ៩១
**មាត្រា ២៥៣.-** អំពើចាប់ ឃុំឃាំង ឬបង្ខាំងខុសច្បាប់ ----------- ៩១

**មាត្រា ២៥៤.-** ស្ថានទម្ងន់ទោស-------------------------- ៩១
**មាត្រា ២៥៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល----------- ៩២
**ជំពូកទី ២ ការប៉ះពាល់ដល់សេរីភាពដទៃទៀត** ------------------- ៩៣
**មាត្រា ២៥៦.-** អំពើដណ្ដើមកាន់កាប់មធ្យោបាយដឹកជញ្ជូន -------- ៩៣
**មាត្រា ២៥៧.-** ស្ថានទម្ងន់បណ្ដាលមកពីមានការកាត់អវៈយវៈ
ឬពិការភាព -------------------------------- ៩៣
**មាត្រា ២៥៨.-** ស្ថានទម្ងន់បណ្ដាលមកពីការធ្វើទារុណកម្ម
ឬអំពើឃោរឃៅ ----------------------------- ៩៣
**មាត្រា ២៥៩.-** ស្ថានទម្ងន់បណ្ដាលមកពីមានការកាត់អវៈយវៈ
ឬពិការភាព -------------------------------- ៩៣
**មាត្រា ២៦០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៩៣
**មាតិកាទី ៥ ការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ** ------------------------ ៩៥
**ជំពូកទី ១ ការប៉ះពាល់ដល់ការគោរព ដែលត្រូវឱ្យមានចំពោះអ្នកដែលស្លាប់**
------------------------------------------ ៩៥
**មាត្រា ២៦១.-** អំពើប៉ះពាល់ដល់បូរណភាពនៃសាកសព ---------- ៩៥
**មាត្រា ២៦២.-** អំពើប្រមាថទីបញ្ចុះសព --------------------- ៩៥
**មាត្រា ២៦៣.-** ការប៉ុនប៉ង -------------------------------- ៩៥
**មាត្រា ២៦៤.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៩៥
**ជំពូកទី ២ ការរើសអើង** ------------------------------------ ៩៦
**មាត្រា ២៦៥.-** អំពើបដិសេធក្នុងការផ្ដល់ទ្រព្យ ឬសេវា ---------- ៩៦
**មាត្រា ២៦៦.-** អំពើផ្ដល់ទ្រព្យ ឬសេវាដោយមានលក្ខខណ្ឌ ------- ៩៦
**មាត្រា ២៦៧.-** អំពើបដិសេធនូវការជួលបុគ្គលឱ្យធ្វើការ ---------- ៩៧
**មាត្រា ២៦៨.-** អំពើបដិសេធនូវការជួលបុគ្គលឱ្យធ្វើការ ---------- ៩៧
**មាត្រា ២៦៩.-** ទោសដែលអនុវត្តចំពោះការបណ្ដេញចេញ
ឬដកហូតដោយផ្អែកលើ មូលហេតុនៃការរើសអើង --- ៩៨

**មាត្រា ២៧០.~** ការរើសអើង ការបដិសេធផ្តល់សិទ្ធិដោយអ្នករាជការ ៩៨
**មាត្រា ២៧១.~** ការរើសអើងដែលអនុញ្ញាតដោយច្បាប់ ----------- ៩៨
**មាត្រា ២៧២.~** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------- ៩៩
**មាត្រា ២៧៣.~** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ------- ៩៩
**ជំពូកទី ៣ លក្ខខណ្ឌការងារផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស**---------១០០
**មាត្រា ២៧៤.~** អំពើដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស---------------------------១០០
**មាត្រា ២៧៥.~** ការប៉ុនប៉ង ------------------------------១០០
**មាត្រា ២៧៦.~** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------១០១
**មាត្រា ២៧៧.~** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ------១០១
**ជំពូកទី ៤ អំពើពុករលួយនៃនិយោជិត**----------------------- ១០៣
**មាត្រា ២៧៨.~** អំពើស៊ីសំណូកនៃនិយោជិត ---------------- ១០៣
**មាត្រា ២៧៩.~** អំពើសូកប៉ាន់ចំពោះនិយោជិត---------------- ១០៣
**មាត្រា ២៨០.~** អំពើស៊ីសំណូករបស់អភិបាល ជាអាទិ៍---------- ១០៣
**មាត្រា ២៨១.~** ការប៉ុនប៉ង--------------------------------១០៤
**មាត្រា ២៨២.~** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---------១០៤
**មាត្រា ២៨៣.~** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល-------១០៤
**ជំពូកទី ៥ សញ្ញារកម្ម** ------------------------------------១០៦
**មាត្រា ២៨៤.~** សញ្ញារកម្ម--------------------------------១០៦
